# ការត្រួតពិនិត្យមីន



# 2006




តំបន់រងគ្រោះថ្នាក់ ឆ្នាំ 1979-2005

# កម្ពុជា




តំបន់រងគ្រោះថ្នាក់ឆ្នាំ 2005

## របាយការណ៍ប្រចាំឆ្នាំលើកទី៨

## ប្រទេសកម្ពុជា

*ការអភិវឌ្ឍន៍សំខាន់ៗចាប់តាំងពី ខែឧសភា ឆ្នាំ២០០៥:* ប្រទេសកម្ពុជាបានប្រកាសថា ពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០០៥ គ្រាប់មីនប្រឆាំងមនុស្សដែលគេប្រមូលរក្សាទុកចំនួនសរុប ៧១ ១៣៦ គ្រាប់ ត្រូវបានគេរកឃើញ និង បំផ្លាញចោលក្នុងពេលថ្មីៗនេះ ដែលក្នុងនោះរួមមានគ្រាប់មីនចំនួន ១៦ ៨៧៨ គ្រាប់ នៅឆ្នាំ ២០០៥ ដែលជាចំនួនគ្រាប់មីនត្រូវបានបោសសំអាតច្រើនជាងគេបំផុតគិតក្នុងរយៈពេល០១ ឆ្នាំ ។ ការបោសសំអាតមីនបានកើនឡើងច្រើនជាង ៦៣ % នៅក្នុងឆ្នាំ ២០០៥ អាស្រ័យដោយកំនើននៃការបោសសំអាតមីន ធ្វើឡើងដោយមជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា និងដោយសារប្រតិបត្តិការផ្សេងៗទៀត ដែលបានចាត់ទុកថាផ្ទៃដីកំពុងដាំដុះ និងដីដែលគ្មានឧបទ្ទវហេតុជាកន្លែងមិនសូវមានគ្រោះថ្នាក់។ យុទ្ធសាស្ត្រកាត់បន្ថយផ្ទៃដីនេះត្រូវបានអនុម័តយល់ព្រមដោយរដ្ឋាភិបាល នៅក្នុងខែឧសភា ឆ្នាំ ២០០៦ ។ នៅក្នុងឆ្នាំ ២០០៥ មានគ្រោះថ្នាក់ដោយសារគ្រាប់មីនកប់ដី និងគ្រាប់មិនទាន់ផ្ទុះចំនួន៨៧៥ករណើ គិតជាមធ្យមគឺមានគ្រោះថ្នាក់ពីរករណើក្នុងមួយថ្ងៃចាប់តាំងពីឆ្នាំ ២០០០មក។ ដើម្បីដោះស្រាយបញ្ហានេះ យុទ្ធសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីនត្រូវបានគេធ្វើការពិនិត្យពិចារណាឡើងវិញ នៅក្នុងឆាំ ២០០៦។ គ្រោះថ្នាក់ចំពោះអ្នកដោះមីនចំនួន ២២ ករណើត្រូវបានគេកត់ត្រានៅក្នុងឆ្នាំ ២០០៥ ប៉ុន្តែមានតែ ១៤ ករណើប៉ុណ្ណោះ ដែលកើតមានចំពោះអ្នកប្រតិបត្តិការដោះមីនដែលគេបានស្គាល់។ កងទ័ពកម្ពុជាបានបញ្ជូនអ្នកដោះមីនជាលើកទី១ទៅចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

## គោលនយោបាយលុបបំបាត់មីន

ព្រះរាជាណាចក្រកម្ពុជាបានចុះហត្ថលេខាលើសន្ធិសញ្ញាប្រឆាំងនឹងការប្រើប្រាស់គ្រាប់មីន កាលពីថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ និងបានធ្វើសច្ចានុម័តនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៩ ហើយសន្ធិសញ្ញានេះបានចូលជាធរមានចាប់តាំងពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០០០។ ច្បាប់អនុវត្តន៍ក្នុងស្រុក " ច្បាប់ស្តីពីការហាមឃាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស "បានចូលជាធរមាន នៅថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ។[1]

ប្រទេសកម្ពុជាបានផ្តល់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ស្តីពីតម្លាភាពនៃការអនុវត្តន៍មាត្រាទី ៧ សំរាប់ឆ្នាំ ២០០៥ រួចហើយ ព្រមទាំងបានផ្តល់សំណុំបែបបទបំពេញដោយស្ម័គ្រចិត្ត J (Voluntary Form J) ដែលរាយការណ៍អំពីសកម្មភាពជួយអ្នករងគ្រោះ។ កន្លងមកប្រទេសកម្ពុជាបានផ្តល់របាយការណ៍ចំនួន ០៦ ។[2]

អគ្គលេខាធិការនៃអាជ្ញាធរមីនកម្ពុជា ហៅកាត់ថា (CMAA) បានដឹកនាំគណៈប្រតិភូកម្ពុជាមួយក្រុមទៅចូលរួមក្នុងកិច្ចប្រជុំរបស់រដ្ឋជាសមាជិកទាំងអស់លើកទី ៦ នៅទីក្រុង Zagreb ប្រទេសក្រូអាត ពីខែវិច្ឆិកា ដល់ ខែ ធ្នូ ឆាំ ២០០៥។

---

[1] The law bans the production, use, possession, transfer, trade, sale, import and export of antipersonnel mines. It provides for criminal penalties, including fines and imprisonment for offenses committed by civilians or members of the police and the armed forces. It also provides for the destruction of mine stockpiles.

[2] Landmine Monitor obtained a copy of Cambodia's Article 7 report dated April 2006, for calendar year 2005; this was not recorded by the UN website as of 19 June 2006. Previous reports were submitted on 22 April 2005, 30 April 2004, 15 April 2003, 19 April 2002, 30 June 2001 and 26 June 2000 (this report covered the period from 1993 to 26 June 2000).

ប្រទេសកម្ពុជាបានធ្វើបទអន្តរាគមន៍នៅក្នុងសម័យប្រជុំនានាស្តីអំពីការបោសសំអាតមីន និងអំពីការជួយជន រងគ្រោះ។

ប្រទេសកម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រជុំអន្តរសម័យប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៅទីក្រុង Geneva ក្នុងខែ មិថុនា ឆ្នាំ ២០០៥ និង ក្នុងខែ ឧសភា ឆ្នាំ ២០០៦។ ខុសប្លែកពីកិច្ចប្រជុំមុនៗ នៅក្នុងខែ ឧសភា ប្រទេសកម្ពុជា មិនបានធ្វើសេចក្តីថ្លែងការណ៍ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនចំពោះការបោសសំអាតមីននិងការជួយជនរងគ្រោះឡើយ។

ប្រទេសកម្ពុជា មិនបានចូលរួមក្នុងកិច្ចពិភាក្សាបន្ត ដែលភាគីជាសមាជិកត្រូវចូលរួមជជែកវែកញែក ស្តីពីការបកស្រាយ និងការអនុវត្តន៍មាត្រាទី១, ២, និងទី ៣ ហើយជាពិសេសបញ្ហាដែលពាក់ព័ន្ធនឹងប្រតិបត្តិការយោធាចំរុះជាមួយរដ្ឋដែលមិនមែនជាសមាជិក បញ្ហាគ្រាប់មីនប្រឆាំងយានយន្តដែលមានខ្សែឆ្នូនរូស ឬ ឧបករណ៍ប្រឆាំងនឹងការប៉ះពាល់ (antihandling devices) និងបញ្ហាចំនួនគ្រាប់មីនដែលគេអនុញ្ញាតអោយរក្សាទុកសំរាប់ការបណ្តុះបណ្តាល។

ប្រទេសកម្ពុជាគឺជារដ្ឋសមាជិកនៃសន្ធិសញ្ញាស្តីពីសព្វាវុធមិនមែននុយក្លេអ៊ែរ (CCW) និងពិធីសារកែសំរួលលើកទី២នៃសន្ធិសញ្ញានេះស្តីពីគ្រាប់មីនកប់ដី។ ប្រទេសកម្ពុជាបានចូលរួមក្នុងសន្និសីទប្រចាំឆ្នាំលើកទី៧ របស់រដ្ឋជាសមាជិកនៃពិធីសារនេះក្នុងទីក្រុង Geneva នាខែ វិច្ឆិកា ឆ្នាំ ២០០៥ ។ កម្ពុជាបានផ្តល់របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ដូចដែលបានកំនត់ក្នុងមាត្រាទី ១៣ នៅថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៥ ។

*<u>សកម្មភាពអង្គការក្រៅរដ្ឋាភិបាល</u>*

យុទ្ធនាការរបស់ប្រទេសកម្ពុជាប្រឆាំងនឹងការប្រើប្រាស់គ្រាប់មីន (CCBL) បានចាប់ផ្តើមនៅឆ្នាំ១៩៩៤។ កម្ពុជាបានផ្តល់របាយការណ៍ត្រួតពិនិត្យគ្រាប់មីននៅប្រទេសកម្ពុជា ជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៩។ អង្គការ Jesuit Refugee Service Cambodia បានដើរតួនាទីនាំមុខគេ។ អង្គការវេទិកាសកម្មភាពមីន ដែលចូលរួមដោយ អ្នកប្រតិបត្តិការបោសសំអាតមីន ទីភ្នាក់ងារអភិវឌ្ឍន៍នានា អ្នកកសាងយុទ្ធសាស្ត្រទាក់ទិននឹងគ្រោះថ្នាក់ដោយសារមីន និងអង្គការ CCBL គឺជាអង្គការសំរបសំរួលបញ្ហាទាក់ទងនឹងការបោសសំអាតគ្រាប់មីន និងការអភិវឌ្ឍន៍ ។ មានក្រុមសំរាប់ជួយជនរងគ្រោះមួយក្រុមដែលមានសមាជិកខ្លះមកពីអង្គការវេទិកាសកម្មភាពមីន និងក្រុមប្រឹក្សាសកម្មភាពជនពិការ ។

របាយការណ៍ត្រួតពិនិត្យគ្រាប់មីនឆ្នាំ ២០០៥ ត្រូវបានគេចែកចាយនៅតាមដងផ្លូវក្នុងពេលប្រកួតកីឡារត់ប្រណាំង ម៉ារ៉ាតុនពីសៀមរាបទៅកាន់ក្រុងភ្នំពេញកាលពីថ្ងៃទី ២៧ ខែ វិច្ឆិកា ដល់ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០០៥។ ព័ត៌មានជាក់ស្តែងអំពីគ្រាប់មីន និង អត្ថបទសង្ខេបអំពីបញ្ហាគ្រាប់មីននៅទូទាំងពិភពលោកត្រូវបានគេផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅកន្លែងឈប់សំរាកនីមួយៗ នៃការរត់ប្រណាំង។

ចំពោះទិវាយល់ដឹងអំពីមីននៅកម្ពុជានាថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ២០០៦ អង្គការ CCBL បានផ្ញើលិខិតទៅស្ថានទូតរដ្ឋាភិបាល និងទៅអង្គការក្រៅរដ្ឋាភិបាលនានា។[3] នៅក្នុងឱកាសនោះ មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា អង្គការ CCBL

[3] The text of the letter follows: "Dear Friends of a Mine Free Cambodia, This week we celebrate Mine Awareness Day in Cambodia. Some of you with long memories will recall the birth of the landmine campaign here in Cambodia in 1994. To initiate it, four Cambodia men wrote a letter, which gathered more than a million signatures from around the world. This week one of them Suon Chreuk died suddenly. In honour of his memory we reprint the letter which was signed by HRH King Sihanouk, the Prime Minister Samdech Hun Sen, HRH Prince Norodom Rannaridh, Excellency Sam Rainsy and many other famous Cambodians: 'We are

និង អង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត បានមកជួបជុំគ្នានៅភូមិបឹងត្រកួន ស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ដើម្បីផ្សព្វផ្សាយការយល់ដឹងអំពីមីននៅក្នុងខេត្តមួយដែលទទួលរងគ្រោះខ្លាំងដោយសារគ្រាប់មីន។

ចំពោះកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីអ្នកផ្តល់ជំនួយសំរាប់កម្ពុជា ពីថ្ងៃទី ២ ដល់ទី ៤ ខែ មិនា ឆ្នាំ ២០០៦ អង្គការយុទ្ធនាការលុបបំបាត់មីនកម្ពុជា (CCBL) អង្គការជនពិការអន្តរជាតិ (Handicap International) និង អង្គការជំនួយរបស់ប្រជាជនណ័រវេស (Norwegian People’s Aid) បានរៀបចំធ្វើសេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាលមួយស្តីពីសកម្មភាព មនុស្សធម៌ទាក់ទិននឹងបញ្ហាមីន។ សេចក្តីថ្លែងការណ៍នោះបានប្រកាសអោយដឹងថា” រាជរដ្ឋាភិបាលកម្ពុជាបន្តគាំទ្រយ៉ាង សកម្មនូវសន្ធិសញ្ញាប្រឆាំងនឹងការប្រើប្រាស់គ្រាប់មីន” ។ បើទោះបីជាគេបានធ្វើអោយមានការរីកចំរើនជាក់ស្តែងខ្លះនៅក្នុងឆ្នាំ ២០០៥ លើផ្នែកបោសសំអាតមីន, ផែនការកម្ម, ការប្រមូល, ការបំផ្លាញចោល, ការអប់រំស្តីពីគ្រោះថ្នាក់បណ្តាលមកពីគ្រាប់មីន, ការស្រាវជ្រាវ និងការគ្រប់គ្រងទិន្នន័យយ៉ាងណាក្តី ក៏ការកែទំរង់ និងការធ្វើអោយជឿនលឿនបន្ថែម ទៀតនៅតែមានលក្ខណៈចាំបាច់ ប្រសិនបើប្រទេសកម្ពុជាចង់សំរេចបាននូវទិសដៅរបស់ខ្លួននិងគោលដៅនៃសន្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីន។ ជាពិសេស គេត្រូវការការជួយឧបត្ថម្ភបន្ថែមទៀតខាងផ្នែកជំនួយសំរាប់ជនរងគ្រោះ ។[4]

អង្គការ CCBL បានជួយសំរបសំរួលក្នុងកិច្ចប្រជុំស្រាវជ្រាវសាកលស្តីពីការត្រួតពិនិត្យគ្រាប់មីន (Landmine Monitor Global Research Meeting) ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ២ ដល់ទី ៤ ខែ មេសា ឆ្នាំ ២០០៦ នៅទីក្រុង ភ្នំពេញ។

## ការផលិត ការដឹកជញ្ជូន និងការប្រើប្រាស់

រដ្ឋាភិបាលបានរាយការណ៍អោយដឹងថាខ្លួនពុំមានសំភារៈផលិតគ្រាប់មីនប្រឆាំងមនុស្សទេ ។[5] ក្នុងអតីតកាល គេក៏ដឹងថាប្រទេសកម្ពុជាមិនបាននាំចេញនូវគ្រាប់មីនប្រឆាំងមនុស្សឡើយ ។ ការត្រួតពិនិត្យគ្រាប់មីនមិនបានស្វែងយល់ពីការលក់ដូរជាលក្ខណៈឯកជននូវគ្រាប់មីនប្រឆាំងមនុស្សឡើយ បើទុកជាមានការរកស៊ីជួញដូរភ្លាមនូវកាកសំណល់លោហៈ (អេតចាយ) ដែលបានមកពីគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះដែលគេបោះបង់ចោល ។ ពុំមានការចោទប្រកាន់ច្បាស់លាស់ណាមួយទាក់ទិននឹងការប្រើប្រាស់ ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស ដោយកងកំលាំងរដ្ឋាភិបាល ឬកងកំលាំងប្រឆាំងនានាឡើយ ចាប់តាំងពីឆ្នាំ ១៩៩៩ មក។

## ការស្តុកទុក និង ការបំផ្លាញចោល

កងយោធពលខេមរភូមិន្ទ បានបំផ្លាញចោលនូវគ្រាប់មីនប្រឆាំងមនុស្ស ដែលខ្លួនបានប្រមូលទុកចំនួន ៧១,៩៩១

---

amputees. Before we were soldiers, members of different armies that laid mines and blew the legs and arms and eyes off one another. Now we teach and learn together in the The Centre of the Dove. We beg the world to stop making mines, We beg the world to stop laying mines, We beg for funds for clearing mines so that we can rebuild our families, our villages and our country again.’ Signed by *Tun Channareth*, *Hem Phang*, *Khlieng Vann*, *Suon Chreuk*, *1994*. Twelve year later where are we? Much land has been cleared, but not yet enough. Survivors have received some assistance, but not yet enough. Mine affected communities are developing their areas, but need much more help.”

[4] Statement by the NGO community in Cambodia to the Consultative Group on Cambodia Donors Meeting, 19 January 2006.

[5] Article 7 Reports, Form E. In the 1970s, Cambodia manufactured one type of antipersonnel landmine, the KN-10 Claymore-type mine, and various forces manufactured home-made mines in the past.

គ្រាប់ ក្នុងចន្លោះឆ្នាំ១៩៩៤ និងឆ្នាំ ១៩៩៨ ហើយនៅក្នុងខែកុម្ភៈ ឆ្នាំ ១៩៩៩ អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ បានប្រកាសជាផ្លូវការថា កងយោធពលខេមរភូមិន្ទ លែងមានគ្រាប់មីនប្រឆាំងមនុស្សក្នុងស្តុកទៀតហើយ ។[6]

នៅក្នុងឆ្នាំ ២000 ប្រទេសកម្ពុជាបានរាយការណ៍អោយដឹងថា គ្រាប់មីនប្រឆាំងមនុស្សក្នុងឃ្លាំងចំនួន ២,0៣៤ គ្រាប់ស្ថិតក្រោមការគ្រប់គ្រងដោយនគរបាលជាតិ ។[7] ប្រទេសកម្ពុជាបានប្រកាសជាបន្តបន្ទាប់ថា គ្មានគ្រាប់មីនប្រឆាំងមនុស្សក្នុងស្តុកទៀតឡើយ ចាប់តាំងពីឆ្នាំ ២00១ មក ។[8]

ក៏ប៉ុន្តែ កងឯកភាពនគរបាលនិងយោធានៅតែបន្តរកឃើញគ្រាប់មីនប្រឆាំងមនុស្សនិងសព្វាវុធផ្សេងៗទៀតនៅតាមទីកន្លែងនានា និងប្រភពផ្សេងៗជុំវិញផ្ទៃប្រទេស ។ គ្រាប់មីនជាច្រើនគឺជាគ្រាប់ដែលបានបន្សល់ទុកដោយសារសង្គ្រាមរាប់ទសវត្សកន្លងមក ។ ការដោះមីនក្រៅផ្លូវការ (តាមភូមិ) និងការជួញដូរសំណល់អេតចាយក៏គេចាត់ទុកជាស្តុកគ្រាប់មីនដែលគេរកឃើញថ្មី ។ គេត្រូវរាយការណ៍អំពីគ្រាប់មីនទាំងនោះអោយអាជ្ញាធរមីនកម្ពុជា (CMAA) បានដឹង និងត្រូវប្រគល់វាទៅអោយ អង្គការ CMAC ដើម្បីធ្វើការកំទេចចោល, គេក៏អាចយកគ្រាប់មីនទាំងនោះខ្លះប្រើប្រាស់សំរាប់ការបណ្តុះបណ្តាល ។[9] ការររកឃើញនិងការរៀបចំទុកដាក់នូវគ្រាប់មីនចាស់ៗទាំងនេះ មិនត្រូវបានគេរាយការណ៍ជានិច្ចកាល ឬ ទាំងអស់ឡើយ នៅក្នុងរបាយការណ៍មាត្រាទី៧លើកមុនរបស់កម្ពុជា ។[10]

នៅក្នុងរបាយការណ៍មាត្រាទី៧របស់ខ្លួនសំរាប់ខែវិច្ឆិកា ឆ្នាំ ២00៦ ប្រទេសកម្ពុជាបានប្រកាសថា ពីឆ្នាំ ២000 ដល់ឆ្នាំ ២00៥ គ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៧១,១៣៦ គ្រាប់ ត្រូវបានគេរកឃើញនិងបំផ្លាញចោល ក្នុងនោះរួមមានមីន ១៦,៨៧៨ គ្រាប់ ត្រូវបានកំទេចចោលដោយទីភ្នាក់ងារបីនៅក្នុងឆ្នាំ ២00៥: ៩,៥៤៤ គ្រាប់ដោយ CMAC, ៥,៧២0គ្រាប់ ដោយអង្គការ HALO Trust និង១,៦១៤គ្រាប់ ដោយក្រុមផ្តល់យោបល់អំពីបញ្ហាមីន Mines Advisory Group (MAG) ។ នោះគឺជាចំនួនមីនដ៏ច្រើនជាងគេធៀបនឹងឆ្នាំមុនៗ ។ ប្រទេសកម្ពុជាបានកត់សំគាល់ឃើញថាគ្រាប់មីនទាំងនោះ" ត្រូវបានប្រមូលដោយជនស៊ីវិលនិងអាជ្ញាធរយោធាពីប្រភព ទីតាំង និងកាកសំណល់អេតចាយផ្សេងៗ ។[11]

នៅក្នុងខែសីហា ឆ្នាំ ២00៥ អង្គការ HALO បានរាយការណ៍អោយដឹងថា កាលពីពីរបីសប្តាហ៍មុន កងយោធពលខេមរភូមិន្ទបានប្រគល់គ្រាប់មីនប្រឆាំងមនុស្ស ចំនួនច្រើនជាង ១២,000 គ្រាប់ ។ អង្គការ HALO បានជួយកងយោធពលខេមរភូមិន្ទក្នុងការរៀបចំចាត់ចែងគ្រាប់រំសេវចាស់ៗ ដែលគេមិនត្រូវការនៅក្នុងឃ្លាំងផ្ទុកសំភារៈដ៏ធំរបស់ខ្លួនក្នុងខេត្តកំពង់ស្ពឺ ។ អង្គការ HALO បានកត់សំគាល់ឃើញថាគ្រាប់មីនភាគច្រើនត្រូវបានគេដាក់ក្នុងកេសនិងស្ថិតក្នុងលក្ខណៈត្រឹមត្រូវ " ហើយបានពោលសំដៅទៅកិច្ចការនេះថាជា " ឧទាហរណ៍ដែលគេអាចត្រួតពិនិត្យបានដោយឯករាជ្យ

[6] See *Landmine Monitor Report 1999*, p. 391, for annual destruction totals.
[7] Article 7 Report, Form B, 26 June 2000.
[8] Article 7 Report, Form F, 30 April 2004.
[9] Article 7 Report, Forms D and F, 22 April 2005.
[10] See *Landmine Monitor Report 2004*, p. 248.
[11] Article 7 Report, Form G, dated April 2006. Mines destroyed in previous years included: 8,739 in 2000; 7,357 in 2001; 13,509 in 2002; 9,207 in 2003 (all by CMAC from 2000-2003); and 15,446 in 2004 (10,033 by CMAC, 3,632 by HALO and 1,781 by Mines Advisory Group). For information on past inconsistencies in Article 7 reporting on discovered mines, see *Landmine Monitor Report 2004*, p. 248.

មួយរបស់កងយោធពលខេមរភូមិន្ទថាមានឆន្ទៈក្នុងការអនុវត្តកាតព្វកិច្ចនៃសន្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីន"(១២) ។[12]

នៅក្នុងខែ កុម្ភៈ ឆ្នាំ ២០០៦ លិខិតមួយច្បាប់ត្រូវបានគេផ្ញើក្នុងនាមអង្គការវេទិកាសកម្មភាពមីន ទៅកាន់អគ្គលេខាធិការនៃ CMAA ស្តីអំពីចំនួនគ្រាប់មីនប្រឆាំងមនុស្សដ៏សន្ធឹកសន្ធាប់ដែលគេទើបរកឃើញថ្មីៗ ។ លិខិតនោះបានបញ្ជាក់ថា" ចាប់តាំងពីរបាយការណ៍ត្រួតពិនិត្យគ្រាប់មីនឆ្នាំ ២០០៥មក យើងបានដឹងថា កងយោធពលខេមរភូមិន្ទនៅតែបន្តបោះបង់ចោលនូវគ្រាប់មីនប្រឆាំងមនុស្សដ៏ច្រើនសន្ធឹកសន្ធាប់ ។ យើងក៏បានដឹងដែរថាកងយោធពលខេមរភូមិន្ទរបស់ប្រទេសកម្ពុជាគ្មានកន្លែងស្តុកគ្រាប់មីនទៀតទេ។ ជាការពិតណាស់ បញ្ហានេះគួរតែត្រូវបានគេធ្វើការបែងចែកអោយដាច់ស្រឡះពីអ្វីដែលជាស្តុកកាកសំណល់អេតចាយ...... យើងយល់ឃើញថា មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យស៊ើបអង្កេត និងរាយការណ៍អំពីបញ្ហានេះ ។ តើសព្វថ្ងៃលោកមានព័ត៌មានជាឯកសារស្តីពីលទ្ធផលនៃការស៊ើបអង្កេតបញ្ហាទាំងនេះឬទេ? ហើយតើមាននិតិវិធីណាមួយដែល CMAA បានបង្កើតឡើងដើម្បីត្រួតពិនិត្យនិងតំកល់ទុកជាឯកសារនូវបញ្ហាដ៏មានសារសំខាន់នេះឬទេ? " ។[13]

អគ្គលេខាធិការនៃ CMAAបានមានប្រសាសន៍ថា គាត់នឹងទៅជួបជាមួយឯកឧត្តម ឧត្តមសេនីយ៍ឯក ប៉ុល សារឿន ដើម្បីពិភាក្សាអំពីការរកឃើញនូវស្តុកគ្រាប់មីន និងសំណល់អេតចាយដែលគេពុំបានដឹងពីមុនមក។ លោកបានធានាអះអាងថា គ្រាប់មីនទាំងនោះនឹងត្រូវគេកំទេចចោលអោយបានទាន់ពេលវេលា ។[14]

យោងតាមតួលេខខុសៗគ្នាដែលគេបានផ្តល់ក្នុងមាត្រាទី៧ គិតក្នុងប៉ុន្មានឆ្នាំនេះ វាហាក់ដូចជាមានការលំបាកណាស់សំរាប់ប្រទេសដែលរងគ្រោះដោយសារគ្រាប់មីនដូចប្រទេសកម្ពុជា ក្នុងការឆ្លើយតបទៅនឹងបញ្ហាចោទអំពីស្តុកនិងការបំផ្លាញចោលគ្រាប់មីនអោយបានត្រឹមត្រូវ។ ប្រទេសជាច្រើនក្នុងចំណោមប្រទេសទាំងនេះបានទទួលរងគ្រោះដោយសារសង្គ្រាមជាច្រើនឆ្នាំ ដោយសារការដាក់មីនពាសវាលពាសកាល ការបោសសំអាតនិងការបំផ្លាញមីន និងការបោសសំអាតមីនតាមភូមិដែលគេមិនបានរាយការណ៍។ ក៏មានការច្របូកច្របល់អំពីមីនដែលត្រូវគេផ្ទេរពីចំការមីន ហើយទុកដាក់ក្នុងស្តុកបណ្តោះអាសន្ន អំពីកាកសំណល់អេតចាយនៅតាមភូមិ និងអំពីគ្រាប់មីនដែលគេទុកនៅក្នុងឃ្លាំង ។

### *គ្រាប់មីនដែលគេរក្សាទុកសំរាប់ការស្រាវជ្រាវនិងបណ្តុះបណ្តាល*

ក្នុងគ្រប់របាយការណ៍មាត្រាទី៧របស់ខ្លួន ប្រទេសកម្ពុជាបានបញ្ជាក់ថា ខ្លួនពុំមានគ្រាប់មីនប្រឆាំងមនុស្សដែលគេរក្សាទុកសំរាប់ការបណ្តុះបណ្តាល ឬសំរាប់គោលបំណងអភិវឌ្ឍន៍ ដូចដែលបានអនុញ្ញាតក្នុងមាត្រាទី ៣ ឡើយ។ ក៏ប៉ុន្តែប្រទេសសនេះក៏បានរាយការណ៍អំពីការផ្ទេរគ្រាប់មីនសំរាប់ប្រើក្នុង ការបណ្តុះបណ្តាលនិងសំរាប់គោលបំណងអភិវឌ្ឍន៍ទៅអោយមជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ CMAC ជារៀងរាល់ឆ្នាំ ។ វាស្តែងអោយឃើញថា ជារៀងរាល់ឆ្នាំ គ្រាប់មីនមួយចំនួនត្រូវបានគេបញ្ជូនទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាល គឺជាមីនដែលត្រូវបានគេយកចេញពីដីដោយអ្នកដោះមីនឬក៏ជាមីនដែលបានមកពីសំណល់អេតចាយដែលគេទើបនឹងរកឃើញថ្មីហើយប្រហែលជាបន្ទាប់មកត្រូវបានគេយកមកប្រើប្រាស់

[12] See *Landmine Monitor Report 2005*, p. 211.
[13] Email from Marc Bonnet, Regional Representative, NPA South East Asia, 15 February 2006.
[14] Interview with Sam Sotha, Secretary-General, CMAA, Phnom Penh, 13 March 2006.

ភ្លាមៗ។ ក្នុងខែមិនា ឆ្នាំ ២០០៦ CMAA បានប្រាប់អោយដឹងថា ខ្លួនពុំបានទទួលសំណើណាមួយ ដើម្បីរក្សាទុកគ្រាប់មីន សំរាប់ការបណ្តុះបណ្តាលឡើយ ។[15]

ប្រទេសកម្ពុជាពុំបានបញ្ជាក់អោយច្បាស់លាស់ថា តើគេយកគ្រាប់មីនទាំងអស់ ឬគ្រាប់មីនមួយចំនួនដែលគេបាន ផ្ទេរនោះទៅប្រើប្រាស់ ជារៀងរាល់ឆ្នាំ ឬក៏រក្សាទុកពីមួយឆ្នាំទៅមួយឆ្នាំ សំរាប់ការបណ្តុះបណ្តាល ។ ជាងនេះទៅទៀត កម្ពុជាពុំទាន់បានរាយកាណ៏ជាពិស្តារអំពីគោលដៅគ្រោងទុក និងការប្រើប្រាស់មីនជាក់ស្តែង សំរាប់ការបណ្តុះបណ្តាល នៅឡើយ — ជាវិធានការណ៏ដែលរដ្ឋជាសមាជិកទាំងអស់បានព្រមព្រៀងនៅក្នុងផែនការសកម្មភាពនៅទីក្រុង Nairobi (Nairobi Action Plan) ដែលកើតចេញពីសន្និសីទត្រួតពិនិត្យឡើងវិញលើកទី១ (The First Review Conference) ។ ប្រទេសកម្ពុជាមិនបានប្រើប្រាស់បែបបទបំពេញបន្ថែម" ឃ " ថ្មី (New Expanded Form D) សំរាប់ រាយការណ៏អំពីគ្រាប់មីនដែលគេរក្សាទុក ដូចដែលបានព្រមព្រៀងក្នុងកិច្ចប្រជុំលើកទី ៦ របស់រដ្ឋជាសមាជិកកាលពីខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៥ ឡើយ ។

ប្រទេសកម្ពុជាបានរាយការណ៏អោយដឹងថានៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់អង្គការ CMAC ពុំបានទទួលគ្រាប់មីនប្រឆាំងមនុស្ស ដើម្បីបំរើដល់ការបណ្តុះបណ្តាលរបស់ខ្លួនឡើយ ។ កម្ពុជាបានកត់សំគាល់ឃើញថា HALO ទទួលបានមីនចំនួន ៧៧ គ្រាប់ពីអ្នកស្រុកនៅមូលដ្ឋាន សំរាប់ការបណ្តុះបណ្តាល ។[16] ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៤ គ្រាប់មីនប្រឆាំងមនុស្សសរុបចំនួន ៣,០៧៩គ្រាប់ ត្រូវបានគេរាយការណ៏ថា បានផ្ទេរទៅអោយមជ្ឈមណ្ឌល បណ្តុះបណ្តាលរបស់ CMAC ដើម្បីប្រើប្រាស់ក្នុងការបណ្តុះបណ្តាលជំនាញដោះមីន រួមទាំងមីនចំនួន ៥៩៦ គ្រាប់ ដែលបានមកពីកងឯកភាពដោះមីននានារបស់ CMAC នៅក្នុងឆ្នាំ ២០០៤ ។[17]

HALO បានប្រាប់អ្នកត្រួតពិនិត្យមីនក្នុងខែកុម្ភៈឆ្នាំ២០០៦ ថា ខ្លួនតែងតែត្រូវបាននគរបាល ឬយោធាហៅអោយ ទៅរៀបចំចាត់ចែងគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះផ្សេងៗ ដែលគេយកមកប្រគល់នៅតាមតំបន់ដាច់ស្រយាល ។ អង្គការ នេះបានអោយដឹងថា គេអាចប្រើប្រាស់គ្រាប់មីនមួយចំនួនសំរាប់ការបណ្តុះបណ្តាល និងធ្វើការពិសោធន៏តាមបច្ចេកទេស បំផ្លាញចោល អង្គការ HALO ជឿជាក់ថា ការបណ្តុះបណ្តាលដ៏ល្អបំផុតសំរាប់អ្នកដោះមីនគឺត្រូវធ្វើនៅក្នុងចំការមីនផ្ទាល់ ហើយគេអាចត្រូវការចំនួនគ្រាប់មីនក្នុងបរិមាណដ៏តិចតួចបំផុតសំរាប់ការបណ្តុះបណ្តាល ។[18]

## <u>**បញ្ហាគ្រាប់មីននិងសំណល់គ្រឿងផ្ទុះដែលបន្សល់ទុកដោយសារសង្គ្រាម**(ERW)</u>

សង្គ្រាមជិត ៣ ទសវត្សបានធ្វើអោយប្រទេសកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសទាំងឡាយដែល មានគ្រាប់មីន និងសំណល់គ្រឿងផ្ទុះ ដែលបន្សល់ទុកដោយសារសង្គ្រាមយ៉ាងច្រើនសន្ធឹកសន្ធាប់ទាំងគ្រាប់ផ្ទុះ និង

---

15 Ibid.
16 Article 7 Report, Form D, dated April 2006.
17 Article 7 Reports, Form D, 22 April 2005 and dated April 2006. In addition, 348 mines were transferred to CMAC from MCTU/UNTAC in 1993, 236 from CMAC PMU Siem Reap in 1998, 272 from CMAC EOD Preah Vihear in 1999, 546 from CMAC DU2 in 1999, 52 from CMAC HQ Phnom Penh in 2000, 423 from CMAC DU6 Siem Reap in 2001, 240 from the Ministry of Interior in 2002, and 366 from various CMAC demining units in 2003.
18 Interview with Richard Boulter, Programme Manager, HALO Trust, Siem Reap, 28 February 2006.

យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ (UXO)។ [19] ប៉ុន្តែការប៉ាន់ស្មានពីបរិមាណនៃគ្រាប់ទាំងនោះមានភាពខុសៗគ្នាជាខ្លាំង ។ ការវាស់ស្ទង់ផលប៉ះពាល់របស់គ្រាប់មីន (Landmine Impact Survey "LIS") ដែលបានបញ្ចប់ទៅនៅឆ្នាំ ២០០៣ បានប៉ាន់ស្មានផ្ទៃដីដែលអាចមានគ្រោះថ្នាក់ដោយសារគ្រាប់មីនថាមានប្រមាណ ៤,៤៤៦ គីឡូម៉ែត្រការេ ។ ការវាយតំលៃដោយឯករាជ្យអំពីសកម្មភាពមីននៅក្នុងឆ្នាំ ២០០៤ បានប៉ាន់ស្មានផ្ទៃដីថាមានប្រហែល ៤៦០ គីឡូម៉ែត្រការេ និងបានសន្និដ្ឋានថាតួលេខនេះអាចត្រូវបានគេកាត់បន្ថយទៀតដោយការវាស់ស្ទង់និងការធ្វើផែនទីចុងក្រោយបំផុត។[20] ការស៊ើបអង្កេតដែលធ្វើឡើងដោយអង្គការ HALO នៅក្នុងឆ្នាំ ២០០៥បានរកឃើញបរិមាណដីមួយចំនួនដែលបានកត់សំគាល់ដោយ LIS ថាអាចប្រើប្រាស់សំរាប់ការបង្កបង្កើនផលបាន។[21] សំណល់គ្រាប់មីនទាំងឡាយបានកើតមានឡើងបន្ទាប់ពីប្រទេសវៀតណាមបានចូលលុកលុយប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៧៨ ដែលបានទំលាក់របបខ្មែរក្រហម ប៉ុល ពត និងបណ្តេញកងទ័ពនៃរបបនេះទៅព្រំដែនកម្ពុជាថៃ។ ដើម្បីទប់ទល់នឹងការជ្រៀតចូលរបស់ក្រុមឧទ្ទាមមិនមែនកុម្មុយនីស្ត និង ពួកខ្មែរក្រហម រដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមបានបង្កើតខ្សែក្រវ៉ាត់ក៥ (K5) ជារនាំងដែលពោរពេញទៅដោយគ្រាប់មីនដ៏សន្ធឹកសន្ធាប់ មានទទឹងពី ១០ ទៅ ១៥ ម៉ែត្រ (ហើយក្រោយមកចេះតែកើនឡើងដោយការដាក់មីនរំខាន (nuisance mining)ដែលលាតសន្ធឹងប្រវែង ៧០០ គីឡូម៉ែត្រតាមបណ្តោយព្រំដែនថៃ ។ បន្ទាប់ពីកងទ័ពវៀតណាមដកចេញពីកម្ពុជានៅក្នុងឆ្នាំ១៩៨៨ ក្រុមឧទ្ទាមបានជ្រៀតចូលជ្រៅមកក្នុងប្រទេសកម្ពុជាភាគខាងជើង និងខាងត្បូងទន្លេសាប ហើយភាគីប្រយុទ្ធទាំងសងខាងបានដាក់ពង្រាយចំការមីនដោយគ្មានបានកំនត់ច្បាស់លាស់និងគ្មានផែនទីក្នុងគោលបំណងការពារខ្លួនរយៈពេលខ្លី ។[22]



ប្រទេសកម្ពុជា ក៏បានរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយសារសំណល់ ERW ភាគច្រើនចាប់ពីទសវត្សទី៦០ (1960s) ។ ក្នុងអំឡុងសង្គ្រាមវៀតណាម សហរដ្ឋអាមេរិក បានទំលាក់គ្រាប់បែករាប់លានតោនសំរាប់គោលដៅទូទៅ និង គ្រាប់បែកសំណុំ (Cluster bomlets) រាប់លានគ្រាប់មកលើទឹកដីកម្ពុជាភាគច្រើននៅប៉ែកខាងត្បូង និងប៉ែកខាងជើងប្រទេស ដែលពុំសូវមានប្រជាជនរស់នៅ តាមបណ្តោយព្រំដែនជាមួយប្រទេសវៀតណាម។[23] ប៉ុន្តែការសិក្សាអំពី ERW ក្នុងប្រទេសកម្ពុជា នៅឆ្នាំ២០០៦ បានអោយដឹងថាជាង ៨០% នៃគ្រាប់មិនទាន់ផ្ទុះដែលត្រូវបានគេបោសសំអាតគឺជាគ្រាប់កាំភ្លើងធំ ថ្មើរជើង

[19] Under Protocol V to the Convention on Conventional Weapons, explosive remnants of war are defined as unexploded ordnance and abandoned explosive ordnance. Mines are explicitly excluded from the definition.
[20] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004.
[21] HALO, "The need to document reclaimed land on the National Mined Area Database," Phnom Penh, 2005.
[22] HALO powerpoint presentation, viewed in Phnom Penh, 21 March 2006.
[23] South East Asia Air Sortie Database, cited in Dave McCracken, "National Explosive Remnants of War Study, Cambodia," (draft), NPA in collaboration with CMAA, March 2006, p. 15.

និងគ្រាប់រំសេវផ្សេងៗ ហើយតិចជាង២០%គឺជាគ្រាប់ដែលទំលាក់ពីលើអាកាស ។[24]

១៤ឆ្នាំ ក្រោយពីការដោះមីនតាមរយៈជំនួយមនុស្សធម៌បានចាប់ផ្តើមក្នុងប្រទេសកម្ពុជា ហើយទោះបីជាមានការអប់រំស្តីអំពីគ្រោះថ្នាក់ដោយសារមីន និងវិធានការអប់រំស្តីពីគ្រោះថ្នាក់ផ្សេងៗទៀតយ៉ាងណាក៏ដោយ ក៏គ្រោះថ្នាក់នៅតែមានកំរិតខ្ពស់ ដោយបន្តក្នុងកំរិតជាមធ្យមជាង៨០០នាក់ក្នុងមួយឆ្នាំ ពីឆ្នាំ២០០០ដល់ឆ្នាំ២០០៥។[25] ប៉ុន្តែរបាយការណ៍ស្តីពីគ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះបានប្រែប្រួលគួរអោយកត់សំគាល់នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ នៅប្រទេសកម្ពុជាភាគកណ្តាលមានគ្រោះថ្នាក់ដ៏តិចតួចក្នុងរយៈពេល២-៣ឆ្នាំមុន។ ឥឡូវនេះគ្រោះថ្នាក់ដោយសារគ្រាប់មីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ស្ទើរតែទាំងអស់កើតមាននៅតាមខ្សែបណ្តោយក្រវ៉ាត់មីនក៥ និងក្នុងខេត្តតាមបណ្តោយព្រំដែនដូចជា ខេត្តបាត់ដំបង និងបន្ទាយមានជ័យ ដែលឆ្លុះអោយឃើញនូវតំរូវការដីធ្លី ហើយភាគច្រើន គឺជាលទ្ធផលនៃការស្វែងរកឈើ និង អនុផលព្រៃឈើ។[26] ការប្រែប្រួលមួយទៀតគឺថា បើទោះជាធនធានសំរាប់ដោះមីនផ្តោតជាសំខាន់ទៅលើការបោសសំអាតគ្រាប់មីន គ្រោះថ្នាក់ភាគច្រើនត្រូវបានគេរាយការណ៍ក្នុងរយៈ២ឆ្នាំមុន ៦១% ថាបានកើតឡើងដោយសារគ្រាប់មិនទាន់ផ្ទុះ។[27] ក្រៅពីខេត្តបាត់តំបង បន្ទាយមានជ័យ និងក្រុងប៉ៃលិន ៨៣%នៃគ្រោះថ្នាក់គិតចាប់តាំងពី ឆ្នាំ២០០១មក បានកើតឡើងដោយសារឧបទ្ទវហេតុគ្រាប់មិនទាន់ផ្ទុះ។[28]

បញ្ហានេះត្រូវបានគូសបញ្ជាក់ដោយ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅក្នុងខែកុម្ភៈឆ្នាំ២០០៦ ដែលបានថ្លែងទៅកាន់ជនរួមជាតិតាមកញ្ចក់ទូរទស្សន៍នៅក្នុងឱកាសទិវាយល់ដឹងអំពីមីន។ សម្តេចបានមានប្រសាសន៍ថា "......បើទោះបីជាយើងខិតខំប្រឹងប្រែងខ្លាំងក្លាជាងពេលណាណាក៏ដោយ ក៏ចំនួនគ្រោះថ្នាក់ដោយសារគ្រាប់មីននៅតែមានជាដដែល...លើសពីនេះគ្រោះថ្នាក់ ដែលបណ្តាលមកពីគ្រាប់មិនទាន់ផ្ទុះ បានកើនឡើងសារជាថ្មីប្រមាណពាក់កណ្តាល បើប្រៀបធៀបទៅនឹងគ្រោះថ្នាក់ដោយសារគ្រាប់មីន។ ចំនុចនេះបានបង្ហាញអោយឃើញយ៉ាងច្បាស់ថាប្រទេសកម្ពុជានៅតែមានបញ្ហាគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះយ៉ាងធ្ងន់ធ្ងរនៅឡើយ។..............យើងត្រូវតែចាត់វិធានការអោយបានហ្មត់ចត់ ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីនអោយបានច្រើនបំផុតតាមដែលអាចធ្វើទៅបានជារៀងរាល់ឆ្នាំ " ។[29]

នៅថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៦ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានមានប្រសាសន៍ថា " បើទុកណាជាគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះមិនបានសំលាប់ឬធ្វើអោយប្រជាពលរដ្ឋរងគ្រោះក៏ដោយ ក៏គ្រាប់ទាំងនោះគឺជាឧបសគ្គដ៏ចំបងចំពោះការអភិវឌ្ឍន៍ប្រទេស ពីព្រោះគេមិនអាចប្រើប្រាស់ដីដែលមានគ្រាប់ទាំងនោះសំរាប់ធ្វើកសិកម្ម ឬតាំងទីលំនៅជាថ្មី, ប្រជាជនមិនអាចធ្វើដំណើរ ឬអាចប្រើប្រាស់គ្រឹះហេដ្ឋារចនាសម្ព័ន្ធសង្គមបានឡើយ ។

ការចៀសវាងអោយបាននូវគ្រោះថ្នាក់មីន គឺជាតំរូវការជាបឋមក្នុងការជួយលើកកំពស់ជីវភាពជនរងគ្រោះឱ្យ

---

[24] Interview with Dave McCracken, Consultant, NPA, Phnom Penh, 21 March 2006.
[25] Cambodian Mine Victim Information Service (CMVIS), "Reported mine/UXO casualties for the period of: January 2002 to December 2005," December 2005, p. 5.
[26] CMVIS maps provided to HALO by Chhiv Lim, Project Manager, CMVIS, 27 February 2006.
[27] CMVIS, "Reported mine/UXO casualties for the period of: January 2002 to December 2005," December 2005,p. 8.
[28] Dave McCracken, "National Explosive Remnants of War Study, Cambodia," (draft), NPA/CMAA, P. Penh, March 2006, p. 51.
[29] Samdech Hun Sen, Prime Minister, television address to the national Mine Awareness Day, 24 February 2006.

ចាកផុតពីភាពក្រីក្រ ”។[30] ភាពជឿនលឿនទៅមុខ ដែលធ្វើឡើងដោយសហគមន៍មូលដ្ឋានក្នុងការប្រគល់មកវិញនូវផ្ទៃដីដែលពីមុនគេសង្ស័យថាមានគ្រាប់មីនដើម្បីបង្កបង្កើនផល និងឧបទ្ទវហេតុដោយសារមីនដែលកើតមាននៅតាមភូមិសាស្ត្រតូចៗបានជំរុញអោយមានការពិភាក្សាគ្នាអំពីវិធីដែលអាចជួយបង្កើនល្បឿននៃការអភិវឌ្ឍន៍របស់កម្ពុជា អោយរួចចាកផុតទាំងស្រុងពីការរងគ្រោះដោយសារគ្រាប់មីន។ អង្គការ HALO ជឿជាក់ថា ផ្ទៃដីជាអាទិភាពដែលបានកត់សំគាល់សហគមន៍មូលដ្ឋាន អាចនឹងត្រូវបានបោសសំអាតក្នុងរយៈពេល៥ឆ្នាំទៀត ក្នុងករណីដែលធនធានសំរាប់បោសសំអាតមីនត្រូវបានគេផ្តោតទៅលើតំបន់ទាំងនោះ។[31] ស្រដៀងគ្នានេះដែរក្នុងសេចក្តីថ្លែងការណ៏មួយទៅកាន់កិច្ចប្រជុំជាមួយអ្នកផ្តល់ជំនួយ នាខែមករា ឆ្នាំ២០០៦ អង្គការមនុស្សធម៌ក្រៅរដ្ឋាភិបាលបានជំរុញកម្មវិធីសកម្មភាពមីនរបស់ប្រទេសកម្ពុជា អោយផ្តោតទៅលើតំបន់នៅតាមព្រំដែន ដែលជាកន្លែងមានគ្រោះថ្នាក់កើតឡើងភាគច្រើន ហើយកាត់បន្ថយទីតាំងសង្ស័យដោយពិចារណាទៅលើដី ដែលអ្នកភូមិបានកាន់កាប់ឡើងវិញ ។[32]

## <u>កម្មវិធីសកម្មភាពកំចាត់មីន</u>

*អាជ្ញាធរជាតិសកម្មភាពមីនៈ* អាជ្ញាធរមីនកម្ពុជា (CMAA) ត្រូវបានបង្កើតឡើងនៅក្នុងខែកញ្ញា ឆ្នាំ ២០០០ ដើម្បីដឹកនាំនិងសំរបសំរួលសកម្មភាពមីន, ដែលពីមុនជាការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា, បន្តធ្វើជាអ្នកប្រតិបត្តិការដោះមីនធំជាងគេនៅក្នុងប្រទេសកម្ពុជា ។ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** គឺជាប្រធាន CMAA ហើយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** គឺជាអនុប្រធាន CMAA ដែលមានការគ្រប់គ្រងប្រចាំថ្ងៃដោយអគ្គលេខាធិការ **សម សុត្ថា** (Sam Sotha) ។ [33]

CMAA ត្រូវបានផ្លាស់ប្តូររចនាសម្ព័ន្ធឡើងវិញនៅក្នុងឆ្នាំ២០០៥ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានត្រូវតែងតាំងដោយព្រះរាជក្រិត្យមួយដែលបានចេញក្នុងខែមិថុនាឆ្នាំ២០០៥ ជាអនុប្រធានទីពីរបស់ CMAA ដើម្បីដឹកនាំពិភាក្សាជាមួយម្ចាស់ជំនួយ។[34] ការតែងតាំងលោក **ប្រាក់ សុខុន** អោយកាន់មុខតំណែងនេះ និងមុខតំណែងជាប្រធានក្រុមការងារបច្ចេកទេសស្តីអំពីសកម្មភាពមីន ត្រូវបានការទទួលស្វាគមន៏ពីក្រុមម្ចាស់ជំនួយថាជាការពង្រឹងការគ្រប់គ្រងថ្នាក់ជាតិលើផ្នែកនេះ និង ផ្តល់ឳកាសអោយពួកគេបានធ្វើការទាក់ទងក្នុងកំរិតដ៏ខ្ពស់មួយក្នុងក្របខ័ណ្ឌរដ្ឋាភិបាល។[35] អាជ្ញាធរមីន ”បានបង្ហាញឱ្យឃើញនូវការចាប់អារម្មណ៏កាន់តែខ្លាំងឡើងក្នុងកិច្ចទំនាក់ទំនងរបស់ខ្លួនជាមួយអ្នកប្រតិបត្តិការដោះមីន និង ក្រុមអ្នកផ្តល់ជំនួយតាមរយៈកិច្ចប្រជុំសំរបសំរួលដោយទៀងទាត់ជាមួយក្រុមការងារបច្ចេកទេស និង

---

[30] Deputy Prime Minister Sok An, address during the signing ceremony between UN Development Programme (UNDP) and Australia, 25 January 2006.
[31] Interview with Richard Boulter, HALO, Siem Reap, 27 February 2006.
[32] NGO statement on mine action to Consultative Group meeting with donors, Phnom Penh 19 January 2006.
[33] A royal decree dated 4 September 2000 and a subdecree dated 8 August 2001 define the roles and responsibilities of CMAA; the 2001 subdecree also confirmed CMAC's status as service provider. For details of legislation regarding CMAA and CMAC, see Geneva International Centre for Humanitarian Demining, "A Study of the Development of Mine Action Legislation," Geneva, 2004, pp. 64-66.
[34] Royal decree, NS/RKT/0605/296, 29 June 2005; speech by Deputy Prime Minister Sok An, Third Conference on Mine Action Achievements, Phnom Penh, 24 May 2006.
[35] Donor and stakeholder interviews, Phnom Penh, 20-23 March 2006.

វេទិការសកម្មភាពមីន ” ។[36]

កិច្ចប្រជុំមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់អាជ្ញាធរមីន នាថ្ងៃទី ៥ មករា ២០០៦ បានកំណត់នូវការទទួលខុសត្រូវរបស់អាជ្ញាធរមីនដូចតទៅ:

- បង្កើតគោលនយោបាយ, ចក្ខុវិស័យយុទ្ធសាស្ត្ររយៈពេលវែងនិងមធ្យម និង ផែនការ ៥ឆ្នាំ សំរាប់ការដោះមីន ការបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងជំនួយសំរាប់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់
- សំរបសំរួលគ្រប់សកម្មភាពដោះមីន, បោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងជំនួយសំរាប់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់
- ត្រួតពិនិត្យ ការដោះមីន, ការបោសសំអាតយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងជំនួយសំរាប់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ ដើម្បីធ្វើអោយប្រាកដថា អ្នកប្រតិបត្តិការដោះមីនអនុវត្តតាមផែនការនិងយុទ្ធសាស្ត្រដែលបានកំនត់
- ចាត់ចែងបែងចែកជំនួយហិរញ្ញវត្ថុនិងជំនួយបច្ចេកទេសក្នុងប្រទេសកម្ពុជានិងពីបរទេស
- ចេញបទបញ្ជាអោយបំផ្លាញចោលនូវឃ្លាំងស្តុកគ្រាប់មីនប្រឆាំងមនុស្ស និងគ្រឿងផ្ទុះផ្សេងៗទៀត
- ចាត់ចែងគ្រប់គ្រងគ្រប់សកម្មភាពដែលទាក់ទិននឹងសកម្មភាពមីន
- ផ្តល់ការទទួលស្គាល់រាល់អង្គការជាតិនិងអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើសកម្មភាពដោះមីននៅកម្ពុជា
- គ្រប់គ្រងទិន្នន័យរាល់គ្រប់សកម្មភាពពាក់ព័ន្ធនឹងសកម្មភាពមីននិងគ្រាប់មិនទាន់ផ្ទុះនិងជំនួយសំរាប់ជនរងគ្រោះដែលនៅរស់
- បង្កើតគោលនយោបាយស្តីអំពីការប្រើប្រាស់ដីធ្លីក្រោយពេលបោសសំអាតមីនរួច
- គ្រប់គ្រងការអនុវត្តច្បាប់ជាតិស្តីអំពីសន្ធិសញ្ញាប្រឆាំងនឹងការប្រើប្រាស់មីន, និង
- ត្រួតពិនិត្យនិងផ្តល់ប្រឹក្សាស្តីអំពីការប្រើប្រាស់ធនធានដោយអង្គការជាតិនិងអង្គការក្រៅរដ្ឋាភិបាលនានា [37]

អជ្ញាធរមីន បានបញ្ចប់ពង្រាងជំពូកទី ១៧ នៃបទដ្ឋានសកម្មភាពមីនថ្នាក់ជាតិនៅក្នុងឆ្នាំ ២០០៤។ អង្គការនេះបានដាក់ ៥ជំពូកដំបូង ដើម្បីស្នើសុំការអនុម័តពីសម្តេចនាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ ២០០៥ ហើយជំពូកទាំងនោះបានចូលជាធរមាននៅខែសីហា។[38] ជំពូកទាំងនោះទាក់ទីននឹងការទទួលស្គាល់និងការផ្តល់អាជ្ញាប័ណ្ណ ការត្រួតពិនិត្យអង្គការបោសសំអាតមីន ការស្តុកទុក ការដឹកជញ្ជូននិងការចាត់ចែងគ្រឿងផ្ទុះផ្សេងៗ ព្រមទាំងរបាយការណ៍គ្រោះថ្នាក់នៃការដោះមីន។[39]

អង្គការបោសសំអាតមីនត្រូវបានគេផ្តល់ពេលវេលា ៦ ខែ ដើម្បីដាក់ពាក្យស្នើសុំការទទួលស្គាល់ ។ ត្រឹមខែ មីនា ឆ្នាំ២០០៦ អង្គការបោសសំអាតមីនមនុស្សធម៌សំខាន់ៗចំនួនបីគឺ CMAC, HALO និង MAG បានដាក់ពាក្យស្នើសុំការទទួលស្គាល់។[40] អង្គការ HALO និង MAG ត្រូវបានគេប្រាប់អោយដឹងថាអាចទទួលបានការទទួលស្គាល់នៅថ្ងៃទី ២៩ ខែ

[36] NPA, "Contribution to the NGO Statement to the Consultative Group Meeting on Cambodia," March 2006.
[37] CMAA, "Secretariat Restructuring and Responsibilities," 13 March 2006, pp. 1-2.
[38] Royal Government of Cambodia, Decision No. 29 S.S.R. on The Implementation of Cambodian Mine Action Standards (CMAS), First Five Chapters, 10 August 2005, Article 3.
[39] Interview with Sam Sotha, CMAA, Phnom Penh, 20 March 2006.
[40] Ibid.

ឧសភា ឆ្នាំ ២០០៦ ។[41]

អាជ្ញាធរមីន បានចេញជាលើកដំបូងនូវលិខិតទទួលស្គាល់អ្នកប្រតិបត្តិការដោះមីនទាំងអស់ដោយពេញលេញ (ខុសពីបណ្តោះអាសន្ន) ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីរដ្ឋាភិបាល ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានព្រមាននៅក្នុងខែឧសភា ឆ្នាំ ២០០៦ ថា " ចាប់ពីពេលនេះតទៅប្រតិបត្តិករបោសសំអាតមីនទាំងអស់ ត្រូវដាក់ពាក្យសុំទៅអាជ្ញាធរមីន និងត្រូវឆ្លងកាត់នីតិវិធីទាំងឡាយដែលបានកំណត់ ដើម្បីទទួលបានការទទួលស្គាល់ដោយគ្មានការលើកលែង មិនថាក្នុងលក្ខណៈមនុស្សធម៌ ឬពាណិជ្ជកម្ម, ជាតិ ឬអន្តរជាតិ ឡើយ។ អង្គការទាំងឡាយណាដែលមិនបំពេញតាមលក្ខខណ្ឌបទដ្ឋានជាតិនិងត្រូវបានព្យួរការងារជាបណ្តោះអាសន្ន ហើយប្រតិបត្តិការរបស់ខ្លួននឹងត្រូវបានគេបញ្ឈប់ ប្រសិនបើក្រោយមកអង្គការទាំងនោះមិនបានបំពេញតាមតំរូវការបទដ្ឋាន។[42]

***មជ្ឈមណ្ឌលសកម្មភាពមីន:*** មជ្ឈមណ្ឌលសកម្មភាពមីនកម្ពុជា (CMAC) គឺជាអ្នកប្រតិបត្តិការដោះមីនជាតិឈានមុខគេ ប៉ុន្តែមិនប្រតិបត្តិនូវអ្វីដែលជាការទទួលខុសត្រូវទូលំទូលាយអោយសមនឹងពាក្យជា " មជ្ឈមណ្ឌល " ឡើយ។ CMAC ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩២ ហើយត្រូវបានប្រគល់តួនាទីជាអ្នកសំរបសំរួលក្នុងពាក់កណ្តាលទសវត្សទី ៩០ (1990s) ។ អង្គការនេះបានបោះបង់តួនាទីនេះក្នុងការរៀបចំការងារសកម្មភាពមីនឡើងវិញ ក្នុងឆ្នាំ ២០០០ ដែលបានផ្តាច់ចេញនូវតួនាទីជាទីភ្នាក់ងារគ្រប់គ្រងនិងអនុវត្ត ហើយបាននាំអោយមានការបង្កើតអាជ្ញាធរមីន (CMAA) ។[43]

*<u>ផែនការយុទ្ធសាស្ត្រ និង ការអភិវឌ្ឍ</u>*

CMAA ទទួលខុសត្រូវក្នុងការធ្វើផែនការយុទ្ធសាស្ត្រ។ នៅឆ្នាំ ២០០៣ ស្ថាប័ននេះបានធ្វើពង្រាងយុទ្ធសាស្ត្រជាតិមួយ និង ផែនការសកម្មភពមីនរយៈពេល៥ឆ្នាំ (២០០៣-២០០៧) មួយ, គោលដៅមួយចំនួនក្នុងចំណោមគោលដៅទាំងឡាយមានជាអាទិ៍ ការពង្រឹងការសំរបសំរួលសកម្មភាពមីនថ្នាក់ជាតិ និងការបង្កើតសកម្មភាពមីនដែលកាន់តែឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។[44]

ប្រទេសកម្ពុជា បានដាក់បញ្ចូលសកម្មភាពមីនទៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សទី៩របស់ខ្លួន។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានមានប្រសាសន៍ថា "កិច្ចការនេះត្រូវបានគេធ្វើ ដោយសារយើងបានកត់សំគាល់នូវឧបសគ្គចំបងចំពោះការអភិវឌ្ឍន៍និងការកាត់បន្ថយភាពក្រីក្រ ដោយសារគ្រាប់មីន និង ដើម្បីធ្វើអោយប្រាកដថាបញ្ហា នេះនៅតែជាបញ្ហាជាអាទិភាពសំរាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា " ។[45]

នៅក្នុងខេត្តទាំងប្រាំ ដែលរងគ្រោះខ្លាំងជាងគេដោយសារគ្រាប់មីន ( បាត់ដំបង, បន្ទាយមានជ័យ, ក្រុងប៉ៃលិន, ឧត្តមានជ័យ,និងព្រះវិហារ) ការធ្វើផែនការប្រចាំឆ្នាំ និងការដាក់លំដាប់អាទិភាពនៃសកម្មភាពមីនត្រូវបានធ្វើឡើងដោយក្រុមធ្វើផែនការសកម្មភាពមីន (MAPUs) ដែលធ្វើប្រតិបត្តិការអនុលោមទៅតាមសេចក្តីណែនាំដែលបានចែងក្នុង

[41] Email from Richard Boulter, HALO, Cambodia, 31 May 2006; email from Tim Carstairs, Director of Policy, MAG, 12 July 2006.
[42] Opening statement of Deputy Prime Minister Sok An, Third Conference on Mine Action Achievements, P. Penh, 24 May 2006.
[43] See *Landmine Monitor Report 2001*, p. 443.
[44] See *Landmine Monitor Report 2004*, p. 251.
[45] Deputy Prime Minister Sok An, address during the signing ceremony between UNDP and Australia, 25 January 2006.

អនុក្រឹត្យមួយចេញផ្សាយក្នុងខែវិច្ឆិកា ឆ្នាំ២០០៤។ CMAA គ្មានផែនការបង្កើត MAPU បន្ថែម ក្នុងខេត្តផ្សេងៗ ដែលមានចំនួនគ្រោះថ្នាក់ថយចុះយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ និងមានគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ចាត់ចែងដោយអ្នកប្រតិបត្តិការនានាដែលពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋានឡើយ។[46]

ដោយផ្អែកលើក្រុមធ្វើផែនការប្រើប្រាស់ដីធ្លី ដែលគេបង្កើតឡើងក្នុងរវាងឆ្នាំ ១៩៩៩- ២០០១ ក្រុមធ្វើផែនការសកម្មភាពមីន (MAPU) បានផ្តល់អ្នកសំរបសំរួលម្នាក់សំរាប់សំណើសុំបោសសំអាតមីនពីអាជ្ញាធរភូមិ ឃុំ ស្រុក និង ធ្វើពង្រាងផែនការការងារប្រចាំឆ្នាំដោយមានការពិគ្រោះយោបល់ជាមួយអ្នកប្រតិបត្តិការបោសសំអាតមីន។ ផែនការការងារត្រូវបានធ្វើរួចជាស្ថាពរក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការសកម្មភាពមីនខេត្ត (PMACs) ដែលជាស្ថាប័នមិនអចិន្ត្រៃយ៍ជួបប្រជុំគ្នា ក្រោមអធិបតីភាពរបស់អភិបាលរងខេត្ត ទទួលបន្ទុកធានានូវការដាក់បញ្ចូលផែនការសកម្មភាពមីនទៅក្នុងអាទិភាពអភិវឌ្ឍន៍ថ្នាក់ខេត្តនិងថ្នាក់ជាតិ។[47]

ក្រុមធ្វើផែនការសកម្មភាពមីន ត្រូវបានបង្កើតឡើងដើម្បីពង្រឹងការចូលរួមរបស់កម្ពុជាក្នុងការកំណត់អាទិភាព និងភារកិច្ចបោសសំអាតមីន ដែលពីមុនគឺជាដំណើរការដែលដឹកនាំដោយអ្នកប្រតិបត្តិការដោះមីន។[48] នៅក្នុងឆ្នាំ ២០០៥ MAPU បានទទួលការគាំទ្រផ្នែកបច្ចេកទេសពីអង្គការ Australian Volunteers International (AVI) ដើម្បីអភិវឌ្ឍន៍សមត្ថភាពផ្នែកគ្រប់គ្រង, សំរបសំរួល, វិភាគ និង ធ្វើផែនការ និងអភិវឌ្ឍន៍ខាងបច្ចេកទេសវិភាគនិងប្រមូលទិន្នន័យតាមរយៈគំរោងធ្វើផែនការវាយតំលៃការងារ ដែលធ្វើឡើងដោយអង្គការ Geospatial International។[49] វិធានការផ្សេងៗទៀត ដែលបានដាក់ស្នើដើម្បីពង្រឹងស្ថានភាពការងាររបស់ MAPU និង ឆ្លើយតបទៅនឹងអាទិភាពនានានៅថ្នាក់ខេត្ត រួមមានការបង្កើតមូលនិធិរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP Trust Fund) ដើម្បីផ្តល់ហិរញ្ញវត្ថុសំរាប់កិច្ចការដោះមីន ដែលបានដាក់ចេញដោយ MAPU ផ្អែកលើមូលដ្ឋាននៃការដេញថ្លៃ ដោយអង្គការប្រតិបត្តិការដោះមីន។[50] ក្រោយមកការដេញថ្លៃត្រូវបានបញ្ឈប់ ជាបណ្តោះអាសន្ន ដោយសារតែលក្ខណ្ឌតំរូវមួយចំនួនមិនត្រូវបានគេបំពេញដើម្បីអោយការដេញថ្លៃប្រព្រឹត្តទៅដោយជោគជ័យ។[51]

បន្ទាប់ពីបានធ្វើប្រតិបត្តិការរបស់ខ្លួនពេញមួយឆ្នាំដំបូង ដោយមានការពិគ្រោះយោបល់ជាមួយបុគ្គលិករបស់ MAPU អង្គការ AVI បានធ្វើការពិនិត្យមើលស្ថានភាពការងាររបស់ MAPU ឡើងវិញ នៅដើមឆ្នាំ ២០០៦ និងបានកត់សំគាល់នូវតំរូវការអោយមានការកែលំអក្នុងកិច្ចសំរបសំរួលរវាងអង្គការប្រតិបត្តិការដោះមីនជាមួយ MAPU។[52] ប៉ុន្តែ អង្គការប្រតិបត្តិការដោះមីនទាំងឡាយ បានបន្តដើរតួនាទីជាអ្នកសំរេចក្នុងការជ្រើសរើសភារកិច្ចដោយសំអាងថា ខ្លួនមាន

[46] Interview with Sam Sotha, CMAA, Phnom Penh, 20 March 2006.
[47] See *Landmine Monitor Report 2004*, p. 252.
[48] Interview with Julien Chevillard, Mine Action Specialist, UNDP, Phnom Penh, 21 March 2006.
[49] AVI, "Review and Recommendations from MAPU Planning Process 2005, Discussion Paper," February 2006, p. 1.
[50] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume I, Phnom Penh, 4 December 2004, pp. 4-5.
[51] Email from Julien Chevillard, UNDP, Phnom Penh, 1 June 2006.
[52] AVI, "Review and Recommendations from MAPU Planning Process 2005, Discussion Paper," February 2006, p. 1.

បទពិសោធន៏ និង ជំនាញបច្ចេកទេសខ្ពស់ជាង ហើយជាពិសេសផ្អែកលើមូលនិធិផ្ទាល់ពីអ្នកផ្តល់ជំនួយសំរាប់គំរោងដែលបានកំនត់ជាក់លាក់រួចហើយ ។[53]

ការធ្វើការពិនិត្យមើលឡើងវិញរបស់អង្គការ AVI បានកត់សំគាល់នូវតំរូវការអោយមានការពង្រឹងថែមទៀតនូវការប្រមូលទិន្នន័យរបស់ MAPU , ការវាយតំលៃលើសេចក្តីត្រូវការរបស់សហគមន៏ និងការវិភាគទិន្នន័យ ព្រមទាំងបានគូសបញ្ជាក់ពីសេចក្តីត្រូវការអោយមានការធានាថាអាទិភាពនៃការបោសសំអាតមីនត្រូវបានគេកំណត់ផ្អែកលើកំរិតធ្ងន់ធ្ងរនៃផលប៉ះពាល់របស់គ្រាប់មីន។ អង្គការនេះបានកត់សំគាល់ឃើញថា PMAC ខ្វះគោលនយោបាយសំរាប់ការប្រើប្រាស់ដីធ្លីដែលបានបោសសំអាតរួច និងបានផ្តល់សេចក្តីណែនាំបន្តិចបន្តួចទៅអោយ MAPU អំពីតំបន់សំខាន់ៗសំរាប់អភិវឌ្ឍន៏និងត្រូវបោសសំអាត។ អង្គការមិនមែនរដ្ឋាភិបាលបានផ្តល់ការគាំទ្រដោយផ្តោតទៅលើប្រសិទ្ធភាពរបស់គំរោង ដែលអង្គការទាំងនោះកំពុងអនុវត្តជាជាងផ្អែកលើទំនុកចិត្តក្នុងពេលដំណើរការគំរោង។ ដូច្នេះហើយបានជាភារកិច្ចការបោសសំអាតមីន ដែលនៅមានសុពលភាពមួយចំនួនត្រូវបានលុបចោល ពីព្រោះអង្គការមិនមែនរដ្ឋាភិបាលមិនធ្វើប្រតិបត្តិការនៅនឹងកន្លែង។ ការធ្វើការពិនិត្យមើលឡើងវិញក៏បានសង្កេតឃើញថា " MAPU ត្រូវការជំនួយគាំទ្របន្ថែមទៀត និងការកសាងសមត្ថភាព មុននឹងគេអាចចាត់ចែងដំណើរការដេញថ្លៃ " ។[54]

*ការវាយតំលៃសកម្មភាពមីន*

ការវាយតំលៃសកម្មភាពមីនក្នុងរយៈពេលបីឆ្នាំមុន បានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើសេចក្តីត្រូវការនិងឱកាសសំរាប់ប្រទេសកម្ពុជា និងអ្នកពាក់ព័ន្ធនឹងសកម្មភាពមីនទាំងអស់ក្នុងការអនុវត្តយុទ្ធសាស្រ្តដែលង្កើនល្បឿនយ៉ាងខ្លាំងក្លានូវការលុបបំបាត់ចោលតំបន់ ដែលសង្ស័យថាមានគ្រាប់មីននឹងបន្ថយទំហំនៃការគំរាមកំហែងដោយសារគ្រាប់មីននៅកម្ពុជា ។

ការសិក្សាមួយអំពីការគ្រប់គ្រងគ្រោះថ្នាក់ដែលគេបានធ្វើសំរាប់នាយកដ្ឋានអភិវឌ្ឍន៏អន្តរជាតិរបស់ចក្រភពអង់គ្លេស នៅក្នុងឆ្នាំ ២០០៣ បានអំពាវនាវអោយមានការចាត់ការចំពោះការប្រើប្រាស់ដីធ្លីផ្សេងៗអោយបានត្រឹមត្រូវនៅគ្រប់លំដាប់ថ្នាក់ និង អោយមានការទទួលស្គាល់នូវកំរិតគ្រោះថ្នាក់ដែលនៅសេសសល់ ។[55] ការវាយតំលៃសកម្មភាពមីនរួមនៅកម្ពុជាដែលគេបានធ្វើសំរាប់ម្ចាស់ជំនួយ នៅឆ្នាំ ២០០៤ បានលើកឡើងថា " ផ្ទៃដីដែលគេបាននិងកំពុងប្រើប្រាស់រួចហើយ ហើយដែលបង្ហាញថាគ្មានគ្រោះថ្នាក់ចំពោះសហគមន៏ " គួរតែត្រូវបានគេឈប់ពិចារណាក្នុងការបោសសំអាត ។[56]

ការពិភាក្សាគ្នាពីរឿងនេះមានសន្ទុះកាន់តែខ្លាំងឡើងនៅក្នុងឆ្នាំ ២០០៥ ដោយអង្គការ HALO គេបានចែកចាយសំនួរពិភាក្សា ដែលអំពាវនាវអោយមានការទទួលស្គាល់នូវការរួមចំណែកយ៉ាងខ្លាំងក្លានូវគំនិតផ្តួចផ្តើមពីមូលដ្ឋានចំពោះ

[53] Interviews with Richard Boulter, HALO, and Rupert Leighton, Country Manager, MAG, Phnom Penh, 20-23 March 2006; AVI, "Review and Recommendations from MAPU Planning Process 2005, Discussion Paper," February 2006, p. 29.
[54] AVI, "Review and Recommendations from MAPU Planning Process 2005, Discussion Paper," February 2006, pp. 5, 28-30.
[55] Julian Williams, "A Risk Strategy for Mine Action," Serco Assurance, UK, September 2003, www.itep.ws.
[56] Robert Griffin and Robert Keeley, "Joint Evaluation of Mine Action in Cambodia for the Donor Working Group on Mine Action," Volume 1, Phnom Penh, 4 December 2004.

ការប្រគល់ដីធ្លីដែលពីមុនគេសង្ស័យថាមានគ្រាប់មីន ដើម្បីបានបង្កបង្កើនផលឡើងវិញ។ តាមការវាយតំលៃរបស់អង្គការ HALO បានអោយដឹងថា គំនិតផ្តួចផ្តើមបែបនោះបានកើតឡើងដោយឥតគ្រោងទុកនៅពេលគេបោសសំអាតគ្រាប់មីននៅលើដីដែលប្រជាកសិករនិយាយថាមានដង់ស៊ីតេមីនប្រហែល ១ គ្រាប់ក្នុង១ ហិកតា ( ១០,000 ម៉ែត្រការេ) ធៀបជាមួយ និង ដង់ស៊ីតេមីនជាមធ្យម ៤៨ គ្រាប់ក្នុង១ ហិកតា ដែលអង្គការ HALO បានបោសសំអាតនៅក្នុងឆមាសទី ១ ឆ្នាំ ២០០៤។[57]

លើសពីនោះទៅទៀត អង្គការ HALO បាននិយាយថា មីនភាគច្រើនដែលកសិករបង្ហាញមិនអាចនឹងផ្ទុះឡើយ អាស្រ័យដោយអាយុកាលនិងភាពរិចរិល។ HALO បានផ្តល់យោបល់ថា" ដោយគេពុំទាន់បានធ្វើការវិភាគពីទំហំនៃបញ្ហានៅឡើយ ជាការពិបាកណាស់ក្នុងការចាត់អាទិភាពអោយបានត្រឹមត្រូវដើម្បីធ្វើការបោសសំអាតនូវផ្ទៃដីដែលគេបាន និងកំពុងប្រើប្រាស់រួចហើយ ដែលគេរកឃើញថាមានគ្រាប់មីនពីរបីគ្រាប់ ហើយដែលគ្មានគ្រោះថ្នាក់កើតឡើង និងមានសញ្ញាណបញ្ជាក់ថាប្រសិនបើមានមីននៅសល់គឺមានតែពីរបីគ្រាប់ប៉ុណ្ណោះ "។ អង្គការ HALOក៏បានអោយដឹងដែរថា ដីដែលគេបានកាន់កាប់ឡើងវិញពុំត្រូវបានគេកត់បញ្ចូលទៅក្នុងទិន្នន័យថ្នាក់ជាតិឡើយ ដូច្នេះហើយ" ការសំរេចចិត្តធ្វើផែនការសំខាន់ៗត្រូវបានធ្វើឡើងតាមទស្សនៈហួសសម័យនិងគ្មានព័ត៌មានច្បាស់លាស់ ។[58]

អង្គការ HALO និង អង្គការ MAG បានស្នើថា មតិផ្តួចផ្តើមពីមូលដ្ឋានចំពោះការកាន់កាប់ដីឡើងវិញគួរតែត្រូវបានគេដាក់បញ្ចូលនៅក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ហើយត្រូវបានគេចាត់ថ្នាក់ទៅតាមកំរិតទី ១, ២ ឬទី៣ ដោយផ្អែកលើចំនួនរដូវដែលគេដាំដុះនៅលើដីទាំងនោះដោយគ្មានគ្រោះថ្នាក់ ។ អង្គការទាំងនោះបានស្នើបន្តទៀតថាកំរិតទី ៣ គួរតែត្រូវបានគេដកស្រង់ចេញពីតារាងបញ្ជាក់កំរិតគ្រាប់មីន។[59]

វិធីសាស្ត្ររបស់អង្គការ HALO និង MAG ត្រូវបាន អង្គការ CMAC អះអាងតបវិញថាដី ដែលគេកំពុងដាំដុះមិនមែនមានសុវត្ថិភាពជាស្វ័យប្រវត្តិនោះទេ ហើយគួរតែត្រូវបានគេធ្វើការវាស់ស្ទង់តាមបច្ចេកទេស ឬយ៉ាងហោចណាស់ក៏ត្រូវផ្ទៀងផ្ទាត់បញ្ជាក់ដោយអ្នកប្រតិបត្តិការដោះមីន។[60] វិធីសាស្ត្ររបស់អង្គការ HALO និង MAG បានទទួលការគាំទ្រពី CMAA និងរាជរដ្ឋាភិបាលកម្ពុជា ។ លោក អគ្គលេខាធិការ **សម សុត្ថា** បានបញ្ជាក់ថា " ដីដែលគេបានកាន់កាប់ឡើងវិញមិនទាក់ទងទៅនឹងដី ដែលត្រូវបានបោសសំអាតឡើងវិញនោះទេ។ ផ្ទុយទៅវិញវាត្រូវបានគេចាត់ទុកថាជាដីដែលគេបានកាត់បន្ថយគ្រោះថ្នាក់ដល់កំរិតមួយ ដែលគេមិនគួរយកមកពិចារណាដើម្បីធ្វើការបោសសំអាតមីនបន្តទៀតឡើយ លើកលែងតែក្នុងកាលៈទេសៈពិសេស ( ដូចជា សំរាប់ហេដ្ឋារចនាសម្ព័ន្ធ) ។[61]

ការសិក្សាថ្នាក់ជាតិមួយអំពី ERW ដែលធ្វើឡើងដោយអង្គការជំនួយរបស់ប្រជាជនណ័រវេសសំរាប់ CMAC

---

[57] HALO, “The need to document reclaimed land on the National Mine Area Database in Cambodia,” Phnom Penh, 16 September 2005, p. 2; email from Richard Boulter, HALO, Cambodia, 31 May 2006.
[58] HALO, “The need to document reclaimed land on the National Mine Area Database in Cambodia,” Phnom Penh, 16 September 2005, pp. 2-4.
[59] Email from Tim Carstairs, MAG, 12 July 2006.
[60] Interview with Heng Rattana, Deputy Director General, CMAC, Phnom Penh, 22 March, 2006.
[61] Statement by Sam Sotha, CMAA, to a Landmine Monitor panel on mine action, Landmine Monitor Global Research Meeting, Phnom Penh, 3 April 2006; CMAA, “Draft Strategy on Area Reduction,” Phnom Penh, 26 April 2006.

បានសង្កេតឃើញថា " ការបញ្ចប់ផលប៉ះពាល់របស់គ្រាប់មីនកប់ដីអោយបានឆាប់អាចសំរេចទៅបានអាស្រ័យដោយបច្ចេកទេសកាត់បន្ថយផ្ទៃដីប្រកបដោយគំនិតច្នៃប្រឌិតខ្ពស់។ តំបន់តាមព្រំដែនដែលនៅមានឥទ្ធិពលដោយសារគ្រាប់មីនក៏រិតខ្ពស់អាចត្រូវបានគេកាត់បន្ថយបានក្នុងរយៈពេល ៥ ទៅ ១០ឆ្នាំ " ហើយបានកត់សំគាល់ថា បើទោះបីជាគេបង្ហាញថាការប៉ាន់ស្មានមានលក្ខណៈអភិរក្សក៏ដោយចុះ។[62] របាយការណ៏នោះក៏បានសង្កេតឃើញផងដែរថាការកាន់កាប់ដីឡើងវិញកំពុងធ្វើអោយយុទ្ធសាស្ត្រដោះមីនរបស់កម្ពុជាបច្ចុប្បន្នមានលក្ខណៈស្មុគស្មាញ និងមិនចាំបាច់ “redundant” ហើយក៏បានរកឃើញថាមានបញ្ហាដោយសារកង្វះចក្ខុវិស័យបញ្ចប់ច្បាស់លាស់ (end state vision) "។[63] ល្បឿននៃការបោសសំអាតដ៏គំហុក និងការកាត់បន្ថយផ្ទៃដីបានស្តែងអោយឃើញនូវតំរូវការជាបន្ទាន់ក្នុងការកំណត់នូវគ្រោះថ្នាក់ ដែលនៅសេសសល់ និងការប្រថុយគ្រោះថ្នាក់ដោយសារគ្រាប់មីន និង ERW ក្នុងក៏រិតអប្បរមានិងអាចទទួលយកបានព្រមទាំងការយកចិត្តទុកដាក់លើតំរូវការរបស់ស្ថាប័ននាពេលអនាគត ចំពោះបញ្ហាបោសសំអាតមីននិងការគំរាមកំហែងយូរអង្វែងនៃERW ។[64] អាជ្ញាធរមីនកម្ពុជា និងក្រុមការងារបច្ចេកទេសរបស់អ្នកផ្តល់ជំនួយ/រដ្ឋាភិបាលបានអនុម័តនូវពង្រាងយុទ្ធសាស្ត្រកំចាត់គ្រាប់ជាទិសដៅគន្លឹះសំរាប់ឆ្នាំ ២០០៦ ។[65]

*សេចក្តីសង្ខេបនៃកិច្ចខិតខំប្រឹងប្រែងអនុវត្តមាត្រាទី៥*

អនុលោមតាមមាត្រាទី ៥ នៃសន្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីន ប្រទេសកម្ពុជាមានកាតព្វកិច្ចបោសសំអាតគ្រាប់មីនប្រឆាំងមនុស្សទាំងអស់ចេញពីតំបន់ដែលមានគ្រាប់មីនដែលស្ថិតនៅក្រោមសមត្ថកិច្ច ឬការត្រួតត្រារបស់ខ្លួនអោយបានឆាប់តាមដែលអាចធ្វើទៅបាន ប៉ុន្តែមិនអោយហួសពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១០ ។ សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានដាក់ចេញនូវគោលដៅមួយសំដៅធ្វើអោយរួចចាកផុតពីផលប៉ះពាល់ដោយសារគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះ នៅឆ្នាំ ២០១២ ដែលបង្កប់ន័យថាកម្ពុជាប្រហែលជាមិនអាចសំរេចបានតាមកាលកំណត់ក្នុងមាត្រា ៥ ឡើយ ។ នៅក្នុងខែ មេសា ឆ្នាំ ២០០៦ អគ្គលេខាធិការរបស់អាជ្ញាធរមីនកម្ពុជាបានអះអាងថា ប្រទេសកម្ពុជាមិនអាចសំរេចការងារតាមកាលកំណត់នោះបានទេហើយគេត្រូវការ "ការពន្យារពេល" ។[66] លោកបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលនឹងប្រាប់រយៈពេលនៃការពន្យារនោះអោយបានច្បាស់លាស់តាមការស្នើសុំ ហើយនិងពន្យល់បកស្រាយអោយបានពិស្តារពីមូលហេតុនៃការ ពន្យារពេល ។

## ការដោះមីននាឆ្នាំ ២០០៥

អង្គការប្រតិបត្តិការដោះមីនមនុស្សធម៌ចំនួន ៣ បានដឹកនាំការអនុវត្តន៏សកម្មភាពមីននៅក្នុងប្រទេសកម្ពុជាៈ គឺ អង្គការ CMAC ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៩២, អង្គការ HALO ដែលបានចាប់ដំណើរការនៅឆ្នាំ ១៩៩១ និង អង្គការក្រុមផ្តល់ប្រឹក្សាអំពីមីន (MAG) ដែលបានចាប់ផ្តើមធ្វើប្រតិបត្តិការក្នុងខែវិច្ឆិការឆ្នាំ១៩៩២។ កងយោធពលខេមរភូមិន្ទ

[62] Email from Tim Carstairs, MAG, 12 July 2006.
[63] Dave McCracken, “National Explosive Remnants of War Response Study, Cambodia,” (draft), NPA/CMAA, Phnom Penh, March 2006, pp. vii, 73.
[64] Interview with Dave McCracken, NPA, Phnom Penh, 21 March 2006.
[65] Email from Julien Chevillard, UNDP, Phnom Penh, 1 June 2006.
[66] Statement by Sam Sotha, CMAA, to a Landmine Monitor panel on mine action, Phnom Penh, 3 April 2006.

បានផ្តល់នូវទីភ្នាក់ងារបោសសំអាតមីនដ៏ចំបងជាលើកទី៤ តាមរយៈកងវិស្វកម្មរបស់ខ្លួន ដែលបានធ្វើការងារសំខាន់ជាលក្ខណៈពាណិជ្ជកម្ម ដោយអនុវត្តកិច្ចសន្យារបស់រាជរដ្ឋាភិបាលដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីនិងធនាគារពិភពលោកប៉ុន្តែពុំមានការបញ្ជាក់ដោយឯករាជ្យនូវលទ្ធផលបោសសំអាតមីនដែលទីភ្នាក់ងារនេះបានអះអាងនោះឡើយ ។

អាជ្ញាធរមីនកម្ពុជា បានបដិសេធថាពុំមានក្រុមហ៊ុនពាណិជ្ជកម្មណាត្រូវបានគេទទួលស្គាល់អោយធ្វើប្រតិបត្តិការដោះមីននៅកម្ពុជាឡើយ ។[67] ប៉ុន្តែ បុគ្គលិក CMAA បានអះអាងថាក្រុមហ៊ុនពាណិជ្ជកម្មមួយគឺ ក្រុមហ៊ុនសកម្មភាពមីននិងគ្រាប់មិនទាន់ផ្ទុះបានធ្វើការបោសសំអាតមីននៅក្នុងឆ្នាំ ២០០៦ ប៉ុន្តែដំបូងៗគេមិនអាចស្គាល់ម្ចាស់របស់ ក្រុមហ៊ុននេះឡើយ ។[68] ក្នុងខែ ឧសភា ឆ្នាំ ២០០៦ ក្រុមហ៊ុនសកម្មភាពមីននិងគ្រាប់មិនទាន់ផ្ទុះបានដាក់ពាក្យស្នើសុំការទទួលស្គាល់ ។[69] តាមពាក្យចចាមអារាមបានអោយដឹងថា យ៉ាងហោចណាស់មានក្រុមហ៊ុនប្រតិបត្តិការដោះមីន ជាលក្ខណៈពាណិជ្ជកម្មចំនួន១៥ បានទទួលលិខិតអនុញ្ញាតជាបណ្តោះអាសន្នរយៈពេល ៦ខែ និងដែលអាចធ្វើជាថ្មីបានសំរាប់ធ្វើប្រតិបត្តិការពីអាជ្ញាធរមីនកម្ពុជា ។[70]

*ការកំណត់អត្តសញ្ញាណតំបន់ដែលរងគ្រោះដោយសារគ្រាប់មីននិងERW : ការវាស់ស្ទង់និងការវាយតំលៃ*

ប្រទេសកម្ពុជាមានទិន្នន័យដែលបានមកពីការវាស់ស្ទង់តាមផ្នែកនានា ដែលជាការវាស់ស្ទង់ផលប៉ះពាល់ដែលបានបញ្ចប់ទៅនៅឆ្នាំ ២០០២ និងការវាស់ស្ទង់បច្ចេកទេសស៊ីជំរៅដែលធ្វើឡើងដោយអង្គការប្រតិបត្តិការដោះមីននានាក្នុងរយៈពេល១៤ ឆ្នាំកន្លងទៅ ។[71] ប៉ុន្តែ ប្រទេសនេះនៅតែកំពុងជួបប្រទះបញ្ហាប្រឈមក្នុងការវិភាគទិន្នន័យ ដើម្បីកំណត់អាទិភាពនិងគោលដៅបោសសំអាតមីន ។ នៅក្នុងឆ្នាំ ២០០៥ មានការផ្តោតការយកចិត្តទុកដាក់ទៅលើការទទួលបានការទទួលស្គាល់ជាវិជ្ជមាននូវទំហំផ្ទៃដីដែលអ្នកផ្តួចផ្តើមបោសសំអាតមីនក្រៅផ្លូវការបានធ្វើការបង្កបង្កើនផលឡើងវិញ ។

ការស្រាវជ្រាវផលប៉ះពាល់មីនកំរិត១ (LIS) បានបន្សល់ទុកនូវឧបករណ៍សំរាប់ធ្វើផែនការគ្រឹះ ដែល MAPU ប្រើប្រាស់ ។ គេបានប៉ាន់ប្រមាណថា ផ្ទៃដីប្រមណ ៤,៤៤៦ គីឡូម៉ែត្រការេ ត្រូវបានគ្របដណ្តប់ដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះនិង ERW ផ្សេងៗ ដែលបានធ្វើអោយប្រជាពលរដ្ឋ ៥,១៨លាននាក់ រស់នៅក្នុងភូមិចំនួន ៦,៤២២ ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ។ ប៉ុន្តែ LIS បានដកស្រង់ការរិះគន់ពីសំណាក់អង្គការប្រតិបត្តិការនានាចំពោះការដាក់បញ្ចូលផ្ទៃដីដែលគេបោសសំអាតរួច ហើយមិនបានបញ្ចូលផ្ទៃដីមួយចំនួនដែលមានគ្រាប់មីន ។[72] ជាងនេះទៅទៀត "គេមិនបានបែងចែកប្រភេទ ដី អោយបានច្បាស់លាស់ទៅតាមកំរិតនៃបរិមាណគ្រាប់មីន" ។[73]

---

[67] Interview with Sam Sotha, CMAA, Phnom Penh, 20 March 2006.
[68] Information provided by CMAA staff, Phnom Penh, 24 March 2006.
[69] Email from Julien Chevillard, UNDP, Phnom Penh, 1 June 2006.
[70] Dave McCracken, "National Explosive Remnants of War Response Study, Cambodia," (draft), NPA/CMAA, Phnom Penh, March 2006, p. 23. The study notes that: "All inquiries meet silence at national coordination meetings on the nature, composition and authority in which commercial companies operate in Cambodia."
[71] Dave McCracken, "National Explosive Remnants of War Response Study, Cambodia," (draft), NPA/CMAA, Phnom Penh, March 2006, p. 18. Available data sources include an UNTAC Mine Liaison Team Survey (1992-1993), HALO Trust Survey (1992-1993), CMAC Verification Survey (1996-1997) and the databases of CMAC, HALO Trust and MAG.
[72] CMAC found that more than 15 percent of land designated for clearance in the 2003 workplan was not included in the LIS.
[73] HALO, "The need to document reclaimed land on the National Mine Area Database in Cambodia," Phnom Penh, 16 September 2005, p. 2.

នៅក្នុងឆ្នាំ ២០០៥ អង្គការ HALO បានដាក់ពង្រាយក្រុមវាស់ស្ទង់ចំនួន៣ក្រុមសំរាប់រយៈពេលពីរខែ ដើម្បីស៊ើបអង្កេតអំពីគំនិតផ្តួចផ្តើមនៃការចូលកាន់កាប់ដីឡើងវិញនៅមូលដ្ឋានក្នុងស្រុកចំនួន ៣ នៃខេត្តចំនួន ២ ។ ពួកគេបានរកឃើញថាកសិករបានកាន់កាប់ដីឡើងវិញចំនួន ៣,៤៥៣ ហិកតា (៣៤.៥៣ គីឡូម៉ែត្រការេ) ដោយបានបោសសំអាតមីនចំនួន ៣,៣៧១ និង គ្រាប់មិនទាន់ផ្ទុះចំនួន ២,២២២ គ្រាប់ ហើយរងរបួសតែម្នាក់ប៉ុណ្ណោះ។ អង្គការ HALO បានសន្និដ្ឋានថា "ការផ្តួចផ្តើមក្រៅផ្លូវការនេះមានតំលៃស្មើនឹងទឹកប្រាក់ចំនួន ១០ លានដុល្លារសំរាប់អង្គការប្រតិបត្តិករដោះមីនធ្វើការបោសសំអាត ដូច្នេះហើយកិច្ចការនេះសមនឹងទទួលបានការយកចិត្តទុកដាក់អោយបានហ្មត់ចត់ "។[74]

ការស៊ើបអង្កេតនេះបានអោយដឹងថា "តាមពិត ផ្ទៃដីដែលគេសង្ស័យតាមបច្ចេកទេសទាំងនេះភាគច្រើន ត្រូវបានគេដាក់មីនម្តងម្កាល ហើយជានិច្ចកាលមានគ្រាប់ផ្ទុះវែង១ (long-redundant ordnance) ដែលរងការបំផ្លាញដោយឥទ្ធិពលនៃពេលវេលានិងធម្មជាតិ ។ បច្ចុប្បន្ននេះ ទីភ្នាក់ងារបោសសំអាតមីនផ្លូវការនានាកំពុងកាត់យកបញ្ហាមីនទាំងមូលក្នុងក៏រិត ២០ គីឡូម៉ែត្រការេ (២,000 ហិកតា) ក្នុងមួយឆ្នាំ ។ ដូច្នេះ ដីដែលគេសង្ស័យហើយបានចុះបញ្ជីរួចភាគច្រើននឹងមិនត្រូវបានគេធ្វើការបោសសំអាតទេ ប្រសិនបើគេធ្វើគឺក្នុងរយៈពេលរាប់ទសវត្សខាងមុខ ។ ទិន្នន័យពី LIS នៅតែជាអាំងឌីកាទ័រសំខាន់សំរាប់អ្នកធ្វើផែនការអំពីតំរូវការបោសសំអាតមីនរបស់រដ្ឋាភិបាល ដូច្នេះហើយគេត្រូវធ្វើការកែសំរួលអោយទាន់ពេលវេលាដើម្បីដាក់បញ្ចូលកិច្ចខិតខំប្រឹងប្រែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។[75]

## ការបោសសំអាតមីន និងសំណល់ជាតិផ្ទុះដែលសេសសល់ពីសង្គ្រាម (ERW)

ដីដែលត្រូវបានបោសសំអាតដោយអង្គការប្រតិបត្តិការដោះមីនមនុស្សធម៌បីក្នុងប្រទេសកម្ពុជា ដែលជាចំបងប្រើប្រាស់ក្រុមដោះមីនដោយដៃ ជាមួយនឹងគ្រឿងបរិក្ខារមេកានិច និង ក្រុមឆ្កែរកមីនមួយចំនួនបានកើនឡើងចំនួន ៦៣ ភាគរយនៅក្នុងឆ្នាំ ២០០៥ គិតជាផ្ទៃដីមាន ៣០.៩ គីឡូម៉ែត្រការេ ។ ការកើនឡើងនេះជាសំខាន់អាស្រ័យដោយការកើនឡើងនូវសមត្ថភាពការងាររបស់ CMAC ដែលបានធ្វើការបោសសំអាតផ្ទៃដីកើនឡើងជិតពីរដង។

កងយោធពលខេមរភូមិន្ទ ក៏បានដោះមីននៅលើផ្ទៃដីជាសំខាន់សំរាប់ទ្រទ្រង់ដល់គំរោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាតិ។ នៅក្នុងឆ្នាំ២០០៥ កងយោធពលខេមរភូមិន្ទ បានផ្តោតទៅលើការបោសសំអាតមីនក្នុងខេត្តភាគខាងកើត មានខេត្តក្រចេះ និងស្ទឹងត្រែងជាចំណែកមួយនៃការកសាងផ្លូវជាតិលេខ ៧។ គេបានរាយការណ៏មកថា សកម្មភាពកំចាត់មីន និងគ្រាប់មិនទាន់ផ្ទុះក៏បានគេធ្វើដើម្បីបោសសំអាតមីនតាមដងផ្លូវក្នុងខេត្តបន្ទាយមានជ័យក្នុងនាមក្រសួងសាធារណៈការ។[76]

**ផ្ទៃដី ( គិតជាម៉ែត្រការេ) ដែលបានដោះមីនរួច និង ចំនួនគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ដែលត្រូវបានបំផ្លាញចោលក្នុងប្រទេសកម្ពុជា ពីឆ្នាំ ២០០១ ដល់ ២០០៥**[77]

[74] Ibid.
[75] Ibid.
[76] Information provided by CMAA staff, Phnom Penh, 24 March 2006.
[77] Statistics provided by CMAA, 23 March 2006. There are a number of mostly small discrepancies between the totals reported by CMAA in March 2006 and previous Landmine Monitor reporting. Bigger discrepancies occurred with MAG in 2003 and with HALO's number of antivehicle mines destroyed in 2001. In its Article 7 report for 2005, Cambodia reported different numbers of antipersonnel mines cleared. Article 7 Report, Form G, dated April 2006.

| | | 2001 | 2002 | 2003 | 2004 | 2005 |
|---|---|---|---|---|---|---|
| អង្គការ CMAC | ផ្ទៃដីដែលបានដោះមីនរួច | 9,637,455 | 11,582,239 | 9,708,686 | 11,157,336 | 22,086,486 |
| | មីនប្រឆាំងមនុស្ស | 16,916 | 32,688 | 22,160 | 43,635 | 74,165 |
| | មីនប្រឆាំងរថក្រោះ | 465 | 493 | 504 | 936 | 851 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 77,034 | 61,840 | 76,671 | 106,360 | 128,865 |
| អង្គការ MAG | ផ្ទៃដីដែលបានដោះមីនរួច | 1,400,149 | 1,766,740 | 2,619,740 | 2,039,495 | 3,149,018 |
| | មីនប្រឆាំងមនុស្ស | 4,898 | 1,870 | 4,790 | 6,687 | 4,037 |
| | មីនប្រឆាំងរថក្រោះ | 37 | 50 | 44 | 58 | 66 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 10,816 | 5,882 | 4,965 | 16,394 | 17,336 |
| អង្គការ HALO | ផ្ទៃដីដែលបានដោះមីនរួច | 4,366,828 | 4,400,541 | 5,007,019 | 5,681,054 | 5,650,790[78] |
| | មីនប្រឆាំងមនុស្ស | 4,699 | 4,485 | 8,463 | 20,020 | 38,433[79] |
| | មីនប្រឆាំងរថក្រោះ | 140 | 124 | 224 | 588 | 611 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 7,319 | 5,638 | 18,568 | 18,709 | 27,146 |
| អង្គការ Humanitarian operators total | ផ្ទៃដីដែលបានដោះមីនរួច | 15,404,432 | 17,749,520 | 17,335,445 | 18,877,885 | 30,886,294 |
| | មីនប្រឆាំងមនុស្ស | 26,513 | 39,043 | 35,413 | 70,342 | 116,635 |
| | មីនប្រឆាំងរថក្រោះ | 642 | 667 | 772 | 1,582 | 1,528 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 95,169 | 73,360 | 100,204 | 141,463 | 173,347 |
| RCAF | ផ្ទៃដីដែលបានដោះមីនរួច | 6,482,357 | 17,118,994 | 24,348,664 | 13,129,136 | 9,744,500 |
| | មីនប្រឆាំងមនុស្ស | 2,581 | 1,935 | 25,841 | 1,133 | 234 |
| | មីនប្រឆាំងរថក្រោះ | 15 | 266 | 307 | 161 | 52 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 4,060 | 3,680 | 21,094 | 12,729 | 9,182 |
| សរុប | ផ្ទៃដីដែលបានដោះមីនរួច | 21,886,789 | 34,868,514 | 41,684,109 | 32,007,021 | 40,630,794 |
| | មីនប្រឆាំងមនុស្ស | 29,094 | 40,978 | 61,254 | 71,475 | 116,869 |
| | មីនប្រឆាំងរថក្រោះ | 657 | 933 | 1,079 | 1,743 | 1,580 |
| | គ្រាប់មិនទាន់ផ្ទុះ UXO | 99,229 | 77,040 | 122,298 | 154,192 | 182,529 |

[78] HALO later amended this figure to 5,622,609 million square meters (as in HALO's Annual Report 2005); email from Richard Boulter, HALO, Phnom Penh, 31 May 2006.

[79] Including 21,015 antipersonnel mines cleared manually, 5,720 cleared by EOD teams and 11,698 cleared in an operation destroying munitions found in RCAF's K86 storage depot in Kampong Speu province. In the K86 operation, HALO also destroyed 15.9 metric tons of conventional ammunition and 24.5 metric tons of small arms ammunition.

អង្គការ CMAC ដែលជាអង្គការប្រតិបត្តិការដោះមីនដ៏ធំជាងគេដែលមានបុគ្គលិកចំនួន ២៣០០ នាក់ បានបោសសំអាតមីនលើផ្ទៃដី ២២,១ គីឡូម៉ែត្រការេ នៅក្នុងឆ្នាំ ២០០៥ ច្រើនជាងការបោសសំអាតមីនសរុបប្រចាំឆ្នាំរបស់អង្គការប្រតិបត្តិការដោះមីនធំៗទាំងបីរបស់កម្ពុជាក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ។ លើសពីនេះទៅទៀត អង្គការនេះបានកាត់បន្ថយផ្ទៃដីចំនួន ៣៥ គីឡូម៉ែត្រការេផ្សេងទៀត។[80] នៅក្នុងឆ្នាំ ២០០៦ អង្គការ CMAC មានគោលដៅការបោសសំអាតមីនលើផ្ទៃដីចំនួន ២២ គីឡូម៉ែត្រការេបន្ថែមទៀត ថ្នាក់ដឹកនាំអង្គការនេះជឿជាក់ថា ខ្លួនអាចសំរេចបានរហូតដល់ជិត ២៤ គីឡូម៉ែត្រការេឯណោះ ។[81]

អង្គការ CMAC បានចាត់ទុកលទ្ធផលការងារល្អជាងមុនរបស់ខ្លួនថា មួយចំណែកបានមកពីការបែងចែកគ្រឿងបរិក្ខារមេកានិចចំបងថ្មីៗ និងមួយចំណែកទៀតបានមកពីការប្រើប្រាស់វិធីសាស្ត្របោសសំអាតមីនតាមបែប “tool box approach” បានកាន់តែប្រសើរ ដោយបានប្រើប្រាស់គ្រឿងបរិក្ខារនិងវិធីសាស្ត្រផ្សេងៗនៅក្នុងចំការមីនដូចគ្នា ដើម្បីឆ្លើយតបទៅនឹងប្រភេទផ្សេងៗគ្នារបស់ទីលាន។ គ្រឿងបរិក្ខារថ្មីៗរួមមានប្រដាប់កាត់ស្មៅចំនួន១៤គ្រឿង ដែលថ្នាក់ដឹកនាំបានអោយដឹងថាអាចបង្កើនផលិតភាពការងាររបស់ក្រុមបោសសំអាតមីនបានពីរឬបីដងទៀតផង, ឧបករណ៍រាវមីនថ្មីៗ ចំនួន ៥០០ គ្រឿង និងរថយន្តដឹកជញ្ជូនថ្មីចំនួន ១០០ ដែលបង្កើនប្រសិទ្ធភាពនៃការចល័តអ្នកដោះមីន។[82]

ក្នុងឆ្នាំ ២០០៥ អង្គការ CMAC បានកែលំអនិតិវិធីប្រតិបត្តិអចិន្ត្រៃយ៍របស់ខ្លួនសំរាប់ការបោសសំអាតមីន ហើយបន្ទាប់ពីការសាកល្បងអស់រយៈពេលជិតពីរឆ្នាំមក CMAC បានប្រើប្រាស់ការហ្វឹកហាត់ដោះមីនមួយជួរម្នាក់ឬក៏មួយជួរពីរនាក់ដើម្បីបង្កើនផលិតផលការងារ។ អង្គការ CMAC ក៏ដូចជាអង្គការក្រុមផ្តល់យោបល់អំពីមីនដែរ គាំទ្រនូវការដោះមីនតាមសហគមន៍ អង្គការនេះបានបណ្តុះបណ្តាល និងបំពាក់សំភារៈអោយអ្នកភូមិដើម្បីធ្វើការបោសសំអាតមីនដោយដៃ និងដាក់ពង្រាយពួកគេអោយធ្វើកិច្ចការនៅមូលដ្ឋានក្រោមការគ្រប់គ្រងរបស់មេបញ្ជាការកងឯកភាពរបស់ CMAC។ អង្គការ CMAC ក៏ចាត់ទុកកំណើនផលិតភាពរបស់ខ្លួនថាមួយចំណែកបានមកពីការប្រើប្រាស់ក្រុមវាស់ស្ទង់ បច្ចេកទេស និងមួយចំណែកទៀតបានមកពីក្រុមកាត់បន្ថយគ្រោះថ្នាក់មីននៅតាមសហគមន៍ ក្នុងការកំណត់ភារកិច្ច និងកាត់បន្ថយផ្ទៃដីមុននឹងធ្វើការបោសសំអាតមីន។[83]

អង្គការ CMAC បានជ្រើសរើសយកក្រុមកាត់បន្ថយគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះដែលឈរជើងនៅមូលដ្ឋាននិងក្រុមដាក់ផ្លាកសំគាល់មីននៅតាមសហគមន៍ ដើម្បីចលនាអោយសហគមន៍មូលដ្ឋានចូលរួមក្នុងការប៉ាន់ស្មានគ្រោះថ្នាក់ កំនត់អាទិភាពបោសសំអាតមីន ធ្វើផែនទីចំការមីន និងលើកកំពស់ការយល់ដឹងអំពីគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ។ [84] បន្ទាប់ពីការសាកល្បងក្នុងឆ្នាំ ២០០៥មក អង្គការ CMAC មានបំនងប្តូរក្រុមទាំងនេះអោយចូលធ្វើការក្នុងក្រុមបាសសំអាតមីនតាមមូលដ្ឋានដែលមានគ្នា ៩នាក់ ដើម្បីធ្វើការបោសសំអាតមីនជាទ្រង់ទ្រាយតូច (នៅទីកន្លែង

[80] CMAC, “Annual Report January-December 2005,” Phnom Penh, 2006, p. vi.
[81] Interview with Heng Rattana, CMAC, Phnom Penh, 22 March 2006.
[82] Ibid.
[83] Ibid; response to Landmine Monitor Questionnaire by Heng Rattana, CMAC, 9 March 2006.
[84] CMAC, “Annual Report January-December 2005,” Phnom Penh, 2006, p. vii.

ដែល មានផ្ទៃដីរហូតដល់ ១០០០០ ម៉ែត្រការេ) ដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហគមន៍ដែលត្រូវការការបោសសំអាតមីន ជាបន្ទាន់ និងភារកិច្ចកាត់បន្ថយផ្ទៃដី ។ អង្គការក៏មានគោលដៅដាក់ពង្រាយក្រុមវាស់ស្ទង់បច្ចេកទេសតូចៗចំនួន១៩ ក្រុម និង ធំចំនួន ៤ ក្រុមដើម្បីធ្វើការកាត់បន្ថយផ្ទៃដី និងរៀបចំបោសសំអាតចំការមីន ហើយក្រុមកាត់បន្ថយផ្ទៃដីចំនួនបីក្រុម ត្រូវបានគេចាត់អោយបំពេញភារកិច្ចបោសសំអាតមីនតាមការកំណត់ ព្រមទាំងធ្វើការវាស់ស្ទង់ ដាក់ផ្លាកសំគាល់ និង កាត់បន្ថយផ្ទៃដី។[85]

អង្គការ CMAC បានធ្វើអោយកម្ពុជាមានសមត្ថភាពកំចាត់គ្រាប់ផ្ទុះ (EOD) ដោយប្រើប្រាស់ក្រុមកំចាត់គ្រាប់ផ្ទុះ EOD ចំនួន ២១ ក្រុម ក្នុងចំណោមនោះ មាន ៥ក្រុមត្រូវបានឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលជប៉ុនឈ្មោះ Japan Mine Action Service ។ CMAC ក៏បានធ្វើការបណ្តុះបណ្តាលទាក់ទិននឹងការអប់រំអំពីគ្រោះថ្នាក់មីន និងការកាត់បន្ថយគ្រោះ ថ្នាក់ដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ នៅតាមមូលដ្ឋាន។[86] មជ្ឈមណ្ឌលបណ្តុះបណ្តាលរបស់ CMAC មិនត្រឹមតែបណ្តុះបណ្តាលបុគ្គលិករបស់ខ្លួនប៉ុណ្ណោះទេ ថែមទាំងបានបណ្តុះបណ្តាលអ្នកដោះមីនរបស់កងយោធពលខេមរភូមិន្ទដែលត្រៀមខ្លួនទៅបំរើការអោយអង្គការសហប្រជាជាតិនៅក្នុងប្រទេសស៊ូដង់ ព្រមទាំងបានបណ្តុះបណ្តាលនគរបាលជាតិចំនួន ២០០ នាក់ទៀតផង។[87]

អង្គការ HALO Trust ដែលមានបុគ្គលិកខ្មែរចំនួន ១,១២២ នាក់ និងបុគ្គលិកបរទេសចំនួន ៤ នាក់នៅដំណាច់ឆ្នាំ ២០០៥ បោសសំអាតបានផ្ទៃដីចំនួន ៥,៧ គីឡូម៉ែត្រការេនៅក្នុងខេត្តដែលមានគ្រាប់មីនច្រើនជាងគេបំផុតគឺ ខេត្ត បាត់ដំបង បន្ទាយមានជ័យ និងក្រុងប៉ៃលិន ដែលមានគ្រោះថ្នាក់កើតឡើងធ្ងន់ធ្ងរជាងគេ រួមមានតំបន់ខ្សែក្រវ៉ាត់មីនក៥ តាមព្រំដែន។[88] បរិមាណផ្ទៃដីដែលគេបានបោសសំអាតមានចំនួនតិចជាងឆ្នាំ ២០០៤បន្តិច ដែល HALO និយាយ ថា បណ្តាលមកពី "ការបោសសំអាតមីនដ៏លំបាកបំផុតខ្លះ" ដែលអ្នកបោសសំអាតមីនរបស់ខ្លួនបានជួបប្រទះក្នុងរយៈពេលជាច្រើនឆ្នាំ ដែលធ្វើអោយការចំរើនទៅមុខយឺតៗដោយសារមានមីនច្រើននិងមានរុក្ខជាតិដុះក្រាស់ឃ្មឹក ប៉ុន្តែចំនួនមីនដែលគេបានបោសសំអាតគឺច្រើនជាងគេក្នុងកំណត់ត្រារបស់ HALO។[89]

អង្គការ HALO ក៏បានផ្តោតការយកចិត្តទុកដាក់លើធនធានសំរាប់ការវាស់ស្ទង់និងការធ្វើផែនទី នៅក្នុងឆ្នាំ ២០០៥ ស្តីអំពីរក្សាទុកជាឯកសារនូវលទ្ធផលនៃការផ្តួចផ្តើមបោសសំអាតមីននៅតាមមូលដ្ឋាន ដើម្បីប្រគល់ដីដែលគេសង្ស័យថាមានមីនទៅអោយប្រជាពលរដ្ឋបង្កបង្កើនផលវិញ ។ នៅដំណាច់ឆ្នាំ ២០០៥ អង្គការ HALO បានធ្វើផែនទីសំរាប់ផ្ទៃដីច្រើនជាង ៥០ គីឡូម៉ែត្រការេ ដែលបានប្រគល់ដើម្បីបង្កបង្កើនផលវិញ ដែល បានយល់ព្រមដកចេញពីប្រព័ន្ធទិន្នន័យនៃដីដែលគេសង្ស័យថាមានមីន ។ អង្គការ HALOបានរាយការណ៍អោយដឹងថា នៅលើផ្ទៃដីចំនួន ៣០០ ហិកតា (៣ គីឡូម៉ែត្រការេ) ដែលខ្លួនបានបោសសំអាតសំរាប់ធ្វើកសិកម្មនៅក្នុងឆ្នាំ ២០០៥ អង្គការនេះបានកំចាត់មីនជាមធ្យម ៤០

85 CMAC, "Integrated Work Plan 2006," pp. 23, 28.
86 CMAC, "Annual Report January-December 2005," Phnom Penh, 2006, p. vii.
87 CMAC, "Progress report January to October 2005," Phnom Penh, 12 January 2006, pp. 5, 41.
88 Interview with Richard Boulter, HALO, Phnom Penh, 21 April 2006; HALO, "Annual Report 2005," 11 January 2006, p. 1.
89 HALO, "Annual Report 2005," 11 January 2006, p. 1.

គ្រាប់ក្នុង ១ ហិកតា ប្រៀបធៀបទៅនឹងមធ្យមភាគ ១ គ្រាប់ក្នុង ១ ហិកតាក្នុងដីដែលកសិករបានចូលកាន់កាប់ឡើងវិញ។ អង្គការ HALO បានសន្និដ្ឋានថា" វាស្តែងអោយឃើញច្បាស់ថា ទាំងកសិករទាំង អង្គការ HALO កំពុងធ្វើការវាយតំលៃភារកិច្ចដ៏ច្បាស់លាស់មុននឹងចាប់ផ្តើមធ្វើការងារ " ។[90]

អង្គការ HALO បានប៉ាន់ស្មានថាការបោសសំអាតមីនដោយអង្គការដោះមីនចេញពីដីនេះអាចមានតំលៃរហូតដល់ទៅជាង៥០លានដុល្លារសហរដ្ឋអាមេរិក។ អង្គការនេះបានពិពណ៌នាការចាត់ប្រភេទដីឡើងវិញថាជា " ជំហានដ៏ធំមួយឆ្ពោះទៅមុខដែលនៅទីបំផុតនឹងកាត់បន្ថយតំរូវការបោសសំអាតមីនផ្លូវការទាំងស្រុងបានយ៉ាងខ្លាំងក្លា ដូច្នេះហើយធ្វើអោយប្រទេសជាតិនិងអ្នកផ្តល់ជំនួយសន្សំថវិការាប់លានដុល្លារ " ។[91]

នៅក្នុងឆ្នាំ ២០០៥ អង្គការ Mines Advisory Group (MAG) បានទទួលបុគ្គលិកខ្មែរចំនួន ៤៨០នាក់ អោយធ្វើការ ដែលក្នុងនោះ ៣៣ ភាគរយជាស្ត្រី ៥ភាគរយ ជាជនពិការអវៈយវៈ ព្រមទាំងបុគ្គលិកបរទេសចំនួន ៣ នាក់។[92] អង្គការ MAG បានបង្កើនផលិតភាពការងារជាង ៥០ ភាគរយនៅក្នុងឆ្នាំ ២០០៥ សំរាប់រយៈពេលពីរឆ្នាំបន្ទាប់ (សូមមើលតារាង) ហើយសង្ឃឹមថានឹងបង្កើនម្តងទៀតនៅឆ្នាំ ២០០៦។ កត្តាសំខាន់ៗដែលរួមចំណែកអោយមានលទ្ធផលបោសសំអាតមីនខ្ពស់បែបនេះរួមមាន ការទទួលបានឧបករណ៏ Tempest mini-flails ចំនួន ៥ គ្រឿងនៅក្នុងឆ្នាំ ២០០៥ ដូច្នេះបច្ចុប្បន្នមានចំនួនសរុប៩គ្រឿងនិងការគ្រប់គ្រងធនធានតាមរបៀប “tool box”កាន់តែមានប្រសិទ្ធភាព។ ក្រុមទំនាក់ទំនងជាមួយសហគមន៏ចំនួន ៨ ក្រុមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលនិងវាយតំលៃទិន្នន័យ ហើយបន្ទាប់មកវាយតំលៃនិងចាត់អាទិភាពភារកិច្ច ។ ក្រុមទាំងនេះក៏បានធ្វើការវាយតំលៃការប្រើប្រាស់ដីក្រោយបោសសំអាតមីនរួច ៦ ខែបន្ទាប់ពីកិច្ចការត្រូវបានបញ្ចប់។ ក្រុមកំចាត់មីនរបស់អង្គការ MAG ចំនួន ១៣ ក្រុម, ក្រុមដោះមីនតាមតំបន់ ចំនួន ៩ ក្រុម និងក្រុមវាស់ស្ទង់បច្ចេកទេសចំនួន ៤ ក្រុម និងក្រុម EOD ចំនួន ១០ ក្រុម បានធ្វើការនៅក្នុខេត្តចំនួន ៦ ជាមួយក្រុមទំនាក់ទំនងជាមួយសហគមន៏ចំនួន ៨។[93] នៅក្នុងឆ្នាំ ២០០៥ អង្គការ MAG បានចាប់ផ្តើមធ្វើប្រតិបត្តិការជាមួយឆ្កែរាវមីន, ដែលចុះកិច្ចសន្យាជាមួយក្រុមពីរមកពីអង្គការ CMAC។[94]

អង្គការ MAG បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងកាធ្វើផែនទីផ្ទៃដីដែលគេបានចូលកាន់កាប់ឡើងវិញ ហើយបានកត់សំគាល់តួនាទីដ៏សំខាន់របស់អ្នកភូមិ ដែលអង្គការ MAG បណ្តុះបណ្តាលនិងបំពាក់សំភារៈសំរាប់ធ្វើការបោសសំអាតមីនងាយៗ។[95] ពួកគេបានសំរេចលទ្ធផលខ្ពស់ជាងក្រុមដោះមីនស្តង់ដាបន្តិច។[96] វិធីនេះត្រូវបានគេមើលឃើញថាបានផ្តល់នូវអត្ថប្រយោជន៏មួយចំនួន។ វាបញ្ចៀសបាននូវការប្រើប្រាស់អ្នកដោះមីនស្តង់ដាដែលមានប្រាក់ខែខ្ពស់ និង

---

[90] Ibid, pp. 3-5.
[91] Ibid, p. 2.
[92] Response to Landmine Monitor Questionnaire by Rupert Leighton, MAG, 1 February 2006; email from Tim Carstairs, MAG, 11 July 2006.
[93] Email from Tim Carstairs, MAG, 11 July 2006.
[94] Interview with Rupert Leighton, MAG, Phnom Penh, 20 March 2006.
[95] Email from Tim Carstairs, MAG, 11 July 2006.
[96] Interview with Rupert Leighton, MAG, Phnom Penh, 20 March 2006.

មានជំនាញច្រើនមុខសំរាប់ការដោះមីនងាយៗ សន្សំបានថ្លៃដឹកជញ្ជូននិងថ្លៃស្នាក់នៅសំរាប់ក្រុមអ្នកដោះមីនស្តង់ដាបង្កើតការងារធ្វើនៅតំបន់ដាច់ស្រយាល និង បង្កើនភាពជាម្ចាស់នៃការខិតខំប្រឹងប្រែងបោសសំអាតមីននៅមូលដ្ឋាន ។[97]

អង្គការ MAG បានរាយការណ៍អោយដឹងថា ខ្លួនបានធ្វើការខិតខំប្រឹងប្រែងគួរអោយកត់សំគាល់ជាច្រើនដើម្បីធ្វើសមាហរណកម្មសកម្មភាពមីនរបស់ខ្លួនទៅក្នុងកម្មវិធីអភិវឌ្ឍន៏និងកំនត់តំបន់បោសសំអាតដែលផ្តល់អត្ថប្រយោជន៏ដល់មនុស្សផង ដល់សុវត្ថិភាពផ្នែកសេដ្ឋកិច្ចផង, អង្គការនេះបានបង្កើតដៃគូជាមួយទីភ្នាក់ងារអន្តរជាតិនិងក្នុងស្រុក រួមមានអង្គការ CARE, World Vision, Wathnakpheap និង Church World Service ។[98]

ការដោះមីននៅតាមសហគមន៏ និងការធ្វើផែនទីដីដែលត្រូវបានគេចូលកាន់កាប់ឡើងវិញ ឆ្លុះបញ្ចាំងអោយឃើញការចូលរួមចំណែកដ៏សំខាន់របស់អ្នកភូមិចំពោះការដោះមីននៅកម្ពុជា ។[99] របាយការណ៏មួយនៅឆ្នាំ ២០០៥ បានជំរុញអោយមានការសិក្សាអំពីទំហំនៃការដោះមីនតាមមូលដ្ឋាន និង ចំនួនគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងកិច្ចការនេះ ដើម្បីផ្តល់មូលដ្ឋានសំរាប់អោយផ្នែកដោះមីនផ្លូវការធ្វើការជាមួយអ្នកដោះមីនតាមភូមិបន្ថែមទៀត ។ របាយការណ៏នេះ បានជំរុញអោយរដ្ឋាភិបាលទទួលស្គាល់ និងអោយការដោះមីនមិនផ្លូវការមានលក្ខណៈស្របច្បាប់ ដើម្បីជំរុញអោយមានការបណ្តុះបណ្តាល ការអនុវត្តន៏ការងារ និង ការបំពាក់ឧបករណ៏ស្តង់ដា ។[100]

CMAA បានទទួលស្គាល់ថា " គេត្រូវកត់ត្រានិងធ្វើផែនទីជាផ្លូវការនូវការផ្លាស់ប្តូរស្ថានភាព(status) នៃតំបន់នានាដែលពីមុនគេសង្ស័យថាមានមីន " ដើម្បីកែលំអការធ្វើផែនការសកម្មភាពមីន ។ អត្ថបទរបស់ CMAA មួយស្តីអំពីការកាត់បន្ថយផ្ទៃដីបានអោយដឹងថា ដីដែលត្រូវបានគេចូលកាន់កាប់ឡើងវិញ " .....នឹងត្រូវគេចាត់ទុកជាដីដែលមានការគំរាមកំហែងថយចុះដល់កំរិតមួយដែលគេមិនគួរធ្វើការពិចារណាបោសសំអាតមីនទៀតឡើយ លើកលែងតែមានករណីពិសេសកើតឡើង ( ដូចជាសំរាប់ហេដ្ឋារចនាសម្ព័ន្ធ) " ។[101]

អ្នកដោះមីនរបស់កងយោធពលខេមរភូមិន្ទមួយក្រុមដែលមានគ្នា ១៣៥ នាក់ត្រូវបានគេដាក់បញ្ជូនទៅប្រទេសស៊ូដង់ជាពីរដំណាក់កាលនៅក្នុងខែកុម្ភៈ និង ខែមេសាឆ្នាំ ២០០៦ ដើម្បីចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ, នេះគឺជាការចូលរួមលើកដំបូងបង្អស់របស់កម្ពុជានៅក្នុងប្រតិបត្តិការអង្គការសហប្រជាជាតិ ។ កងទ័ពទាំងនោះត្រូវបានគេរាយការណ៏ថា បានទទួលការបណ្តុះបណ្តាលអំពីការដោះមីនរយះពេល១៣ ខែ រួមមានមុខវិជ្ជាច្បាប់អន្តរជាតិ ភាសាអង់គ្លេស ។ [102] បន្ទាប់ពីបានធ្វើទស្សនកិច្ចនៅកម្ពុជាមុនពេលបញ្ជូនអ្នកដោះមីន ការិយាល័យ

---

[97] CARE, "Evaluation of the Community-Based Locality Demining model," Phnom Penh, 2005; email from Tim Carstairs, MAG, 12 July 2006.

[98] Email from Tim Carstairs, MAG, 11 July 2006.

[99] See *Landmine Monitor Report 1999*, pp. 392-405; *Landmine Monitor Report 2000*, pp. 388-395. In 2000, estimates were reported that informal village deminers had cleared 45 percent of all land cleared in Cambodia in 1993-1999, more than any other demining agency.

[100] Michael L. Fleischer, "Informal Village Demining in Cambodia, An Operational Study," Handicap International (HI), Phnom Penh, 2005, pp. 42-50.

[101] CMAA, "Draft Strategy on Area Reduction," Phnom Penh, 26 April 2006.

[102] "Cambodia to send deminers to Sudan," *Reuters*, 17 February 2006; "Cambodian mine-clearing soldiers to join UN in Sudan," *Xinhua News Agency*, 13 April 2006.

កំចាត់មីនអង្គការសហប្រជាជាតិប្រចាំប្រទេសស៊ូដង់បានបានសន្និដ្ឋានថា កងទ័ពកម្ពុជានឹងត្រូវការការបណ្តុះបណ្តាលបន្ថែមទៀតក្នុងប្រទេសស៊ូដង់ ដើម្បីទទួលបានស្តង់ដាបច្ចេកទេស និងគោលការណ៍ណែនាំ ផ្អែកលើមូលដ្ឋានស្តង់ដារកំចាត់មីនអន្តរជាតិ (IMAS) ដែលគេបានព្រៀងសំរាប់ប្រទេសស៊ូដង់ ។[103]

*សុវត្ថិភាពអ្នកដោះមីនៈ* អង្គការប្រតិបត្តិករដោះមីនបានរាយការណ៍អោយដឹងថាមានគ្រោះថ្នាក់ ១៤ ករណីនៅក្នុងឆ្នាំ ២០០៥ រួមមានស្លាប់ ១ នាក់ និងរបួសធ្ងន់ពីរនាក់ ។ អង្គការ CMAC បានអោយដឹងថាអ្នកដោះមីនរបស់ខ្លួនម្នាក់ត្រូវបានស្លាប់ដោយសារគ្រាប់មិនទាន់ផ្ទុះ ហើយម្នាក់ទៀតពិការកែវភ្នែកទាំងគូរដោយសារឧបទ្ទវហេតុគ្រាប់មិនទាន់ផ្ទុះ ។ អ្នកដោះមីន ៨នាក់ផ្សេងទៀតរងរបួសស្រាល។[104] អង្គការ HALO បានរាយការណ៍អោយដឹងថា អ្នកដោះមីនម្នាក់ដាច់ជើងនៅពេលដើរជាន់មីនគឺជាឧបទ្ទវហេតុតែមួយគត់ដែលទាមទារសំណងធានារ៉ាប់រង។ អ្នកដោះមីនពីរនាក់ផ្សេងទៀតទទួលការសំរាកព្យាបាលរបួសស្រាលដែលបណ្តាលមកពីឧបទ្ទវហេតុគ្រឿងផ្ទុះនៅមន្ទីរពេទ្យ ប៉ុន្តែបានវិលត្រលប់ទៅបំរើការងារវិញ។[105] អង្គការ MAG បានរាយការណ៍អោយដឹងថាមានការរងរបួសស្រាលមួយ។[106] ប្រត្តិបត្តិករដោះមីន បានស៊ើបអង្កេតរាល់គ្រោះថ្នាក់ដែលកើតមានក្នុងចំណោមបុគ្គលិករបស់ខ្លួនហើយធ្វើការកែលំអ ។

លើសពីនេះទៅទៀត មានគ្រោះថ្នាក់ដែលបណ្តាលមកពីការដោះមីន ៨ ករណីទៀត (សូមមើលនៅផ្នែក គ្រោះថ្នាក់ដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ) ។

## ដំណើរការដោះមីននៅក្នុងឆ្នាំ ២០០៦

នៅក្នុងខែឧសភា ឆ្នាំ ២០០៦ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** បានអនុម័តនូវយុទ្ធសាស្ត្រធ្វើចំណាត់ថ្នាក់ជាថ្មីនូវដីដែលត្រូវបានគេចូលកាន់កាប់ឡើងវិញ ក្នុងសន្និសីទប្រចាំឆ្នាំលើកទី៣ ដើម្បីពិនិត្យមើលឡើងវិញនូវសមិទ្ធផលកំចាត់មីនកន្លងមករបស់កម្ពុជា ។ គាត់បានមានប្រសាសន៍ថា អាជ្ញាធរមីនកម្ពុជា នឹងដើរតួនាទីនាំមុខក្នុងការសំរបសំរួលការកាត់បន្ថយផ្ទៃដី ដើម្បីធ្វើអោយប្រាកដថា ដីដែលត្រូវបានគេចូលកាន់កាប់ឡើងវិញ ត្រូវបានគេចុះបញ្ជីនិងតំកល់ទុកជាឯកសារបានត្រឹមត្រូវ។ ឯកឧត្តមបានជំរុញអោយអង្គការប្រតិបត្តិករដោះមីនទាំងឡាយ " ជួយអាជ្ញាធរមីនកំណត់អត្តសញ្ញាណដីដែលពីមុនគេសង្ស័យថាមានមីន ប៉ុន្តែត្រូវបានគេប្រគល់ទៅអោយប្រជាពលរដ្ឋ ដើម្បីបង្កបង្កើនផលវិញប្រកបដោយសុវត្ថិភាព "។ ឯកឧត្តមក៏បានអោយដឹងដែរថា អង្គការប្រតិបត្តិករដោះមីននានាគួរផ្តោតការយកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងបោសសំអាតមីនទាំងឡាយ នៅលើដីដែលមានគ្រាប់មីនច្រើនបំផុត។[107]

នៅក្នុងឆ្នាំ ២០០៦ អង្គការ CMAC រក្សាបាននូវនិន្នាការទៅរកកំណើនផលិតភាព, ដោយបានរាយការណ៍អោយដឹងថា ការបោសសំអាតមីនលើផ្ទៃដី ៩ គីឡូម៉ែត្រការេ ក្នុងរយៈពេល៤ខែដំបូង ដែលមានគ្រាប់មីនប្រឆាំង

[103] Interview with Paul Heslop, Deputy Program Manager/Chief of Staff, UN Mine Action Office, Khartoum, 19 March 2006.
[104] Response to Landmine Monitor Questionnaire by Heng Rattana, CMAC, 9 March 2006.
[105] HALO, "Annual Report 2005," 11 January 2006, p. 6.
[106] Response to Landmine Monitor Questionnaire by Rupert Leighton, MAG, 1 February 2006.
[107] Opening and closing statements of Deputy Prime Minister Sok An, Third Conference on Mine Action Achievements, Phnom Penh, 24 May 2006.

មនុស្សចំនួន ១០,៣៩៣ គ្រាប់ និងគ្រាប់មីនប្រឆាំងរថក្រោះចំនួន ៤៥៧ គ្រាប់ត្រូវបានកំទេចចោល ។[108]

អង្គការ HALO ហាក់ដូចជាស្ថិតក្នុងដំណើរការបោសសំអាតមីនតាមកំណើនមួយដែលបានកំណត់នៅឆ្នាំ ២០០៦ ដោយបានរាយការណ៍អោយដឹងថា ខ្លួនបានដោះមីនដោយដៃលើផ្ទៃដីចំនួន ១.៧ គីឡូម៉ែត្រការេ និងបោសសំអាតបែបមេកានិកលើផ្ទៃដី ៥.៩២៥ ម៉ែត្រការេ ក្នុងរយៈពេល៤ខែដំបូង ។ អង្គការនេះក៏បានបំផ្លាញចោល គ្រាប់មីនប្រឆាំងមនុស្សចំនួន ១០,០៤២ គ្រាប់ គ្រាប់មីនប្រឆាំងរថក្រោះចំនួន ៩១ គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះចំនួន ៦,៦៤៦ ។[109] អង្គការ MAG បានបោសសំអាតមីនចំនួន ១.៤ គីឡូម៉ែត្រការេ ក្នុងរយៈពេល៤ខែដំបូងនៃឆ្នាំ ២០០៦ និងបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន ១,២១៤ គ្រាប់ គ្រាប់មីនប្រឆាំងរថក្រោះចំនួន ១៨ គ្រាប់ និងគ្រាប់មីនមិនទាន់ផ្ទុះចំនួន ៦,២៥០ គ្រាប់ ។[110]

អង្គការមូលនិធិមនុស្សធម៌ Golden West បានចាប់ផ្តើមធ្វើការជាមួយ CMAC នៅក្នុងឆ្នាំ២០០៥ លើគំរោង Explosive Harvesting and recast Project ដែលឧបត្ថមថវិកាដោយកម្មវិធីអភិវឌ្ឍន៍ និងស្រាវជ្រាវរបស់នាយកដ្ឋានដោះមីនមនុស្សធម៌របស់សហរដ្ឋអាមេរិក ។ គំរោងកម្មវិធីនេះមានបំណងបង្កើតប្រព័ន្ធមួយសំរាប់យកគ្រឿងផ្ទុះ ដែលមានតំលៃខ្ពស់ចេញប្រកបដោយសុវត្ថិភាពពីគ្រាប់មីនប្រឆាំងរថក្រោះ គ្រាប់បែក និងគ្រាប់កាំភ្លើងធ្យូង ។ បន្ទាប់មក អង្គការនេះកែច្នៃគ្រាប់ទាំងនោះ ដើម្បីអោយក្រុម EOD ប្រើប្រាស់ដើម្បីបំផ្លាញគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះធំៗ ។[111] អង្គការនេះផ្តល់នូវការសន្សំប្រាក់រាប់លានដុល្លារដោយសារតំលៃគ្រឿងផ្ទុះ និងកាត់បន្ថយនូវការបំពុលដីនិងបរិស្ថាន ។[112] នៅក្នុងខែមករាឆ្នាំ២០០៦ អង្គការGolden West បានធ្វើការសាកល្បងនៅនិងទីកន្លែងជាមួយអង្គការ CMAC និង HALO Trust ។[113]

## <u>ការអប់រំអំពីគ្រោះថ្នាក់មីន</u>

ក្រសួងអប់រំយុវជន និងកីឡា, CMAC, កាកបាទក្រហមកម្ពុជា, HALO, MAG និងអង្គការ World Vision បានផ្តល់ការអប់រំស្តីពីគ្រោះថ្នាក់មីន (MRE) នៅក្នុងឆ្នាំ២០០៥ ។ UNICEF បានបន្តផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ។ អង្គការទាំងនេះបានរាយការណ៍អោយដឹងថា បានធ្វើការអប់រំស្តីពីគ្រោះថ្នាក់មីន ដល់ប្រជាពលរដ្ឋចំនួន ៧៨១,៨៨៩ នាក់ ក្នុងឆ្នាំ២០០៥ រួមទាំងទស្សនកិច្ចចុះឡើងផង ។[114] ពីឆ្នាំ១៩៩៩ ដល់ ២០០៥ ប្រជាពលរដ្ឋប្រមាណ ៤.២លាននាក់បានចូលរួមក្នុងវគ្គអប់រំស្តីពីគ្រោះថ្នាក់មីន ។[115]

ការអប់រំស្តីពីគ្រោះថ្នាក់មីននៅកម្ពុជា បានជ្រួតជ្រាបដល់ប្រជាជនជាង៤លាននាក់ចាប់តាំងពីឆ្នាំ ១៩៩៣ មក ។

[108] Statement by Khem Sophoan, Director General, CMAC, Third Conference on Mine Action Achievements, P.Penh, 24 May 2006.
[109] Email from Richard Boulter, HALO, Cambodia, 31 May 2006.
[110] Telephone interview with Rupert Leighton, MAG, Phnom Penh, 29 May 2006.
[111] Powerpoint presentation, in email from Roger Hess, Director, Field Operations, Golden Harvest Humanitarian Foundation, 28 March 2006.
[112] CMAC, “Annual Report January-December 2005,” Phnom Penh, 2006, p. ix.
[113] Powerpoint presentation, in email from Roger Hess, Golden Harvest Humanitarian Foundation, 28 March 2006.
[114] CMAA, “Summary of 2005 Annual Mine Risk Education Report,” Phnom Penh, 2006, p. 2; UNICEF, “Mine/UXO risk education in Cambodia,” presentation for Landmine Monitor Global Research Meeting, Phnom Penh, 3 April 2006. The figure was corrected by Landmine Monitor to accord with: Cambodian Red Cross, “Community Based Landmine/UXO Risk Education Program Annual Report 2005,” p. 2, www.redcross.org.kh, accessed on 14 July 2006.
[115] CMAA, “Summary of 2005 Annual Mine Risk Education Report,” Phnom Penh, 2006, p. 2.

តែទោះជាយ៉ាងណាក្តី ចំនួនគ្រោះថ្នាក់នៅតែមានកំរិតខ្ពស់ ជាពិសេសចំពោះបុរស និងក្មេងប្រុសៗ ប៉ុន្តែចំនួនស្ត្រីរងគ្រោះបានកើនឡើងក្នុងរយៈបីឆ្នាំមុន។[116] យោងតាមប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីនកម្ពុជា (CMVIS) ជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះជាង៨០% បានទទួលការអប់រំអំពីគ្រោះថ្នាក់មីន មុននឹងមានឧបទ្ទវហេតុកើតឡើង។ តំរូវការជីវភាពរស់នៅនិងភាពក្រីក្របង្ខំអោយប្រជាពលរដ្ឋប្រថុយនឹងគ្រោះថ្នាក់ ដែលមិនអាចទទួលយកបាន។[117]

ដើម្បីធ្វើអោយស្ថានភាពនេះបានប្រសើរឡើង គេបានធ្វើការពិនិត្យមើលឡើងវិញនូវយុទ្ធសាស្ត្រអប់រំអំពីមីនរបស់ប្រទេសកម្ពុជានៅក្នុងត្រីមាសទីមួយឆ្នាំ២០០៦។[118] យុទ្ធសាស្ត្រអប់រំអំពីគ្រោះថ្នាក់មីនថ្មីសំរាប់ឆ្នាំ ២០០៦-២០១២ មានគោលដៅកាត់បន្ថយគ្រោះថ្នាក់ដោយធ្វើអោយសហគមន៏ ដែលរងគ្រោះដោយសារមីនអាចយល់ដឹងអំពីវិធីសាស្ត្រអប់រំ/កាត់បន្ថយគ្រោះថ្នាក់អោយបានត្រឹមត្រូវនិងមានប្រសិទ្ធិភាព និងដោយធ្វើសមាហរណកម្មកិច្ចខិតខំប្រឹងប្រែងទាំនេះជាមួយនិងសកម្មភាពផ្នែកអភិវឌ្ឍន៏និងមនុស្សធម៌ ដែលមានលក្ខណៈទូលំទូលាយ។ ស្តង់ដាសកម្មភាពមីននៅកម្ពុជាអំពីការអប់រំស្តីពីគ្រោះថ្នាក់មីននឹងត្រូវបានគេបង្កើតឡើង។[119] យុទ្ធសាស្ត្រកំចាត់មីនថ្នាក់ជាតិរបស់កម្ពុជា (កែសំរួលចុងក្រោយក្នុងខែមិថុនាឆ្នាំ២០០៥) មានគោលបំណងពង្រឹងការអប់រំអំពីគ្រោះថ្នាក់មីន ដើម្បីកាត់បន្ថយចំនួនគ្រោះថ្នាក់អោយបានច្រើននៅដំណាច់ឆ្នាំ២០០៦។[120]

នៅក្នុងឆ្នាំ២០០៦, CMVIS បានចូលរួមធ្វើការងារជាមួយក្រុមអង្គការមិនមែនរដ្ឋាភិបាលដែលផ្តល់ការអប់រំ ស្តីអំពីគ្រោះថ្នាក់មីន ដើម្បីជួយកាត់បន្ថយគ្រោះថ្នាក់។[121]

អង្គការផ្តល់ការអប់រំស្តីអំពីគ្រោះថ្នាក់មីនក្នុងប្រទេសកម្ពុជា មានបុគ្គលិកដែលមានសមត្ថភាពសំខាន់ៗនៅក្នុង ឆ្នាំ២០០៥ៈអង្គការ CMAC មានបុគ្គលិក៦២នាក់ អ្នកស្ម័គ្រចិត្តជាច្រើន នៅក្នុងបណ្តាញកាត់បន្ថយគ្រោះថ្នាក់ដោយសារមីនដែលតាមមូលដ្ឋានចំនួន៤២២ និង អ្នកស្ម័គ្រចិត្តនៅក្នុងបណ្តាញកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះនៅតាមមូលដ្ឋានចំនួន១៦៩បណ្តាញ។[122] កាកកាបាទក្រហមកម្ពុជាមានអ្នកស្ម័គ្រចិត្តចំនួន ៥០០នាក់ និង យុវជនស្ម័គ្រចិត្ត ១,០៥០។ [123] គ្រូនៅតាមសាលារៀនចំនួន ៣,៥០០នាក់ បង្រៀនការអប់រំអំពីមីន រួមទាំងសិស្សចំនួន ២៨,០០០នាក់ ដើរតួនាទី ជាគ្រូចុះតាមមូលដ្ឋានដើម្បីអប់រំក្មេងៗដែលមិនបានចូលរៀន និងឪពុក ម្តាយរបស់ពួកគេ ។ ពីថ្ងៃទី ១ ខែ កុម្ភៈ ដល់ ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៦ គ្រូបង្រៀនបឋមសិក្សាចំនួន ៣១១៨នាក់ ត្រូវបានបណ្តុះបណ្តាលអោយធ្វើការអប់រំអំពីគ្រោះថ្នាក់ដល់សិស្សតាមវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល ហើយគ្រូឧទ្ទេសចំនួន ៤,០០០នាក់ ទទួលបានការបណ្តុះបណ្តាលស្តីពីការអប់រំអំពីគ្រោះថ្នាក់មីន។ ទីភ្នាក់ងារអន្តរជាតិនានាដែលពាក់ពាន់នឹងការសំរបសំរួលសកម្មភាពមីន និង

---

[116] From a low of 46 women in 2003 the number rose to 83 in 2005. CMAA, "Mine Risk Education Strategic Plan, First Edition 2006," Phnom Penh, April 2006, p. 7. See section *Landmine/UXO Casualties*.
[117] CMVIS, "Reported mine/UXO casualties for the period of: January 2002 to December 2005," December 2005.
[118] CMAA, "Mine Risk Education Strategic Plan, First Edition 2006," Phnom Penh, April 2006, p. 1.
[119] Ibid, p. 6.
[120] UN, "2006 Portfolio of Mine Action Projects," p. 91.
[121] CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 3.
[122] CMAC, "Annual Report: January-December 2005," Phnom Penh, 2006, pp. 37, 40.
[123] Email from Nhar Ny, Advocacy/Monitor Officer, Jesuit Service Cambodia, 25 April 2006.

ការអប់រំអំពីមីនតាមសហគមន៏បានផ្តល់អ្នកជំនាញចំនួន ២៥នាក់ផ្សេងទៀត : HALO ( បីនាក់), MAG ( ១៨នាក់) និង World Vision ( ៤នាក់) ។[124]

អាជ្ញាធរមីនកម្ពុជាមានអ្នកសំរបសំរួលការអប់រំអំពីគ្រោះថ្នាក់មីនពេញម៉ោងម្នាក់ទទួលខុសត្រូវខាងផ្នែកសំរបសំរួលគ្រប់សកម្មភាពអប់រំអំពីគ្រោះថ្នាក់មីនទាំងអស់ក្នុងប្រទេសកម្ពុជា ដែលមានគោលបំណងធ្វើអោយប្រាកដថា ការអប់រំអំពីគ្រោះថ្នាក់មីនត្រូវបានគេដាក់បញ្ចូលជាមួយនឹងសកម្មភាពកំចាត់មីនជំនួយជនរងគ្រោះនិងការអភិវឌ្ឍសហគមន៏ ។[125]

ប្រទេសកម្ពុជាមិនបានដាក់បញ្ចូលសកម្មភាពអប់រំអំពីគ្រោះថ្នាក់មីននៅក្នុងទំរង់បែបបទទី១ នៃរបាយការណ៏មាត្រាទី ៧សំរាប់ឆ្នាំ ២០០៥ ឬឆ្នាំ ២០០៤ ឡើយ ។

អាជ្ញាធរមីនកម្ពុជាបានរាយការណ៏អោយដឹងថា ការអប់រំអំពីគ្រោះថ្នាក់មីននៅក្នុងប្រទេសកម្ពុជាត្រូវបានគេធ្វើឡើងតាមរយៈការបង្ហាញណែនាំដល់អ្នកភូមិដែលរងគ្រោះដោយសារមីន តាមរយៈអ្នកស្ម័គ្រចិត្តដែលផ្តល់ព័តិមានអប់រំអំពីគ្រោះថ្នាក់មីនដល់មិត្តភក្តិរបស់គេ តាមរយៈក្តាខៀនព័តិមាន ឃុតផ្សាយពាណិជ្ជកម្មតាមកញ្ចក់ទូរទស្សន៏ កម្មវិធីសិក្សាសំរាប់បណ្តុះបណ្តាលគ្រូនិងសាលាបឋមសិក្សា ព្រមទាំងផ្សព្វផ្សាយដល់ក្មេងៗដែលមិនបានចូលរៀនផងដែរ ។[126]

នៅក្នុងឆ្នាំ ២០០៥ អង្គការ CMAC បានបង្កើនយុទ្ធនាការឃោសនាតាមប្រព័ន្ធផ្សព្វផ្សាយព័តិមាន ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័តិមានរបស់ជាតិនិងក្តារខៀនព័តិមាននៅតាមខេត្តចំនួន ៨ ។[127] យុទ្ធនាការឃោសនា តាមប្រព័ន្ធផ្សព្វផ្សាយព័តិមានបានបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបើប្រៀបធៀបទៅនឹងឆ្នាំ ២០០៤ ដោយបានផ្សាយពាណិជ្ជកម្មតាមទូរទស្សន៏ចំនួន ៨០០ ឃុត និង តាមវិទ្យុចំនួន ១,៨០០ ឃុត តាមក្តារខៀនពាណិជ្ជកម្មចំនួន ១០ និងបិទផ្សាយដំណឹងថ្មីៗលើក្តារខៀនចំនួន ១០ ផ្សេងទៀត ។[128] អង្គការ CMAC ជឿជាក់ថាការផ្តល់ការអប់រំ អំពីគ្រោះថ្នាក់មីនតាមរយៈប្រព័ន្ធផ្សព្វផ្សាយមានប្រសិទ្ធភាពក្នុងការបញ្ជូនសារ ជាពិសេស ក្នុងខេត្តនានាដែលមានបញ្ហាគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះ ប៉ុន្តែមានសកម្មភាពកំចាត់មីនបន្តិចបន្តួច ។[129]

ក្រុមផ្សព្វផ្សាយការយល់ដឹងអំពីមីនចល័តចំនួន៦ក្រុម បានធ្វើទស្សនកិច្ចនៅភូមិចំនួន ៦៥៤ ភូមិ ដោយបានផ្សព្វផ្សាយការអប់រំអំពីគ្រោះថ្នាក់មីនទាំងថ្ងៃទាំងយប់ចំនួន ៨៥៥ លើក និងបានធ្វើទស្សនកិច្ចតាមផ្ទះចំនួន ៧៣,៨៣៦ នៅក្នុងឆ្នាំ២០០៥ ។ ជាលទ្ធផលនៃដំណើរទស្សនកិច្ចទាំងនេះរបាយកាណ៏ស្តីពីគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះចំនួន ១,០៥៣ ករណី ត្រូវបានគេបញ្ជូនទៅកាន់អង្គការប្រតិបត្តិករដោះមីននានា ហើយគ្រាប់មីនចំនួន ៤៣៨ គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះចំនួន៩,២០១គ្រាប់ត្រូវបានកំទេចចោល ។[130] ក្រុមនានារបស់អង្គការ CMAC បានផ្សព្វផ្សាយការអប់រំអំពីគ្រោះថ្នាក់

---

[124] Mine Action Support Group, "MASG Newsletter-First Quarter of 2006," Washington DC, 1 May 2006, p. 22.
[125] CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 1.
[126] CMAA, "Mine Risk Education Strategic Plan, First Edition 2006," Phnom Penh, April 2006, pp. 7-8.
[127] CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 2.
[128] Mine Action Support Group, "MASG Newsletter-First Quarter of 2006," Washington DC, 1 May 2006, p. 22; CMAC, "Annual Report: January-December 2005," Phnom Penh, 2006, pp. 36-37.
[129] See *Landmine Monitor Report 2005*, p. 221.
[130] CMAC, "Annual Report: January-December 2005," Phnom Penh, 2006, p. 36.

មីន ដល់អ្នកចូលរួមចំនួនសរុបដល់ទៅ ២៩៨,២០៨ នាក់ នៅក្នុងឆ្នាំ ២០០៥ ។[131]

គំរោងអប់រំស្តីពីមីនរបស់កាកកាបាទក្រហមកម្ពុជានៅតាមមូលដ្ឋាន ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០០ បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់មីនដល់ប្រជាជនចំនួន ១៦,៤០៨ និង សិស្សានុសិស្សចំនួន ២,៦៦៨ នាក់ក្នុងឃុំចំនួន ១៨៣ ឃុំក្នុង ៦ ខេត្ត នៅក្នុងឆ្នាំ ២០០៥ ។[132] គំរោងនោះបានទទួលការគាំទ្រពី កាកកាបាទក្រហមអូស្ត្រាលី ។[133]

ប្រតិបត្តិការបោសសំអាតមីនរបស់អង្គការ HALO ក្នុងឆ្នាំ ២០០៥ ត្រូវបានគាំទ្រដោយក្រុមអប់រំអំពីគ្រោះថ្នាក់មីន ដែលមានគ្នាបីនាក់ ដែលមានភារកិច្ចផ្សព្វផ្សាយការអប់រំអំពីគ្រោះថ្នាក់មីន ក្នុងខណៈពេលដែលគេកំពុងដំណើរការបោសសំអាតមីន ។ ការផ្សព្វផ្សាយទាំងនោះត្រូវបានធ្វើនៅតាមសាលារៀននិងផ្សាយដល់ក្រុមកុមារនិងមាតា នៅពេលថ្ងៃ និង ដល់បុរសៗនៅពេលយប់ ។ ក្រុមនេះបានប្រើប្រាស់វិធីបញ្ចាំងវីដេអូដែលមានខ្លឹមសារទាក់ទិននឹងបញ្ហាសុខភាព និងកសិកម្មផងដែរ ព្រមទាំងប្រើវិធីអោយមានការចូលរួមសួរដេញដោលទៅវិញទៅមកពីទស្សនិកជនផងដែរ ។ ក្នុងអំឡុងឆ្នាំ ២០០៥ ក្រុមនេះបានផ្សព្វផ្សាយដល់អ្នកស្រុកក្នុងឃុំដែលរងគ្រោះដោយសារគ្រាប់មីនចំនួន ២៦,៧១៥ នាក់ ច្រើនជាងនៅក្នុងឆ្នាំ ២០០៤ បន្តិច ។[134]

ការអប់រំអំពីគ្រោះថ្នាក់មីនគឺជាផ្នែកមួយនៃកម្មវិធីសិក្សារបស់ជាតិ ។ នៅក្នុងឆ្នាំ ២០០៥ គ្រូបង្រៀនប្រមាណ ៣,៥០០ នាក់បានផ្តល់ការផ្សព្វផ្សាយនៅក្នុងសាលារៀនចំនួន ៩៩៦ សាលា ដែលស្ថិតនៅក្នុងសហគមន៍ដែលរងគ្រោះដោយសារគ្រាប់មីនខ្លាំងជាងគេបំផុត ដល់សិស្សសាលាបឋមសិក្សាចំនួនប្រមាណ ២៧៥,០០០ នាក់ ។ លើសពីនេះទៅទៀត សិស្សដែលបានបណ្តុះបណ្តាលរួចចំនួន ២៨,០០០ នាក់ បានផ្សព្វផ្សាយការអប់រំអំពីគ្រោះថ្នាក់មីនដល់ក្មេងៗក្រៅសាលាចំនួន ៨៥,២១២ នាក់ព្រមទាំងដល់ឪពុកម្តាយរបស់ពួកគេផង ។ ចំនួនគ្រូបានធ្លាក់ចុះពីជិត ៤,៨០០ នាក់នៅក្នុងឆ្នាំ ២០០៤ ប៉ុន្តែចំនួនសិស្សដែលត្រូវបានផ្សព្វផ្សាយមានការកើនឡើងគួរអោយកត់សំគាល់ដល់ទៅ ៥,០១០នាក់ បើប្រៀប-ធៀបនឹងឆ្នាំ២០០៤ ។ ចំនួនសិស្សដែលបានទទួលការផ្សព្វផ្សាយបានកើនឡើងទាំងក្មេងបានចូលរៀននិងក្មេងមិនបានចូលរៀន ។[135]

ការទំនាក់ទំនងសហគមន៍ត្រូវបានគេចាត់ទុកជាវិធីមួយដ៏មានប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់នៅកម្ពុជា ។ អាជ្ញាធរមីនកម្ពុជា យល់ឃើញថាប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ដែលរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះនានាបានយល់ដឹងអំពីគ្រោះថ្នាក់ ដូច្នេះហើយគួរតែត្រូវបានគេអនុញ្ញាតអោយចូលរួមក្នុងការកំណត់នូវគ្រោះថ្នាក់ និងការបង្កើតយុទ្ធសាស្ត្រជំនួសផ្សេងៗ ។ អង្គការ CMAC ចាប់ដំណើរការនូវគំរោងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះនៅតាមសហគមន៍ក្នុងឆ្នាំ ២០០២ គំរោងនេះបង្កើតបាននូវបណ្តាញអ្នកតំណាងតាមមូលដ្ឋាន

131 CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 2.
132 Ibid, p. 3; UNICEF, "Mine/UXO risk education in Cambodia," powerpoint presentation for Landmine Monitor Global Research meeting, Phnom Penh, 3 April 2006; Cambodian Red Cross, "Community Based Landmine/UXO Risk Education Program Annual Report 2005."
133 CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 3.
134 HALO, "Annual Report 2005," p. 4; CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 3.
135 CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 2; UNICEF, "Mine/UXO risk education in Cambodia," powerpoint presentation for Landmine Monitor Global Researchers meeting, Phnom Penh, 3 April 2006.

ដើម្បីជំរុញ អោយសហគមន៍ដែលរងគ្រោះចូលរួមក្នុងការធ្វើផែនការនិងការកំណត់អាទិភាពសកម្មភាពមីន និងក្នុងការផ្តល់ការអប់រំអំពីគ្រោះថ្នាក់មីន។[136]

នៅក្នុងឆ្នាំ ២០០៥ វិធីសាស្ត្រនេះត្រូវបានគេអនុវត្តនៅក្នុងស្រុកដែលរងគ្រោះដោយសារគ្រាប់មីនខ្លាំងជាងគេចំនួន ១៨ ក្នុងខេត្តចំនួនប្រាំ ( បាត់ដំបង បន្ទាយមានជ័យ ក្រុងប៉ៃលិន និង បន្ថែមទៀតក្នុងឆ្នាំ ២០០៥ គឺពោធិសាត់ និងឧត្តមានជ័យ)។ អ្នកស្ម័គ្រចិត្តនៅក្នុង ៣១៩ ភូមិ ( ជាកំណើនមួយគួរអោយកត់សំគាល់ពីចំនួន ៩៩ ភូមិក្នុងឆ្នាំ ២០០៤) ត្រូវបានជួយជ្រោមជ្រែង និងត្រួតពិនិត្យដោយអ្នកសំរបសំរួលថ្នាក់ស្រុក១៨ នាក់គិតត្រឹមខែមិថុនា ឆ្នាំ ២០០៦ មន្ត្រីត្រួតពិនិត្យនិងបណ្តុះបណ្តាលរបស់ CMAC ប្រចាំខេត្តពីរនាក់ជួយមើលការខុសត្រូវអ្នកសំរបសំរួលថ្នាក់ស្រុក។[137] រៀងរាល់បួនខែម្តង កិច្ចប្រជុំត្រួតពិនិត្យឡើងវិញត្រូវបានគេរៀបចំក្នុងស្រុកនីមួយៗ ផែនទីភូមិចំនួន ៣១៩ ត្រូវបានគេធ្វើការកែសំរួលជាប្រចាំទៅតាមព័ត៌មាននិងសមិទ្ធផលដែលសំរេចបាន ។ គេបានផ្តល់ការអប់រំអំពីគ្រោះថ្នាក់មីនដល់អ្នកភូមិចំនួន ១៣៦,២២៤ នាក់ រួមទាំងការធ្វើទស្សនកិច្ចតាមផ្ទះចំនួន ៥២,៨៣៣ ផង។ គេប្រើប្រាស់បច្ចេកទេសចូលរួម (Participatory Techniques)ដើម្បីកំណត់ទំហំនៃផលប៉ះពាល់របស់គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះនៅក្នុងភូមិគោលដៅនីមួយៗ ព័ត៌មាននេះត្រូវបានបញ្ជូនទៅកាន់ CMVIS និង MAPU។ នៅពេលគេកំណត់បានតំបន់ដែលត្រូវជួយបានភ្លាម គេក៏ស្នើសុំសេវាអប់រំអំពីមីនសមស្របភ្លាមដែរ ។ ជាលទ្ធផលសកម្មភាពបោសសំអាត ១,៤៨៦ ករណី ត្រូវបានគេរាយការណ៍អោយទៅទីភ្នាក់ងារដោះមីន ដោយបានបោសសំអាតមីនចំនួន ២,៧៩៤ គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះចំនួន ៧,២៦០ គ្រាប់ ហើយផ្ទៃដីចំនួន២,៧៩២,៦២៩ ម៉ែត្រការេ ត្រូវបានបោសសំអាត( ៩៤៥,២៣៤ម៉ែត្រការេនៅក្នុងឆ្នាំ២០០៤ ) ។[138]

អង្គការ CMAC បានប្រើប្រាស់វិធីសាស្ត្រស្រដៀងគ្នានៅក្នុងគំរោងរបស់ខ្លួនអំពីការកាត់បន្ថយគ្រោះថ្នាក់មីន និងគ្រាប់មិនផ្ទុះតាមមូលដ្ឋាន ក្នុងខេត្តចំនួន ៤ ដែលពីមុនស្ថិតក្នុងភាពគ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះ ( ខេត្តកណ្តាល កំពង់ស្ពឺ ព្រៃវែង និងស្វាយរៀង)។[139] អ្នកសំរបសំរួលតាមស្រុកចំនួន ១៣នាក់ ត្រូវបានគេដាក់ពង្រាយនៅក្នុងឆ្នាំ ២០០៥ សំរាប់១,៥៩១ភូមិ។ ការអប់រំអំពីគ្រោះថ្នាក់នៃគ្រាប់មិនទាន់ផ្ទុះត្រូវបានគេផ្តល់ដល់អ្នកភូមិចំនួន ៤៦,១២១នាក់ ក្នុង ១,២០៩ វគ្គផ្សព្វផ្សាយ និង ៨,៧៨៧ ទស្សនកិច្ចតាមផ្ទះ, គេបានរាយការណ៍អោយទីភ្នាក់ងារដោះមីននូវសកម្មភាពកំចាត់មីនចំនួន១,១៩៦ករណី ដែលបានដោះមីនចំនួន ៥២៩គ្រាប់ និងគ្រាប់មិនទាន់ផ្ទុះចំនួន១២,០៧៨ គ្រាប់។[140]

អង្គការ MAG និងអង្គការ World Vision ក៏បានប្រើធនធានមនុស្សនៅតាមមូលដ្ឋានដើម្បីប្រមូលផ្តុំប្រជាជនអប់រំនិងគាំទ្រគំរោងតាមមូលដ្ឋាន។ នៅក្នុងឆ្នាំ២០០៥ អង្គការ MAG បានដាក់ពង្រាយក្រុមទំនាក់ទំនងតាមសហគមន៍ចំនួន ៨ ក្រុម ( ក្រុមនីមួយៗមានគ្នា ២ នាក់) មានបីក្រុមនៅក្នុងឆ្នាំ ២០០៤ ។ ក្រុមទាំងនោះដើរតួនាទីជា "ស្ពាន

---

[136] CMAA, "Mine Risk Education Strategic Plan, First Edition 2006," Phnom Penh, April 2006, p. 5.
[137] CMAC, "Mine Action Tools, Community Based Mine Risk Reduction (CBMRR) Project," Phnom Penh, 2006.
[138] CMAC, "Annual Report: January-December 2005," Phnom Penh, 2006, pp. 37-38; CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 2; CMAC, "Annual Report 2004," 28 April 2005, p. 8; email from Chan Rotha, Director, Department of Socio-Economic Planning and Database, CMAA, 24 June 2005.
[139] CMAC, "Annual Report 2005," Phnom Penh, 2006, p. 40.
[140] Ibid.

ទំនាក់ទំនងជាមួយប្រជាពលរដ្ឋរងគ្រោះ ........... គេបានធ្វើការវាយតំលៃមុនពេលធ្វើការបោសសំអាតមីនដើម្បីបង្ហាញពីស្ថានភាពសេដ្ឋកិច្ចសង្គមនៅតំបន់នោះ ក្នុងពេលជាមួយគ្នានោះដែរគេក៏ប្រមូលព័ត៌មាន ដែលត្រូវប្រើប្រាស់សំរាប់កំណត់អាទិភាពតំបន់ដែលត្រូវបោសសំអាត។ នៅពេលដែលកន្លែងមួយត្រូវបានបោសសំអាតមីនរួចភ្លាមក្រុមទំនាក់ទំនងសហគមន៍ អាចធ្វើការវាយតំលៃដោយប្រៀបធៀបក្រោយពេលសំអាតបាន ដែលតាមរយៈការវាយតំលៃនោះ គេអាចបង្ហាញអោយឃើញពីអាំងឌីកាទ័រទាក់ទិននឹងផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច....។ វិធីមួយក្នុងការវាស់វែងអំពីបញ្ហានេះ គឺគេគិតតាមរយៈចំនួនមនុស្សដែលអាចប្រើប្រាស់ធនធានសហគមន៍បានដោយសុវត្ថិភាព ដូចជា អណ្តូងទឹក សាលារៀន មន្ទីរពេទ្យ និងកន្លែងសក្ការៈបូជា "។[141] នៅក្នុងឆ្នាំ ២០០៥ ប្រជាពលរដ្ឋចំនួន ៦៣,១៨៦ បានចូលរួមក្នុងការអប់រំ ផ្សព្វផ្សាយអំពីគ្រោះថ្នាក់មីនធ្វើឡើងដោយអង្គការ MAG។[142]

អង្គការ World Vision បានផ្តល់ការអប់រំអំពីគ្រោះថ្នាក់មីនជាផ្នែកមួយនៃសកម្មភាពខាងកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួន ។ អង្គការមានក្រុមការងារពីរក្រុមធ្វើការតាមភូមិ "ដើម្បីសាកសួរអំពីគ្រោះថ្នាក់មីន និងផ្តល់ដំបូន្មានដល់អ្នកភូមិក្នុងការការពារខ្លួន "។ នៅក្នុងឆ្នាំ ២០០៥ ក្រុមទាំងនោះបានផ្តល់ការអប់រំអំពីគ្រោះថ្នាក់មីនដល់អ្នកភូមិចំនួន ១៤,៤៩២ នាក់ ច្រើនជាងឆ្នាំ ២០០៤ ជិតបីដង។[143]

ពីខែកុម្ភៈឆ្នាំ ២០០៥ ដល់ខែមិនា ឆ្នាំ ២០០៦ អង្គការ UNICEF បានផលិតសំភារៈអប់រំអំពីគ្រោះថ្នាក់មីនចំនួន ១០០,០០០។[144] អនុវត្តតាមការត្រួតពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រអប់រំអំពីគ្រោះថ្នាក់មីនរបស់ប្រទេស កម្ពុជា អង្គការ UNICEF បានផ្តល់ការគាំទ្រដល់ការផលិតនិងការចែកចាយនូវផ្ទាំងរូភាពអប់រំអំពីគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះថ្មីៗជាច្រើន។ អង្គការ UNICEF បានបន្តគាំទ្រដល់ការសំរបសំរួលរបស់ CMAA ស្តីពីការអប់រំអំពីគ្រោះថ្នាក់មីន ការអប់រំអំពីគ្រោះថ្នាក់មីននៅតាមសាលារៀនតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និង សកម្មភាពអប់រំអំពីគ្រោះថ្នាក់មីននានារបស់ CMAC។[145]

នៅក្នុងឆ្នាំ ២០០៥ អង្គការ UNICEF បានគាំទ្រដល់ក្រុមពហុជំនាញ (ផ្សំបញ្ចូលគ្នារវាងការយល់ដឹងអំពីមីន និង EOD ) ដែលរួមគ្នាបង្កើតឡើងដោយអង្គការ UNICEF និង CMAC ដើម្បីចាត់វិធានការជាមួយនឹងគ្រាប់មិនទាន់ផ្ទុះដែលសហគមន៍បានរាយការណ៍ និងអនុញ្ញាតអោយបំផ្លាញគ្រាប់មីននិងគ្រាប់មិនផ្ទុះជាបន្ទាន់ បន្ទាប់ពីវគ្គអប់រំអំពីគ្រោះថ្នាក់មីននីមួយៗ ។ នៅក្នុងអតីតកាល ការកំទេចមីនចោលត្រូវបានធ្វើឡើងក្នុងរយៈពេល ពីរទៅបីសប្តាហ៍បន្ទាប់ពីការប្រជុំអប់រំអំពីគ្រោះថ្នាក់មីន។[146]

នៅក្នុងឆ្នាំ ២០០៦ CMVIS បានបន្ថែមសកម្មភាពអប់រំអំពីគ្រោះថ្នាក់មីនដើម្បីជួយកាត់បន្ថយឧបទ្ទវហេតុគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះ។ គេបានផ្តោតការយកចិត្តទុកដាក់ទៅលើសហគមន៍ដែលមានឧបទ្ទវហេតុថ្មីៗកើតឡើង និងទៅ

---

[141] Email from Rupert Leighton, MAG, Cambodia, 1 February 2006.
[142] CMAA, "Summary of 2005 Annual Mine Risk Education Report," Phnom Penh, 2006, p. 3.
[143] World Vision, "Cambodia," www.wvi.org, accessed 12 April 2006.
[144] CMAC, "Annual Report: January-December 2005," Phnom Penh, 2006, pp. 36-37.
[145] Email from Chhaya Plong, Assistant Project Officer, Accidents, Injuries and Disabilities, UNICEF Cambodia, 10 July 2006.
[146] Ibid.

លើការសហការជាមួយអង្គការប្រតិបត្តិករដោះមីននានា ដែលបានស្នើសុំការអប់រំអំពីគ្រោះថ្នាក់មីនសំរាប់តំបន់ដែលមានគ្រោះថ្នាក់ច្រើន។ ក្នុងពេលសិក្ខាសាលាប្រចាំឆ្នាំរបស់ CMVIS នាខែ ធ្នូ ឆ្នាំ ២០០៥ អង្គការ CMAC បានបណ្តុះបណ្តាលអ្នកប្រមូលព័ត៌មានចំនួន ១៥ នាក់ អ្នកស្ម័គ្រចិត្ត ៥ នាក់ និងបុគ្គលិកគ្រប់គ្រងទិន្នន័យ ៤ នាក់ក្នុងរយៈពេល ១ ថ្ងៃ ។ សកម្មភាពអប់រំអំពីគ្រោះថ្នាក់មីនបានចាប់ផ្តើមឡើងក្នុងខែ មករា ឆ្នាំ ២០០៦ ។ នៅត្រឹមខែ មេសា ប្រជាជនចំនួនជាង ១៥៧៣ នាក់បានទទួលព័ត៌មានអប់រំអំពីគ្រោះថ្នាក់មីនពីអ្នកប្រមូលព័ត៌មាន និងអ្នកស្ម័គ្រចិត្តរបស់ CMVIS ។[147]

ការសិក្សាមួយអំពីការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពមីន ដែលត្រូវបានបោះពុម្ពផ្សាយក្នុងខែ ធ្នូ ឆ្នាំ ២០០៥ មាន ៣ ជំពូក ស្តីពីការអប់រំអំពីគ្រោះថ្នាក់មីននៅក្នុងប្រទេសកម្ពុជា ដោយបានសង្ខេបនូវចំនុចខ្លាំងនិងចំនុចខ្សោយរបស់វិធីសាស្ត្រអប់រំតាមសហគមន៍របស់ CMAC និង MAG ។ ចំនុចខ្លាំង នៃវិធីសាស្ត្ររបស់អង្គការ MAG ដែលគេបានកត់សំគាល់គឺជាការយោគយល់គ្នាកាន់តែប្រសើរឡើងរវាងក្រុមដោះមីនជាមួយប្រជាពលរដ្ឋ ប៉ុន្តែវិធីសាស្ត្រទំនាក់ទំនងសហគមន៍ហាក់ដូចជាមានលក្ខណៈបណ្តោះអាសន្ន (ឆាប់ពេក) គឺមិនស្ថិតស្ថេររហូតដល់ក្រោយពេលដោះមីនរួច. វាអាចស៊ីពេលវេលាច្រើន......វាជាដំណើរការពិគ្រោះយោបល់ជាជាងដំណើរការកសាងសមត្ថភាពនៅមូលដ្ឋាន" ។ វិធីសាស្ត្ររបស់ CMAC ចំណាយធនធានតិចហើយអាចគ្របដណ្តប់លើវិសាលភាពធំទូលាយ អភិវឌ្ឍសមត្ថភាពនៅមូលដ្ឋាន និងជំរុញអោយមានការចូលរួមសំរេចចិត្តពីមូលដ្ឋាន វិធីសាស្ត្រទាំងនេះផ្តល់នូវការឃ្លាំមើលជាអចិន្ត្រៃយ៍ និងលើកកំពស់សមាហរណកម្មរវាង សកម្មភាពមីន ការអភិវឌ្ឍ និងសេវាជនពិការ ។ ប៉ុន្តែវាហាក់ដូចជាមិនសូវមានលក្ខណៈស៊ីជំរៅ ពោលគឺវាគ្រាន់បើជាងការប្រមូលព័ត៌មានគ្រឹះ និងការទំនាក់ទំនងសហគមន៍ធម្មតាៗបន្តិចប៉ុណ្ណោះ និងទាមទារអោយមានការបណ្តុះបណ្តាលអ្នកសំរបសំរួលថ្នាក់ស្រុកបន្ថែមទៀត" សកម្មភាពមីន និងទីភ្នាក់ងារអភិវឌ្ឍន៍នានាមាន អណត្តិ និងរបៀបវារៈរបស់ខ្លួន ហើយមិនឆ្លើយតបជានិច្ចកាលទៅនឹងសំណូមពរសុំជំនួយទាំងអស់ពីសហគមន៍នោះទេ ។[148]

## ការផ្តល់មូលនិធិ និងជំនួយសំរាប់សកម្មភាពមីន

គេបានរាយការណ៍អោយដឹងពីការផ្តល់មូលនិធិសំរាប់សកម្មភាពមីននៅកម្ពុជាក្នុងឆ្នាំ ២០០៥ ថាមានចំនួនសរុប ២៥.៦លានដុល្លារ រួមទាំងវិភាគទានរបស់រដ្ឋាភិបាល ។ ប្រទេសចំនួន ១៤ បានរាយការណ៍ថាបានរួមចំណែកទឹកប្រាក់ចំនួន $23,869,623 ។ នេះគឺជាការធ្លាក់ចុះគួរអោយកត់សំគាល់ធៀបនឹងឆ្នាំ ២០០៤ (41.7 លានដុល្លារផ្តល់ដោយប្រទេសចំនួន ១៣ និងសហគមន៍អឺរ៉ុប ) ។[149] ប្រទេសផ្តល់ជំនួយក្នុងឆ្នាំ ២០០៥ មានៈ

- អូស្ត្រាលីៈ A$4,250,494 (ស្មើនឹង $3,241,852 ដុល្លារអាមេរិក), រួមមាន A$400,000 ($305,080) អោយទៅ CMAC, A$2 million ($1,525,400) អោយទៅ UNDP, A$500,000 ($381,350) សំរាប់គំរោង the Clearing for Results project ដែលបានមកពីមូលនិធិជំនួយជនរងគ្រោះដោយសារមីន 'Landmine Victim Assistance

[147] Emails from Chhiv Lim, CMVIS, 27 April and 2 May 2006.
[148] Ruth Bottomley, "Community Participation in Mine Action, A Review and Conceptual Framework," NPA, Phnom Penh/Oslo, December 2005, pp. 30-35.
[149] See *Landmine Monitor Report 2005*, p. 224.

Fund’, A$46,192 ($35,231) សំរាប់សិក្សាយុទ្ធសាស្រ្តកសាងជាតិឡើងវិញ, A$318,000 ($242,539) អោយទៅ ICRC សំរាប់ស្តារកាយសម្បទា និងផ្តល់មូលនិធិ ដែលមានទឹកប្រាក់ A$368,781 ($281,269) អោយទៅ AUSTCARE, A$298,149 ($227,398) អោយទៅ CARE Australia, A$5,049 ($3,851) អោយទៅ World Vision និង A$314,323 ($239,734) អោយទៅ World Vision ក្នុងសកម្មភាពកំចាត់មីនចំរុះនិងការបញ្រ្ជាប យេនឌ័រ ។[150]

- បែលហ្សិក: €261,223 (ស្មើនឹង $325,197 ដុល្លារអាមេរិក) អោយទៅ Handicap International រួមមាន €178,500 ($222,215) សំរាប់ជំនួយអ្នកនៅរស់ពីគ្រោះថ្នាក់ និង €82,723 ($102,982) សំរាប់ការបង្កាពិការភាព ។[151]
- កាណាដា : C$3,070,188 (ស្មើនឹង $2,534,204 ដុល្លារអាមេរិក), រួមមាន C$228,388 ($188,517) អោយទៅ Oxfam Quebec សំរាប់បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មជនរងគ្រោះដែលនៅរស់, C$390,866 ($322,630) អោយទៅ World Vision សំរាប់សកម្មភាពកំចាត់មីនចំរុះ, C$2 million ($1,650,846) អោយទៅ UNDP សំរាប់សកម្មភាពកំចាត់មីន, C$64,000 ($52,827) ឧបត្ថម្ភគំរោងរបស់ UNDP “the UNDP Clearing for Results project”, C$284,583 ($234,901) អោយទៅអង្គការ Geospatial Cambodia សំរាប់ការធ្វើផែនការ និងការវាយតំលៃភារកិច្ច និង C$102,351 ($84,483) អោយទៅអង្គការ MAG សំរាប់ក្រុម EOD ។[152]
- ហ្វាំងឡង់: €1,020,000 (ស្មើនឹង $1,269,798 ដុល្លារអាមេរិក), រួមមាន €670,000 ($834,083) អោយទៅ HALO សំរាប់បោសសំអាតមីន, €100,000 ($124,490) អោយទៅ HI សំរាប់ប្រមូលទិន្នន័យគ្រោះថ្នាក់ និង €250,000 ($311,225) អោយទៅ FinnChurchAid សំរាប់បោសសំអាតមីន ។[153]
- បារាំង: €200,000 (ស្មើនឹង $248,980 ដុល្លារអាមេរិក) អោយទៅ CMAC ។[154]
- អាល្លឺម៉ង់: €663,000 (ស្មើនឹង $825,369 ដុល្លារអាមេរិក) អោយទៅ CMAA/CMAC សំរាប់ដោះមីន ។[155]
- ជប៉ុន: ¥498,757,592 (ស្មើនឹង $4,529,632 ដុល្លារអាមេរិក) រួមមាន ¥221,738,423 ($2,013,791) អោយទៅ CMAC សំរាប់បោសសំអាតមីន, ¥62,244,040 ($565,290) អោយទៅ JMAS សំរាប់ EOD, ¥58,055,690 ($527,252) អោយទៅ MAG, ¥73,976,540 ($671,842) អោយទៅ MAG សំរាប់យានជំនិះនិងឧបករណ៏ដោះមីន, ¥68,150,547 ($618,931) អោយទៅ HALO សំរាប់បោសសំអាតមីន , ¥592,352 ($5,380) អោយទៅ គណៈកម្មាធិការផលិតឧបករណ៏ដាក់សំគាល់ចំការមីនក្រុងប៉ៃលិន និង ¥14,000,000 ($127,146) សំរាប់ការវាស់ស្ទង់

[150] Email from Katheryn Bennett, AusAID, 30 June 2006. A$1 = US$0.7627. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2006. The UNDP Clearing for Results project started in 2006.
[151] Email from Stan Brabant, Head, Policy Unit, HI, 26 May 2006; email from Dominique Jones, Conseiller, Ministry of Defence, 17 May 2006.
[152] Mine Action Investments database; email from Carly Volkes, DFAIT, 7 June 2006. Average exchange rate for 2005: US$1 = C$1.2115. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2006. The UNDP Clearing for Results project started in 2006.
[153] Mine Action Investments database; email from Rita Helmich-Olesen, Ministry of Foreign Affairs, 31 March 2006. Average exchange rate for 2005: US$1 = DKK5.9953. US Federal Reserve, “List of Exchange Rates (Annual),” 3 January 2006.
[154] France Article 7 Report, Form J, 26 April 2006; CCW Amended Protocol II Article 13 Report, Form E, 6 October 2005.
[155] Germany Article 7 Report, Form J, 27 April 2006; Mine Action Investments database.

តំរូវការរបស់ជនពិការរួមទាំងជនរងគ្រោះដែលនៅរស់ ។[156]

- លុចហ្សមបួ: €50,000 (ស្មើនឹង $62,245 ដុល្លារអាមេរិក) អោយទៅ HI សំរាប់ជួយជនរងគ្រោះដែលនៅរស់ ។[157]
- ហូឡង់ (Netherlands): €1,243,526.00 (ស្មើនឹង $1,548,066 ដុល្លារអាមេរិក), រួមមាន €643,526 ($801,126) អោយទៅ HALO សំរាប់បោសសំអាតមីននិងការអប់រំអំពីគ្រោះថ្នាក់មីន និង €600,000 ($746,940) អោយទៅអង្គការ Norwegian People's Aid សំរាប់កសាងសមត្ថភាព ។[158]
- ញូវ៉ែលសេឡង់: NZ$340,629 (ស្មើនឹង $240,109 ដុល្លារអាមេរិក) អោយទៅអង្គការ Cambodia Trust សំរាប់សាលា SPO ។[159]
- ណ័រវេស: NOK2,812,200 (ស្មើនឹង $436,596 ដុល្លារអាមេរិក), រួមមាន NOK1,312,200 ($203,720) អោយទៅ NPA សំរាប់កម្មវិធីផ្តល់ទីប្រឹក្សាបច្ចេកទេសរបស់ CMAC និង NOK1,500,000 ($232,876) អោយទៅអង្គការ UNDP សំរាប់បោសសំអាតមីន ។[160]
- ស៊ុយអែដ : SEK3,800,000 (ស្មើនឹង $508,633 ដុល្លារអាមេរិក) អោយទៅ UNDP សំរាប់បោសសំអាតមីន និងឆ្កែរាវមីនរបស់ CMAC ។[161]
- ចក្រភពអង់គ្លេស: £645,023 (ស្មើនឹង $1,173,942 ដុល្លារអាមេរិក) សំរាប់ការដោះមីនចំរុះ, រួមមាន £378,156 ($688,244) អោយទៅ MAG, £33,000 ($60,060) អោយទៅ CMVIS និង £233,867 ($425,638) អោយទៅ HALO ។[162]
- សហរដ្ឋអាមេរិក: $6,925,000, រួមមាន $3,920,000 បានមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក, $180,000 បានមកពីក្រសួងការពារជាតិសហរដ្ឋអាមេរិក និង $2,825,000 បានមកពីមូលនិធិ Leahy War Victims Fund ។[163]

លើសពីនេះទៅទៀតអង្គការ Adopt-A-Minefield បានចូលរួមវិភាគទានទឹកប្រាក់ចំនួន $975,945 ($508,157 អោយទៅ CMAC សំរាប់បោសសំអាតមីន និងសំរាប់ជួយជនរងគ្រោះដែលនៅរស់ $100,087 អោយទៅ Cambodia Trust, $117,100 អោយទៅអង្គការ Clear Path International, $68,100 អោយទៅមជ្ឈមណ្ឌលជាតិសំរាប់ជនពិការ, $62,500 អោយទៅអង្គការ Operations Enfants de Battambang, $40,000 អោយទៅមូលនិធិ Vietnam Veterans of

---

[156] Emails from Kitagawa Yasu, Japan Campaign to Ban Landmines (JCBL), March-May 2006, with translated information received by JCBL from Multilateral Cooperation Department, 11 May 2005, and Non-proliferation and Science Department, 11 April 2006. Average exchange rate for 2005: US$1= ¥110.11. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2006.
[157] Email from François Berg, Ministry of Foreign Affairs, Luxembourg, 30 March 2006.
[158] Email from Ellen Schut, Ministry of Foreign Affairs, 7 April 2006; email from Brechtje Paardekooper, Ministry of Foreign Affairs, 18 April 2006.
[159] Email from Helen Fawthorpe, Ministry of Foreign Affairs, 6 June 2006; email from Megan McCoy, Ministry of Foreign Affairs, 6 June 2006. Average exchange rate for 2005: NZ$1 = US$0.7049. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2006.
[160] Email from Annette A. Landell-Mills, Ministry of Foreign Affairs, 21 June 2006. Average exchange rate for 2005: US$1 = NOK6.4412. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2006.
[161] Sweden Article 7 Report, Form J, 2 May 2006; emails from Sara Brandt-Hansen, Ministry of Foreign Affairs, March-May 2006. Average exchange rate for 2005: US$1 = SEK7.4710. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2006.
[162] Email from Andrew Willson, Department for International Development, 20 March 2006. Average exchange rate for 2005: £1 = US$1.820. US Federal Reserve, "List of Exchange Rates (Annual)," 3 January 2006.
[163] USG Historical Chart containing data for FY 2005, by email from Angela L. Jeffries, Financial Management Specialist, US Department of State, 8 June 2006.

America Foundation និង $80,000 អោយទៅ World Rehabilitation Fund) ។[164]

រដ្ឋាភិបាល អង្គការមនុស្សធម៌ និងប្រភពឯកជននានាក្នុងប្រទេសកម្ពុជា ក៏បានផ្តល់មូលនិធិសំរាប់សកម្មភាពមីនផងដែរ។ រដ្ឋាភិបាលបែងចែកវិភាគទានប្រចាំឆ្នាំចំនួន $800,000 ក្នុង១ ឆ្នាំ។ នៅក្នុងឆ្នាំ ២០០៥ ទឹកប្រាក់ចំនួន $200,000 ត្រូវបានប្រគល់ទៅអោយ CMAA , $250,000 អោយទៅ CMAC, $250,000 អោយទៅកងយោធពលខេមរភូមិន្ទ និង $100,000 អោយទៅក្រសួងសង្គមកិច្ចសំរាប់ជួយជនរងគ្រោះដែលនៅរស់។[165] រដ្ឋាភិបាល ក៏បានរួមចំណែកក្នុងសកម្មភាពកំចាត់មីនក្រោមកម្មវិធីពហុភាគីនានា ដោយប្រើប្រាស់ជំនួយអភិវឌ្ឍន៍តាមរយៈមូលនិធិសមភាគី។ នៅក្នុងឆ្នាំ២០០៥ ទឹកប្រាក់ចំនួន ២ លានដុល្លា បានមកពីមូលនិធិសមភាគីជាមួយធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់គំរោងស្តារហេដ្ឋារចនាសម្ព័ន្ធជនបទត្រូវបានប្រើប្រាស់សំរាប់បោសសំអាតមីន។[166]

អង្គការ CMAC បានចំណាយទឹកប្រាក់ចំនួន $8,778,742 នៅក្នុងឆ្នាំ២០០៥ ។ ចំនួននេះតិចជាងទឹកប្រាក់ក្នុងឆ្នាំ ២០០៤ បន្តិចគឺ $8,783,904 ។[167]

អង្គការ CMAC បានរាយការណ៍អោយដឹងថា ខ្លួនបានទទួលជំនួយដែលមានទឹកប្រាក់សរុបចំនួន $9,181,181 នៅក្នុងឆ្នាំ ២០០៥ ($3,083,765 បានមកពី UNDP; $5,867,942 បានមកពីអ្នកផ្តល់ជំនួយទ្វេភាគី និង $229,474 បានមកពីរដ្ឋាភិបាល) ។ ចាប់តាំងពីឆ្នាំ ២០០១ មក វិភាគទានរបស់អង្គការ UNDP ទៅអោយ CMACបានធ្លាក់ចុះ (៦៤ ភាគរយនៃការផ្តល់មូលនិធិដល់ CMAC នៅឆ្នាំ ២០០១, ៤៨ ភាគរយ នៅក្នុងឆ្នាំ ២០០៤, និង ៣៣ ភាគរយ នៅក្នុងឆ្នាំ ២០០៥) ហើយវិភាគទានទ្វេភាគីបានកើនឡើង ( ៣៥ភាគរយ នៅឆ្នាំ ២០០១ , ៤៩ ភាគរយ នៅក្នុងឆ្នាំ ២០០៤ , និង ៦៦ ភាគរយ នៅក្នុងឆ្នាំ ២០០៥)។[168] តំរូវការមូលនិធិសរុបសំរាប់ផែនការការងាររួមរបស់ CMAC នៅឆ្នាំ ២០០៦ គឺស្មើនឹង $9,525,422 ប៉ុន្តែប្រាក់ចំណូលរំពឹងទុករបស់ CMAC សំរាប់ឆ្នាំ២០០៦ គឺស្មើនឹង $8,050,000 ដែលធ្វើអោយមានកង្វះថវិកា។ ចំណូលរំពឹងទុកបានមកជាទ្វេភាគី គឺស្មើនឹង $5,900,000 ពីរដ្ឋាភិបាលគឺស្មើនឹង $350,000 និងពីអង្គការ UNDP ស្មើនឹង $1,800,000 ។[169]

នៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០៦ អង្គការ UNDP នៅកម្ពុជាបានដាក់ចេញនូវគំរោងកម្មវិធីបោសសំអាតមីនរយៈពេល ៥ ឆ្នាំ ឈ្មោះថា "Clearing for Results" ដើម្បីផ្តល់មូលនិធិដល់ប្រតិបត្តិករនៅតាមចំការមីន និងការកសាងសមត្ថភាពខាងផ្នែកធានាគុណភាព និងត្រួតពិនិត្យលទ្ធផលបោសសំអាតមីនទាក់ទិនទៅនឹងសេដ្ឋកិច្ច និងសង្គមកិច្ច។ អ្នកផ្តល់ជំនួយសំរាប់គំរោងនេះដំបូងគេក្នុងឆ្នាំ ២០០៦ គឺមានប្រទេសអូស្ត្រាលី កាណាដា អង្គការ Adopt-A-Minefield និងអង្គការ UNDP។ យោងតាមអង្គការ UNDP នៅថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៦ បានចុះហត្ថលេខាលើគំរោង

164 Email from Zach Hudson, Program Manager, Adopt-A-Minefield, 2 June 2006.
165 CMAA, "Mine Action Achievement Report 2005, Work Plan 2006," 26 April 2006, pp. 13-14.
166 Prime Minister Samdech Hun Sen, "Remarks at the Donation Ceremony of Mine Clearing Equipments from the Government of Japan to CMAC," *Cambodia New Vision*, 10 September 2005. This amount has not been included in the total for 2005.
167 CMAC, "Annual Report January-December 2005," Phnom Penh, 2006, p. 63; see *Landmine Monitor Report 2005*, p. 224.
168 CMAC, "Annual Report January-December 2005," Phnom Penh, 2006, p. 63.
169 CMAC, "Integrated Work Plan 2006," p. xiii.

ជំនួយឥតសំណងមួយដើម្បីផ្តល់ទឹកប្រាក់6លានដុល្លាសហរដ្ឋអាមេរិក ដល់គំរោងនេះសំរាប់រយៈពេល៥ឆ្នាំ។ [170] ការប៉ាន់ស្មានថវិកាសរុបរបស់គំរោងសំរាប់ខែ មករា ឆ្នាំ ២០០៦ ដល់ ខែ ធ្នូ ឆ្នាំ ២០១០ គឺស្មើនឹង ១៥ លានដុល្លារ ។[171]

## អ្នករងគ្រោះថ្នាក់ដោយសារមីននិងគ្រាប់មិនផ្ទុះ [172]

នៅក្នុងឆ្នាំ ២០០៥ គេបានរាយការណ៍ថាមានគ្រោះថ្នាក់ដោយសារគ្រាប់មីននិងគ្រាប់មិនផ្ទុះថ្មីៗ ចំនួន ៨៧៥ ករណី ដែលបានសំលាប់មនុស្សចំនួន ១៦៨ នាក់ និងធ្វើអោយរបួសចំនួន ៧០៧ នាក់ ក្នុងនោះ មានបុរស ៥២៥ នាក់ ស្ត្រី ៨៣ នាក់ និងក្មេង ២៦៧ បុគ្គលិកយោធា ៧ នាក់ និងអ្នកដោះមីន ២២ នាក់។ [173] តួលេខនេះបង្ហាញអោយឃើញថាមានការថយចុះបន្តិចបើប្រៀបធៀបនឹងតួលេខគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះចំនួន ៨៩៨ ករណីក្នុងឆ្នាំ ២០០៤ (ដែលមានមនុស្សស្លាប់ ១៧១នាក់ និងរបួស ៧២៧ នាក់ ) ។ ប៉ុន្តែ ឧបទ្ទវហេតុដោយសារគ្រាប់មីនមានការកើនឡើង ៧ ភាគរយ ( ៣៦៥ ករណី ក្នុងឆ្នាំ ២០០៥ និង ៣៤០ ករណី ក្នុងឆ្នាំ ២០០៤ ) ហើយឧបទ្ទវហេតុគ្រាប់មិនទាន់ផ្ទុះមានការថយចុះជិត ៩ ភាគរយ (៥១០ ករណី ក្នុងឆ្នាំ ២០០៥ និង ៥៥៨ ករណី ក្នុងឆ្នាំ ២០០៤ ) ។ នៅក្នុងឆ្នាំ ២០០៤ ក្មេងៗ ៨៧ ភាគរយត្រូវបានស្លាប់ឬរងរបួសដោយសារគ្រាប់មិនទាន់ផ្ទុះ ។ ក្នុងចំណោមជនរងគ្រោះជនរងគ្រោះដែលនៅរស់រានមានជីវិតក្នុងឆ្នាំ ២០០៥ មនុស្សចំនួន ១៧៣ នាក់ (២៩ភាគរយ) ត្រូវកាត់ដៃជើង គឺថយចុះពីអត្រាកាត់ដៃជើង ២៧ ភាគរយ នៅក្នុងឆ្នាំ ២០០៤ ។

គេបានបន្តរាយកាណ៍អោយដឹងថា គិតត្រឹមខែ មេសា ឆ្នាំ ២០០៦ គ្រោះថ្នាក់មានចំនួន ២៣៤ ករណី រួមមានមនុស្សស្លាប់ចំនួន ៣៣ នាក់ និង របួស ២០១ នាក់ ។ យ៉ាងហោចណាស់ គ្រោះថ្នាក់ ៧៩ ករណីកើតមានលើក្មេងៗ (៣៤ ភាគរយ) , ៩៣ ករណី បណ្តាលមកពីគ្រាប់មីន ( ស្លាប់ ២៥ នាក់, របួស ៦៨ នាក់) និង ១៤១ ករណី បណ្តាលមកពីគ្រាប់មិនទាន់ផ្ទុះ ( ស្លាប់ ៨ នាក់, របួស ១៣៣ នាក់) ។[174]

តាមប្រវត្តិកន្លងមក អត្រាគ្រោះថ្នាក់មីននិងគ្រាប់មិនផ្ទុះបានធ្លាក់ចុះ ពីគ្រោះថ្នាក់ថ្មី ១២ ករណី ក្នុង ១ ថ្ងៃ នៅឆ្នាំ ១៩៩៦ ដល់ ពីរករណីក្នុង ១ ថ្ងៃ ក្នុងឆ្នាំ ២០០០ ហើយចាប់តាំងពីពេលនោះមក អត្រាគ្រោះថ្នាក់នៅថេរ ។ ក្នុងត្រីមាសទី១ ឆ្នាំ ២០០៥ អត្រាគ្រោះថ្នាក់បានកើនឡើងបន្តិចដល់ បី ករណីក្នុង១ថ្ងៃ ប៉ុន្តែក្រោយមកបានធ្លាក់ចុះវិញដល់ ២,៤ករណីក្នុង១ ថ្ងៃ ជាមធ្យម ក្នុងឆ្នាំដដែល ។[175]

នៅថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០០៦ ដែលជាទិវាយល់ដឹងអំពីមីនរបស់ប្រទេសកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានថ្លែងទៅកាន់ប្រជាពលរដ្ឋតាមទូរទស្សន៍ថា ” .... យើងត្រូវខិតខំប្រឹងប្រែងអោយបានខ្លាំងក្លាដើម្បីកាត់បន្ថយ

[170] Mine Action Support Group, “MASG Newsletter-First Quarter of 2006,” Washington DC, 1 May 2006, p. 7.
[171] UNDP Cambodia, “Clearing for Results: A partnership for landmine action in Cambodia,” April 2006, www.un.org.kh, accessed 20 June 2006.
[172] Unless otherwise stated, information in this section was provided by email from Chhiv Lim, CMVIS, Phnom Penh, 13 June 2006. Landmine Monitor was provided raw data and conducted its own analysis.
[173] Email from Kao Vannarin, Project Advisor, CMVIS, 20 June 2006.
[174] Ibid.
[175] See *Landmine Monitor Report 2005*, p. 225.

ចំនួនឧបទ្ទវហេតុគ្រាប់មីនអោយបានច្រើនតាមដែលអាចធ្វើទៅបានជារៀងរាល់ឆ្នាំ អោយដល់កំរិតមួយដែលអត្រាគ្រោះថ្នាក់ធ្លាក់ដល់សូន្យក្នុងរយៈពេល ១០ ឆ្នាំ ខាងមុខ ....ប៉ុន្តែ.....បើទោះបីជាយើងខិតខំប្រឹងប្រែងខ្លាំងជាងឆ្នាំមុនៗយ៉ាងណាក្តី ចំនួនគ្រោះថ្នាក់ដោយសារគ្រាប់មីន នៅតែថេរដដែល មានន័យថាក្នុងរយៈពេល ៤ ឆ្នាំកន្លងទៅ គឺពីឆ្នាំ ២០០២ ដល់ ២០០៥ អត្រាគ្រោះថ្នាក់ជាមធ្យមគឺ ៨៤២ ករណីក្នុង ១ ឆ្នាំ " ។[176]

ផែនទីនានាដែលបង្ហាញពីទីតាំងឧបទ្ទវហេតុគ្រាប់មីននិងគ្រាប់មិនផ្ទុះ បានអោយដឹងពីកំរិតគ្រាប់មីននៅក្បែរខ្សែក្រវ៉ាត់ ក៥ តាមតំបន់ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្ត បន្ទាយមានជ័យ បាត់ដំបង ក្រុងប៉ៃលិន ឧត្តរមានជ័យ ព្រះវិហារ និងខេត្តពោធិសាត់ ។ គ្រោះថ្នាក់ដោយសារគ្រាប់មិនទាន់ផ្ទុះកើតមាននៅពេញផ្ទៃប្រទេស ដែលភាគច្រើនគ្រោះថ្នាក់ ដោយសារគ្រាប់មិនផ្ទុះកើតមានក្នុងខេត្តបាត់ដំបង កំពង់ចាម (តាមព្រំដែនវៀតណាម) ព្រះវិហារ ក្រុងប៉ៃលិន ឧត្តរមានជ័យ និង បន្ទាយមានជ័យ ។ គេបានរាយការណ៍ថា គ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះកើតមាននៅក្នុងខេត្ត២១ ក្នុងចំណោម ២៤ ខេត្តក្រុង នៅក្នុងឆ្នាំ២០០៥ ដែលក្នុងនោះ៦ខេត្តមានគ្រោះថ្នាក់ចំនួន ៦៩១ករណី (៧៨ភាគរយ) នៃចំនួនគ្រោះថ្នាក់សរុប ហើយខេត្តបីមាន ៤៩១ ករណី ( ៥៦ ភាគរយ ) ។ ខេត្តបាត់ដំបងមានគ្រោះថ្នាក់ ២៤៩ ករណី ( គ្រាប់មីន ៩៩ ករណី និង គ្រាប់មិនទាន់ផ្ទុះ ១៥០ ករណី ) ខេត្តបន្ទាយមានជ័យមានគ្រោះថ្នាក់ ១៣៩ ករណី ( គ្រាប់មីន ១១២ ករណី និង គ្រាប់មិនទាន់ផ្ទុះ ២៧ ករណី ) ក្រុងប៉ៃលិនមានគ្រោះថ្នាក់ ១០៣ ករណី( គ្រាប់មីន ៦៨ ករណី និង គ្រាប់មិនទាន់ផ្ទុះ ៣៥ ករណី ) ខេត្តព្រះវិហារមានគ្រោះថ្នាក់ ៧៣ ករណី ( គ្រាប់មីន ១៧ ករណី និង គ្រាប់មិនទាន់ផ្ទុះ ៥៦ករណី ) ខេត្តឧត្តរមានជ័យ មានគ្រោះថ្នាក់ ៦៦ ករណី ( គ្រាប់មីន ៣៨ ករណី និង គ្រាប់មិនទាន់ផ្ទុះ ២៨ករណី ) និងខេត្តកំពង់ចាមមានគ្រោះថ្នាក់ ៦១ ករណី (គ្រាប់មីន ៣ ករណី និង គ្រាប់មិនទាន់ផ្ទុះ ៥៨ករណី) ។ ខេត្តដែលនៅសល់ ១៥ ទៀត មានគ្រោះថ្នាក់ ១៨៤ ករណី ( គ្រាប់មីន ២៨ ករណី និង គ្រាប់មិនទាន់ផ្ទុះ ១៥៦ករណី ) ។

ស្រុកដែលរងគ្រោះខ្លាំងជាងគេគឺស្រុកអូជ្រៅ ក្នុងខេត្តបន្ទាយមានជ័យដែលមានគ្រោះថ្នាក់ ៥៣ ករណី ( គ្រាប់មីន ៤៦ ករណី និង គ្រាប់មិនទាន់ផ្ទុះ ៧ករណី ) ហើយឃុំដែលរងគ្រោះខ្លាំងជាងគេគឺឃុំអូចារ ក្នុងខេត្តបាត់ដំបងដែលមានគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះចំនួន ៤៤ករណី ) ។

នៅពេលកើតហេតុ ចំនួនគ្រោះថ្នាក់មីនភាគច្រើនជាងគេនៅក្នុងឆ្នាំ ២០០៥ ពាក់ពន្ធ័ទៅនឹងសកម្មភាពចិញ្ចឹមជីវិតប្រចាំថ្ងៃដូចជាការធ្វើស្រែចំការ ការឃ្វាលគោក្របី ការរានដីថ្មី ការនេសាទ ការបេះផ្លែឈើនិងរកអុស (៦០ ភាគរយ) ឬការធ្វើដំណើរ (១៨ ភាគរយ) ចំណែកឯ ៥៧ភាគរយនៃគ្រោះថ្នាក់គ្រាប់មិនផ្ទុះបណ្តាលមកពីការកែឆ្នៃ ។

អង្គការ HALO បានសង្កេតឃើញថា ឈ្មួញទិញអេតចាយដែលលក់វត្ថុគ្រោះថ្នាក់បានថយចុះយ៉ាងខ្លាំងនៅក្នុងតំបន់ដែលពួកគេធ្វើការ ហើយបានចាត់ទុកលទ្ធផលនេះថាបានមកពីការយកចិត្តទុកដាក់របស់នគរបាលនិងការណែនាំច្បាស់លាស់ដល់ឈ្មួញទាំងនោះ ។[177] ចំនួនគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះគួរអោយកត់សំគាល់ (២៥ ភាគរយ) គឺប៉ះទៅលើ

---

[176] Prime Minister Samdech Hun Sen, address to the nation, Mine Awareness Day, 24 February 2006
[177] HALO statement at Cambodian Mine Action Authority Meeting, Phnom Penh, 24 March 2006.

អ្នករងគ្រោះដែលមិនបានធ្វើអ្វីសោះខណៈពេលដែលគ្រាប់ផ្ទុះក្បែរពួកគេ ចំនួនឧបទ្ទវហេតុដែលបណ្តាលមកពីការឆ្កៃគ្រាប់បានធ្លាក់ចុះសមាមាត្រទៅនឹងចំនួនគ្រោះថ្នាក់ ដែលបានបង្ហាញអោយឃើញថាមនុស្សទាំងនោះមិនបានធ្វើអ្វីឡើយ គឺគេជាអ្នកឈរមើលសកម្មភាពកែឆ្នៃគ្រាប់។[178]

នៅក្នុងឆ្នាំ ២០០៥ CMVIS បានកត់ត្រាទុកនូវចំនួនគ្រោះថ្នាក់ដោយសារការដោះមីនចំនួន ២២ ករណី (ស្លាប់ ១ នាក់ របួស ២១ នាក់) គឺមានការកើនឡើងពី ១៨ ករណី ដែលគេបានរាយការណ៍នៅក្នុងឆ្នាំ ២០០៤ ។ បន្ថែមពីលើចំនួនគ្រោះថ្នាក់ដោយសារការដោះមីនដែលត្រូវបានរាយការណ៍ដោយអង្គការ CMAC(ស្លាប់ ១ នាក់ របួស ៩ នាក់) អង្គការ HALO (របួស ៣ នាក់)និងអង្គការ MAG(របួស ១ នាក់)មានគ្រោះថ្នាក់ ៨ ករណីទៀត ដែលមិនកើតមានលើ ឬអះអាងដោយអ្នកប្រតិបត្តិករដោះមីនដែលមានការអនុញ្ញាតត្រឹមត្រូវ នៅក្នុងប្រទេសកម្ពុជា។[179]

ព័ត៌មានស្តីអំពីគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះត្រូវបានគេប្រមូលពីគ្រប់ខេត្តទាំងអស់ដោយបណ្តាញរបស់បុគ្គលិកកាកកាបាទក្រហមកម្ពុជា បន្ទាប់មកទិន្នន័យទាំងនោះត្រូវបានគេបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យរបស់ CMVIS ដែលធ្វើឡើងរួមគ្នាជាមួយអង្គការ Handicap International Belgium ហើយផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធទាំងអស់ម្តងក្នុង ១ខែ។ ប្រព័ន្ធប្រមូលទិន្នន័យមានលក្ខណៈទូលំទូលាយ ហើយត្រូវបានចាត់ទុកជាប្រព័ន្ធល្អបំផុតក្នុងពិភពលោក តែទោះជាយ៉ាងនេះក្តី គ្រោះថ្នាក់ទាំងឡាយ " អាចមិនត្រូវបានគេរាយការណ៍អស់នោះទេ ដោយសារកង្វះមធ្យោបាយទៅរកការព្យាបាលភាពដាច់សង្វែងរបស់ភូមិមួយចំនួន និងបញ្ហាផ្លូវច្បាប់ទាក់ទងនឹងការកែឆ្នៃគ្រាប់ "។ ស្ថិតិទាំងឡាយបង្ហាញអោយឃើញពិស្តារពីទីកន្លែងកើតហេតុ នៅពេលដែលកើតមានឧបត្តិហេតុគ្រោះថ្នាក់មីនកើតឡើង ប៉ុន្តែមិនបានបង្ហាញពីទីកន្លែងដែលជនរងគ្រោះនៅបន្ទាប់ពីកើតឧបទ្ទវហេតុឬទីកន្លែងដែលក្រុមគ្រួសាររបស់គេរស់នៅឡើយ ព្រោះអ្នកខ្លះបានប្តូរទៅតាំងទីលំនៅលើដីស្រែចំការដែលមានជីជាតិ នៅក្នុងខេត្តបីក្នុងចំណោមខេត្តនានាដែលមានគ្រោះថ្នាក់គ្រាប់មីនច្រើនជាងគេ ។ បញ្ហានេះជាបញ្ហាប្រឈមមួយបន្ថែមទៀតសំរាប់ការធ្វើផែនការជួយជនរងគ្រោះដែលនៅរស់ គឺថាកន្លែងដែលឧបទ្ទវហេតុកើតឡើងមិនមែនសុទ្ធតែជាកន្លែងដែលជនរងគ្រោះដែលនៅរស់ស្វែងរកសេវាព្យាបាលជាចាំបាច់ឡើយ។[180]

ចាប់តាំងពីឆ្នាំ ១៩៧៩ មកដល់ ខែមេសា ឆ្នាំ ២០០៦ ប្រពន្ធ័ទិន្នន័យរបស់ CMVIS បានកត់ត្រាគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះចំនួន ៦២,៦៣៨ ករណី : មានមនុស្សចំនួន ១៩,៣៣៣ បានស្លាប់ និង ៤៣,៣០៥ នាក់រងរបួស (រួមមានជនពិការ ៨,៥៨២ នាក់ ) , ៥២,៥០១ ជាជនស៊ីវិល។[181]

ខណៈដែលប្រពន្ធ័ទិន្នន័យរបស់ CMVIS ផ្តល់នូវព័ត៌មានអំពីគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះ គ្មានប្រព័ន្ធទិន្នន័យណាមួយដែលអាចតាមដានការរីកចំរើនរបស់ជនរងគ្រោះដែលនៅរស់តាមរយៈការស្តារលទ្ធភាព និងសេវាផ្សេងៗទៀត

---

[178] Richard Moyes, "Tampering: Deliberate handling and use of live ordnance in Cambodia," London, August 2004, p. 12.

[179] Response to Landmine Monitor Questionnaire by Heng Rattana, CMAC, Phnom Penh, 9 February 2006; HALO, "Annual Report 2005," Phnom Penh, 11 January 2006, p. 6; response to Landmine Monitor Questionnaire by Rupert Leighton, MAG, Phnom Penh, 1 February 2006.

[180] Sheree Bailey, "Landmine Victim Assistance in Integrated Mine Action in Cambodia–Final Report," December 2005, p. 6.

[181] Email from Kao Vannarin, CMVIS, 20 June 2006.

ឡើយ ហើយក៏គ្មានមធ្យោបាយណាមួយផ្តល់នូវការគ្រប់គ្រងករណីនីមួយៗបានទាំងស្រុងឡើយ ។ នៅក្នុងការប៉ុនប៉ងមួយក្នុងការដោះស្រាយបញ្ហានេះ ក្រុមតូចមួយ “mini sub-group”បានត្រូវបង្កើតឡើងក្នុងខែ ធ្នូ ឆ្នាំ ២០០៥ ។ ក្រុមនេះមាន អង្គការ CMVIS, អង្គការ Handicap International-Belgium (HI-Belgium), អង្គការជនពិការកម្ពុជា, អាជ្ញាធរមីនកម្ពុជា, អង្គការ UNICEF, កាកបាទក្រហមកម្ពុជា , អង្គការ Jesuit Service និង សមាគមន៍ Association for Aid and Relief Japan ។ ប៉ុន្តែគេពុំទាន់បានកំណត់ច្បាស់លាស់ពីមធ្យោបាយដើម្បីអនុវត្តប្រព័ន្ធបែបនេះនៅឡើយ គិតមកដល់ខែ មិនា ឆ្នាំ ២០០៦ ។[182]

## ការជួយជនរងគ្រោះដែលនៅរស់ពីគ្រោះថ្នាក់មីន

នៅក្នុងសន្និសីទត្រួតពិនិត្យឡើងវិញលើកទី ១ នាខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៤ ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកជាប្រទេសមួយក្នុងចំណោមរដ្ឋជាសមាជិកទាំង ២៤ ដែលមានចំនួនជនរងគ្រោះដែលនៅរស់ច្រើនគួរអោយកត់សំគាល់ និង ”មានការទទួលខុសត្រូវខ្លាំងជាងគេក្នុងការបោសសំអាតមីន ប៉ុន្តែក៏មានតំរូវការនិងការរំពឹងលើជំនួយច្រើនជាងគេដែរ ” ក្នុងការផ្តល់សេវាថែរក្សា ស្តារលទ្ធភាពពលកម្ម និងការធ្វើសមាហរណកម្មជនរងគ្រោះដែលនៅរស់អោយបានគ្រប់គ្រាន់ ។[183]

នៅក្នុងកិច្ចប្រជុំរបស់រដ្ឋជាសមាជិកលើកទី ៦ នាខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៥ ប្រទេសកម្ពុជាបានប្រកាសថា” ខ្លួនមានជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ ហើយដែលគេបានចុះក្នុងបញ្ជីចំនួន ៤៥,000 នាក់ ។ ប្រទេសកម្ពុជាសារភាពថា ខ្លួនមិនបានចាត់វិធានការអោយបានគ្រាប់គ្រាន់សំរាប់ជួយជនរងគ្រោះទាំងនោះឡើយ ។ អ្នកផ្តល់ជំនួយក៏ដូច្នេះដែរ មិនបានធ្វើការទាមទារអោយបានគ្រប់គ្រាន់ ដើម្បីអោយមូលនិធិជំនួយរបស់ខ្លួនបានដល់ដៃជនរងគ្រោះដោយផ្ទាល់ ។ សន្ធិសញ្ញាប្រឆាំងនឹងគ្រាប់មីនទាមទារអោយយើងធ្វើដូច្នេះ.....រដ្ឋដែលរងគ្រោះទាំងឡាយអាចរៀបរាប់ពីតំរូវការដែលមានលក្ខណៈប្រកួតប្រជែងនានាក្នុងប្រទេសរបស់ខ្លួន ដើម្បីសំរេចបាននូវគោលដៅអភិវឌ្ឍន៏សហសវត្ស ។ ប៉ុន្តែការត្រួតពិនិត្យគ្រាប់មីនកប់ដីបង្ហាញអោយឃើញច្បាស់ថា យើងមិនមានការឆ្លៃប្រឌិត មនសិការ និង ការឃ្លាសវៃគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតំរូវការពិតប្រាកដរបស់អ្នកក្រីក្រជាងគេ នៅក្នុងប្រទេសរបស់យើង ដែលជាអ្នកចំណាយសំរាប់ការប្រើប្រាស់របស់យើងនូវអ្វីដែល លោកស្រី Jody Williams បានហៅកាលពីម្សិលមិញថា ”អាវុធភេរវកម្ម ប្រចាំថ្ងៃ ” ។[184]

ប្រទេសកម្ពុជាក៏បានបង្ហាញពីទិសដៅឆ្នាំ ២០០៥-២០០៩ របស់ខ្លួននៅក្នុងកិច្ចប្រជុំរបស់រដ្ឋជាសមាជិកលើកទី ៦ ។ ទិសដៅទាំងនោះរួមមានៈ រក្សាអោយបានជានិរន្តរ៍នូវការប្រមូលព័ត៌មាន និងបណ្តាញបង្អែកដោយបង្កើនសមត្ថភាពរបស់អ្នកពាក់ព័ន្ធទាំងឡាយនៅក្នុងប្រទេស បង្កើតនូវគោលការណ៏ណែនាំនិងយុទ្ធសាស្រ្តអភិវឌ្ឍន៏ផ្នែកវេជ្ជសាស្រ្ត លើកកំពស់

---

[182] CCBL letter to NGOs in Cambodia, March 2006; email from Bruno Leclerq, Director, HI-B Cambodia, Phnom Penh, 5 June 2006; Jesuit Service minutes of the Mini Sub-Group meeting, Phnom Penh, 9 February 2006; email from Nhar Ny, Jesuit Service Cambodia, 7 June 2006.

[183] UN, “Final Report, First Review Conference of the States Parties to the Convention on the Prohibition of the Use, Stockpiling, Production and Transfer of Anti-Personnel Mines and on Their Destruction,” Nairobi, 29 November-3 December 2004, APLC/CONF/2004/5, 9 February 2005, p. 33.

[184] Statement by Cambodia, Sixth Meeting of States Parties, Zagreb, 30 November 2005.

គុណភាព និងការបែងចែកដោយស្មើភាពនូវសេវាស្តារលទ្ធភាពពលកម្ម ឆ្លើយតបទៅនឹងតំរូវការផ្នែកចិត្តសាស្រ្តសង្គមរបស់ជនរងគ្រោះដោយសារមីនដែលនៅរស់និងរបស់ក្រុមគ្រួសារពួកគេ ជំរុញអោយមានការចូលរួមពីប្រជាពលរដ្ឋពិការក្នុងសកម្មភាពអភិវឌ្ឍន៏សំខាន់ៗ ជួយអោយក្មេងៗមានការអភិវឌ្ឍបានពេញលេញនិងសមាហរណកម្មចូលក្នុងសហគមន៏ និងអនុម័តព្រមទាំងអនុវត្តនូសេចក្តីព្រៀងច្បាប់ ពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់ និងលើកកំពស់ការយល់ដឹងដើម្បីការពារសិទ្ធនិងតំរូវការរបស់ជនពិការគ្រប់រូប។[185] ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ពីរនាក់មកពីប្រទេសកម្ពុជាបានចូលរួម ក្នុងកិច្ចប្រជុំរបស់រដ្ឋជាសមាជិកលើកទី ៦។

ប្រទេសកម្ពុជាមិនបានធ្វើសេចក្តីថ្លែងការណ៍នៅឯគណៈកម្មាធិការអចិន្រ្តៃយ៏ទទួលបន្ទុកជំនួយជនរងគ្រោះ និង សមាហរណកម្មក្នុងសេដ្ឋកិច្ចសង្គមក្នុងខែ ឧសភា ឆ្នាំ ២០០៦ ហើយក៏មិនបានដាក់បញ្ចូលអ្នកជំនាញផ្នែកជំនួយជនរងគ្រោះក្នុងគណៈប្រតិភូរបស់ខ្លួនឡើយ ។

ប្រទេសកម្ពុជាបានប្រគល់ទំរង់បែបបទស្ម័គ្រចិត្ត (Form J) ជាមួយនិងរបាយការណ៏មាត្រាទី ៧ ប្រចាំឆ្នាំរបស់ខ្លួនដែលផ្តល់ព័តិមានអំពីគ្រោះថ្នាក់គ្រាប់មីននិងគ្រាប់មិនផ្ទុះ និង សេវាស្តារលទ្ធភាពពលកម្មនានា ។

អាជ្ញាធរមីនកម្ពុជា ជាអ្នកទទួលខុសត្រូវចំពោះការសំរបសំរួលនិងការត្រួតពិនិត្យជំនួយសំរាប់ជនរងគ្រោះដោយសារមីន ។ នាយកដ្ឋានទទួលបន្ទុកជំនួយសំរាប់ជនរងគ្រោះដោយសារមីនរបស់អង្គការនេះបានបង្កើតផែនការយុទ្ធសាស្រ្តសំរាប់ឆ្នាំ ២០០៤-២០០៩ មួយ ដើម្បីការសំរបសំរួលសកម្មភាពផ្តល់ជំនួយនានារបស់ស្ថាប័នថ្នាក់ជាតិ និង របស់អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិនានា, ប៉ុន្តែនាយកដ្ឋាននេះគ្មានថវិកាដើម្បីអនុវត្តយុទ្ធសាស្រ្តនេះទេ។ នៅក្នុងឆ្នាំ ២០០៤ អាជ្ញាធរមីនកម្ពុជា បានចែករំលែកការទទួលខុសត្រូវចំពោះជំនួយសំរាប់ជនរងគ្រោះទៅអោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC)។ [186] ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវបានគេប្រគល់ភារកិច្ចអោយចងក្រងរបាយការណ៏ប្រចាំឆ្នាំស្តីអំពីជំនួយសំរាប់ជនរងគ្រោះ ។ មកដល់ខែមិថុនា ឆ្នាំ ២០០៦ គេនៅពុំទាន់បានទទួលរបាយការណ៏ឆ្នាំ ២០០៥នៅឡើយ ដោយសារគ្មានការផ្តល់ថវិកា។[187]

ដោយជនពិការភាគច្រើន រស់នៅក្នុងតំបន់ជនបទ ការទទួលបាននូវសេវានានាត្រូវបានរាំងស្ទះ ដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធ ។ ការសិក្សាពីរដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០៥ និង ២០០៦ បានរៀបរាប់ពីបញ្ហារបស់ជនពិការក្នុងប្រទេសកម្ពុជា ដែលត្រូវបានបរិយាយត្រួសៗតាមរយៈផែនការ ១២ចំនុច របស់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ផ្ទាល់។ [188] ជនពិការគឺជាក្រុមមួយក្នុងចំណោមក្រុមមនុស្សដែលក្រីក្រនិងងាយរងគ្រោះជាងគេនៅ

[185] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 122-128.

[186] See *Landmine Monitor Report 2005*, p. 226. MoSVY was formerly the Ministry of Social Affairs, Labor, Vocational Training and Youth Rehabilitation.

[187] Email from Chan Rotha, CMAA, 5 June 2006; emails from Long Sothy, Director, DAC, Phnom Penh, 7 and 12 June 2006.

[188] Philippa Thomas, "Poverty Reduction and Development in Cambodia: Enabling Disabled People to Play a Role," DFID, April 2005; Cooperation Committee for Cambodia (CCC), "The Challenge of Living with Disability in Cambodia, A Study of Mobility Impaired People in the Social Setting of Prey Veng District, Prey Veng Province," March 2006; see *Landmine Monitor Report 2004*, p. 271.

ក្នុងសង្គមកម្ពុជា ជនពិការគឺជាអ្នកក្រីក្រជាងគេក្នុងចំណោមអ្នកក្រីក្រផ្សេងទៀត ដែលទទួលបានសេវាសង្គមមូលដ្ឋាន ការអប់រំ ជំនាញ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារធ្វើ និងឱកាសរកប្រាក់កំរៃ ដ៏តិចតួចស្តួចស្តើងបំផុត ។ តាមសេចក្តីរាយការណ៍បានអោយដឹងថា ព្រះសង្ឃ ឬដូនជីតាជីនៅតាមវត្តអារាមមិនដែល ឬកំរ ទៅសួរសុខទុក្ខជនពិការដែលជានិច្ចកាលមិនសូវបានដឹងពីការប្រជុំនៅតាមភូមិដ្ឋានឬសកម្មភាពការអភិវឌ្ឍន៍នានាឡើយ ។ ជនពិការដែលមានលក្ខណៈធ្ងន់ធ្ងរបំផុតមិនត្រូវបានផ្តល់ព័ត៌មានអំពីរបៀបចុះឈ្មោះបោះឆ្នោតឡើយ ។[189] ពិការភាពដោយសារគ្រាប់មីនកប់ដីមានចំនួន ១១.៥ ភាគរយនៃជនពិការទាំងអស់ ។[190]

ប្រព័ន្ធថែរក្សាសុខភាពក្នុងប្រទេសកម្ពុជាមានរចនាសម្ព័ន្ធនៅតាមមជ្ឈមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងមន្ទីរពេទ្យថ្នាក់ជាតិនានា ។ ការថែទាំវេជ្ជសាស្ត្រជាធម្មតាត្រូវបង់ថ្លៃ ហើយតំលៃថែរក្សាសុខភាពរយៈពេលយូរនៅតែមានកំរិតខ្ពស់ ។[191] ប្រជាជនអាចទទួលបានឱសថជំនួយបឋមនៅតាមមជ្ឈមណ្ឌលសុខភាពរបស់រដ្ឋនានានៅថ្នាក់ឃុំស្រុក ហើយជួនកាលនៅថ្នាក់ភូមិ ប៉ុន្តែរបួសភាគច្រើនត្រូវការការព្យាបាលឯកទេស រួមមានការវះកាត់ ។ ជាញឹកញាប់ឧបទ្ទវហេតុកើតឡើងនៅក្នុងភូមិ ឬ នៅក្នុងព្រៃឆ្ងាយពីមជ្ឈមណ្ឌលសុខភាពនានា ហើយឱសថសង្គ្រោះបន្ទាន់ត្រូវបានផ្តល់ដោយអ្នកភូមិ ។[192] ជានិច្ចកាល ការដឹកជញ្ជូនទៅរកតំហែទាំវេជ្ជសាស្ត្រតែងតែមិនអាចធ្វើទៅបាន ហើយវាអាចត្រូវការពេល១ថ្ងៃ ឬច្រើនជាងនេះដើម្បីទទួលបានបរិក្ខាពេទ្យ ដែលធ្វើអោយអ្នករងគ្រោះជាច្រើនស្លាប់មុនពេលទៅដល់មន្ទីរពេទ្យ ។ ក៏មានការខ្វះខាតផ្នែកបុគ្គលិកថែរក្សាសុខភាពដែលទទួលបានការការបណ្តុះបណ្តាលត្រឹមត្រូវផងដែរ ។[193] នៅក្នុងខែ មេសាឆ្នាំ ២០០៦ ការថែទំាវេជ្ជសាស្ត្រដំបូងៗ ដែលទទួលបានដោយជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនផ្ទុះចំនួន ៤៨ករណីមានដូចតទៅ :- មនុស្ស ១១ នាក់ពុំទទួលបានជំនួយអ្វីឡើយ ១០ នាក់ទទួលបានជំនួយនៅមជ្ឈមណ្ឌលសុខភាពឃុំ ៤ នាក់ នៅមន្ទីរព្យាបាលឯកជន ៤ នាក់ នៅមន្ទីរពេទ្យថ្នាក់ស្រុក ៣ នាក់នៅជំរុំកងទ័ព ២ នាក់នៅមន្ទីរពេទ្យខេត្ត ១ នាក់នៅទីភ្នាក់ងារកំចាត់មីន ៦ នាក់ព្យាបាលខ្លួនឯង និង ០៧ នាក់ត្រូវបានរាយការណ៍ថាទទួលបានការព្យាបាលផ្សេងៗទៀត ។[194]

អាស្រ័យដោយសមត្ថភាពរបស់រដ្ឋាភិបាលនៅមានកំរិត អង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិនានាផ្តល់ជំនួយជនរងគ្រោះដែលនៅរស់ដោយសហការជាមួយក្រសួងដែលពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាននានា ។[195] យោងតាម CMAA បានអោយដឹងថា មានអង្គការជាង ៣០ កំពុងធ្វើការស្តារលទ្ធភាពជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ និង

---

[189] CCC, "The Challenge of Living with Disability in Rural Cambodia," March 2006, pp. 9-10.
[190] US Department of State, "Country Reports on Human Rights Practices-2005: Cambodia," Washington DC, 8 March 2006.
[191] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 123-124.
[192] See *Landmine Monitor Report 2005*, p. 227.
[193] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 124.
[194] CMVIS, "Monthly Mine/UXO Victim Information Report: April 2006," 23 May 2006, p. 3.
[195] Sheree Bailey, "Landmine Victim Assistance in Integrated Mine Action in Cambodia – Final Report," December 2005, p. 12.

ជនពិការដទៃទៀត នៅក្នុងប្រទេសកម្ពុជា។[196] ជាសរុប ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ចំនួន ២,១៧០ នាក់បានទទួលឧបករណ៍សិប្បនិម្មិត និង ការវះកាត់ជនរងគ្រោះដែលនៅរស់ ៣២៣នាក់ ទទួលបានការស្តារលទ្ធភាពពលកម្ម នៅតាមសហគមន៍ ៣៦៥ នាក់ទទួលបានការការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និង ជនរងគ្រោះដែលនៅរស់មួយចំនួនទទួលបានសេវាអភិវឌ្ឍន៍មុខរបរផ្សេងៗនៅក្នុងឆ្នាំ ២០០៥។[197]

ជាទូទៅ នៅក្នុងប្រទេសកម្ពុជា សេវាស្តារកាយសម្បទាសំរាប់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ត្រូវបានរៀបចំយ៉ាងល្អ ប្រកបដោយគុណភាព ជាពិសេសសំរាប់អ្នកដែលត្រូវកាត់អវៈយវៈ បើទោះបីជាតំរូវការនៅតែមានទំហំធំធេងយ៉ាងណាក៏ដោយ។ ប៉ុន្តែ តែងតែមានការយឺតយ៉ាវជានិច្ចទំរាំដល់ពេលទៅកាន់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មជាលើកដំបូង ។ នៅដំណាច់ឆ្នាំ ២០០៥ មានមជ្ឈមណ្ឌលស្តារកាយសម្បទា និងរោងជាងជើងសិប្បនិម្មិត (orthopedic workshops)ចំនួន ១១ កន្លែង នៅតាម ២៤ ខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជា (ថយចុះពី ១៤កន្លែង នៅដើមឆ្នាំ ២០០៣ ជាចំបងដោយសារកង្វះការឧបត្ថម្ភថវិកា) ហើយជំនួយខ្លះក៏ត្រូវបានផ្តល់ដោយក្រុមចល័តដែលចុះតាមមូលដ្ឋានឆ្ងាយៗ។ អ្នកស្រាវជ្រាវត្រួតពិនិត្យគ្រាប់មីនកប់ដីជាច្រើនដែលបានធ្វើទស្សនកិច្ចនៅគ្រប់ខេត្តក្រុងទាំងអស់ នៅក្នុងឆ្នាំ ២០០៥ បានរកឃើញថា មានការលំបាកក្នុងការទទួលបានឧបករណ៍សិប្បនិម្មិតនៅក្នុងខេត្តស្ទឹងត្រែង ព្រះវិហារ កោះកុង និងខេត្តកំពង់ធំ។[198] អង្គការមិនមែនរដ្ឋាភិបាលដែលទទួលបន្ទុកខាងផ្នែកស្តារលទ្ធភាពពលកម្មបានជំរុញអោយរដ្ឋាភិបាលទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុអោយបានខ្លាំងជាងមុនដើម្បីទ្រទ្រង់មជ្ឈមណ្ឌលទាំងនោះ ។ គណៈកម្មាធិការអន្តរជាតិកាកបាទក្រហម (ICRC) និងអង្គការ HIបានអោយដឹងអោយក្នុងឆ្នាំ ២០០៦ថា បញ្ហានេះបានកើតមានឡើងនៅក្នុងមជ្ឈមណ្ឌលដែលអង្គការទាំងនេះទទួលខុសត្រូវ។[199]

នៅក្នុងឆ្នាំ ២០០៥ រដ្ឋាភិបាលបានយល់ព្រមពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រផ្តល់សេវាថែទាំសុខភាព ។ គំរោងសកម្មភាពសំរាប់សេវាមន្ទីពេទ្យបន្ថែមដែលគេបានស្នើ អំពាវនាវអោយដាក់បញ្ចូលមជ្ឈមណ្ឌលស្តារកាយសម្បទាទៅក្នុងក្របខ័ណ្ឌសេវាមន្ទីរពេទ្យជាទូទៅដែលនឹងត្រូវផ្ទេរទទួលខុសត្រូវរបស់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មទៅអោយក្រសួង សុខាភិបាល។[200]

នៅក្នុងខែ មិថុនា ឆ្នាំ ២០០៦ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) បានដាក់ស្នើទៅអង្គការ UNICEF នូវគំរោងស្តារលទ្ធភាពពលកម្មតាមសហគមន៍ទូទាំងប្រទេសមួយដែលសំដៅបង្កើតអោយមានការស្តារលទ្ធភាពពលកម្មតាមសហគមន៍ទូទាំងប្រទេសដែលមានលក្ខណៈយូរអង្វែង ហើយដោះស្រាយបាននូវគំលាតនៃការទទួលបានសេវាសំរាប់ជនពិការ។ កិច្ចការនេះអាចដំណើរការទៅបានតាមរយៈគណៈកម្មាធិការ

---

196 CCC, "The Challenge of Living with Disability in Rural Cambodia," March 2006, p. 16; see *Landmine Monitor Report 2005*, p. 226.

197 CMAA, "Mine Action Achievements Report 2005, Work Plan 2006," 21 April 2006, p. 30.

198 See *Landmine Monitor Report 2005*, p. 228.

199 Interview with Jöel Nininger, Coordinator Rehabilitation Department, ICRC Cambodia, Battambang, 3 March 2006; email from Bruno Leclerq, HI-Belgium, Cambodia, 5 June 2006.

200 Interview with Liz Cross, former Advisor, DAC, Phnom Penh, 3 March 2006; emails from Edith van Wijngaarden, Coordinator, Rehabilitation Department, HI-Belgium, Cambodia, 5 and 14 June 2006.

ក្រុមការងារបច្ចេកទេស វេទិកានានាតាមមូលដ្ឋាន តាមតំបន់ និងនៅថ្នាក់ជាតិ ការរាយការណ៍ និងត្រួតពិនិត្យនៅនឹងកន្លែងរួមគ្នា និងតាមរយៈការបង្កើតរបាយការណ៍ជំនួយជនរងគ្រោះថ្នាក់ជាតិមួយ ។[201]

ការវាយតំលៃលើស្ថេរភាពនៃសេវាព្យាបាលនិងផ្តល់ជើងសិប្បនិម្មិតនៅក្នុងប្រទេសកម្ពុជា ដែលគេបានគ្រោងធ្វើនៅឆ្នាំ ២០០៥ បានចាប់ផ្តើមដំណើរការក្នុងខែ មិថុនា ឆ្នាំ ២០០៦ ។ អង្គការ AusAID, USAIDនិង អង្គការ UNICEF មានគំរោងផ្តល់មូលនិធិស្មើៗគ្នាសំរាប់ទ្រទ្រង់ការសិក្សាស្រាវជ្រាវដែលមានតំលៃចំនួន ៧៥,០០០ ដុល្លារ អោយទៅគណៈកម្មាធិការចំរុះរវាងរដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនឹងជនពិការនានា ។[202] យោងតាមអង្គការ AusAID បានអោយដឹងថា គោលបំណងរួមរបស់ការវាយតំលៃនេះគឺដើម្បីសំរេចបាននូវយុទ្ធសាស្ត្រសំរបសំរួលជាតិមួយសំរាប់ផ្នែកស្តារកាយសម្បទារបស់ប្រទេសកម្ពុជា ដែលរួមបញ្ចូលសេវាសំខាន់ៗសំរាប់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ ។ ធ្វើដូច្នេះអាចដោះស្រាយបាននូវ តំរូវការជាបន្តរបស់អ្នកជំងឺ បញ្ហាតួនាទីរបស់រដ្ឋាភិបាលក្នុងពេលបច្ចុប្បន្ន និងអនាគត និងបញ្ហាការធ្លាក់ចុះនូវជំនួយឧបត្ថម្ភពីម្ចាស់ជំនួយ ។[203]



អង្គការ UNICEF បន្តជួយគាំទ្រដល់ជនពិការតាមរយៈអង្គការ Veterans International, អង្គការ Operation Enfants de Battambang, មជ្ឈមណ្ឌលជាតិសំរាប់ជនពិការ, អង្គការកសាងសមត្ថភាពជនពិការនៅតាមសហគមន៍ ក្រុមប្រឹក្សាសកម្មភាពជនពិការនិងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។[204]

អង្គការអន្តរជាតិចំនួន ៤ គឺអង្គការ ICRC, Cambodia Trust, Handicap International និងអង្គការ Veterans International Cambodia បានជួយឧបត្ថម្ភគាំទ្រដល់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួន ១១ កន្លែង នៅក្នុងឆ្នាំ ២០០៥ ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានថវិកាតិចតួចសំរាប់ដំណើរការការស្តារកាយសម្បទា ដូច្នេះហើយពឹងផ្អែកទៅលើទីភ្នាក់ងារអន្តរជាតិនានា ។ អង្គការនានាដូចជា ICRC រួមជាមួយនិងមជ្ឈមណ្ឌលស្តារកាយសម្បទានានា ដែលរៀបចំឡើងដោយរដ្ឋាភិបាលទទួលបានការឧបត្ថម្ភថវិកាសំរាប់ទ្រទ្រង់ចំនាយរបស់មជ្ឈមណ្ឌល អង្គការផ្សេងៗទៀត មានជោគជ័យក្នុងការទទួលបានមូលនិធិទាំងនេះក្នុងកំរិតខុសៗគ្នា ។[205]

អង្គការ ICRC បានផ្តល់នូវប្រព័ន្ធទិន្នន័យថ្មីមួយសំរាប់មជ្ឈមណ្ឌលស្តារកាយសម្បទានានា ដើម្បីប្រមូលស្ថិតិទាក់ទិន

---

[201] Email from Plong Chhaya, UNICEF, Cambodia, 14 June 2006.

[202] "Proposal for the Evaluation of the Physical Rehabilitation Sector in Cambodia," August 2005; emails from Edith van Wijngaarden, HI-Belgium, Cambodia, 2 March, 5 and 14 June 2006.

[203] Information provided by Stephen Close, Donor Harmonisation Officer, AusAID, Cambodia, 23 March 2006.

[204] Email from Plong Chhaya, UNICEF, Cambodia, 10 July 2006.

[205] Interview with Jöel Nininger, ICRC Cambodia, Battambang, 3 March 2006. For rehabilitation/orthopedic centers assisting mine survivors and other people with disabilities in 2005, see *Landmine Monitor Report 2005*, p. 228.

នឹងការផ្តល់សេវា ។ នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលទាំង ១១ បានជួយមនុស្សចំនួន ២៥,១៥៥ នាក់ ១៩ ភាគរយ គឺជាអ្នកជំងឺថ្មី ២៩ ភាគរយជាស្ត្រី និង ៣៦ ភាគរយជាកុមារ ។ មជ្ឈមណ្ឌលទាំងនេះបានផលិត ជើងសិប្បនិម្មិតចំនួន ៤,៤៦២ និង ជើងរណប ចំនួន ៤,៥៩៣, រទេះជនពិការចំនួន ១,២៧៤ (រួមទាំងរទេះកង់បីផងដែរ) ត្រូវបានចែកចាយ ហើយឧបករណ៍ជំនួយចំនួន ១០,៣៥២គ្រឿងត្រូវបានជួសជុល, គេបានធ្វើការវាយតំលៃលើការព្យាបាលសរីរាង្គកាយចំនួន ១០,០៧១ករណី និងបានបើវគ្គស្តីពីការព្យាបាលសរីរាង្គកាយចំនួន ៧៦,០១៣ លើក, ហើយមនុស្សចំនួន ១២,១៣៦ នាក់ បានប្រើប្រាស់សេវាសយនដ្ឋាននៅក្នុងមជ្ឈមណ្ឌល ។[206] នៅក្នុងឆ្នាំ ២០០៤ ៦២ភាគរយ នៃអ្នកដែលទទួលបានសេវាស្តារកាយសម្បទា គឺជាជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ ។ គេមិនទទួលបានទិន្នន័យស្រដៀងគ្នានេះទេនៅក្នុងឆ្នាំ ២០០៥ ។[207]

អង្គការ ICRC បានគាំទ្រមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួន២កន្លែង នៅក្នុងខេត្តបាត់ដំបង និងកំពង់ស្ពឺ និង រោងចក្រផលិតសំភារៈពិការមួយនៅភ្នំពេញនៅក្នុងឆ្នាំ ២០០៥ ។ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៥ ក្រសួងសុខាភិបាលបាន យល់ព្រមបង្កើនថវិការរបស់ខ្លួនទៅអោយគំរោងដែលគាំទ្រដោយអង្គការ ICRC ។ [208] មជ្ឈមណ្ឌលនៅខេត្តបាត់ដំបង គឺជាអ្នកផ្តល់សេវាដែលធំជាងគេ ដែលផ្តល់សេវាប្រមាណ ២៤ភាគ នៃសេវាស្តារកាយសម្បទាទាំងអស់ក្នុងប្រទេស អោយដល់ខេត្តបាត់ដំបង ក្រុងប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តពោធិសាត់ ។[209] នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួនពីរ បានជួយមនុស្សចំនួន ៧,៨៤៦ នាក់ (៩១០ នាក់ ជាអ្នកជំងឺថ្មី ១៦ ភាគរយ ជាស្ត្រី និង ១៤ ភាគរយជាកុមារ) ផលិតឧបករណ៍សិប្បនិម្មិត ចំនួន១,៩៧១ គ្រឿង (១,៧៦០ គ្រឿងសំរាប់ជនរងគ្រោះ ដែលនៅរស់) និងជើងរណបចំនួន ១,២៨៥ គ្រឿង (៥៩ គ្រឿងសំរាប់ជនរងគ្រោះដែលនៅរស់) និងបានផ្តល់ឈើច្រត់ ជនពិការចំនួន ១,២២៩ គូ ហើយរទេះជនពិការចំនួន៤៩២ គ្រឿង ដែលផលិតដោយអង្គការ JS ត្រូវបានចែកចាយ ។ គេបានធ្វើសកម្មភាពនៅតាមមូលដ្ឋានសរុបចំនួន ៥៦ លើក (២២ លើកពីខេត្តបាត់ដំបង និង ៣៤ លើក ពីខេត្តកំពងស្ពឺ), គេបានធ្វើទស្សនកិច្ចនិងវាយតំលៃចំនួន ៤,១៣២លើក ដែលក្នុងនោះឧបករណ៍សិប្បនិម្មិតចំនួន ២,២៥១គ្រឿង ត្រូវបានជួសជុល និងអ្នកជំងឺចំនួន ៩០៧ នាក់ត្រូវបានគេដឹកទៅកាន់មជ្ឈមណ្ឌលមួយក្នុងចំណោមមជ្ឈមណ្ឌលនានា ។[210]

រោងចក្រផលិតបរិក្ខារថែទាំជនពិការរបស់ ICRC នៅភ្នំពេញ បានបន្តផ្តល់គ្រឿងបរិក្ខារ និង គ្រឿងជំនួយការធ្វើ ដំណើរដោយឥតគិតថ្លៃទៅអោយមជ្ឈមណ្ឌលថែទាំជនពិការទាំងអស់នៅទូទាំងប្រទេស ។ នៅក្នុងឆ្នាំ២០០៥ រោងចក្រ នេះផលិតបានគ្រឿងបរិក្ខារសំរាប់ធ្វើឧបករណ៍ជនពិការ និងគ្រឿងជំនួយការធ្វើដំណើរចំនួនជាង ៩,៥៩០ គ្រឿង ។ [211]

---

[206] DAC Physical Rehabilitation Committee, “Physical Rehabilitation Centre 2005 Statistics Report,” May 2006, pp. 2, 12-14, 18, 22-29.
[207] See *Landmine Monitor Report 2005*, p. 228.
[208] ICRC, “Annual Report 2005,” Geneva, June 2006, p. 192.
[209] For details of the centers, see *Landmine Monitor Report 2005*, p. 228.
[210] ICRC, “Annual Report 2005,” Geneva, June 2006, p. 192; ICRC, “Physical Rehabilitation Programme – Annual Report 2005,” Geneva, July 2006, p. 27; interview with Jöel Nininger, ICRC Cambodia, Battambang, 3 March 2006.
[211] ICRC, “Annual Report 2005,” Geneva, June 2006, p. 192.

អង្គការ ICRC បានបើកវគ្គបណ្តុះបណ្តាលមួយដែលមានរយៈពេល២ខែ នៅក្នុងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មទាំងពីរ ហើយបានឧបត្ថម្ភគ្រូពេទ្យព្យាបាលម្នាក់មកពីមជ្ឈមណ្ឌលនីមួយៗចូលរួមក្នុងកម្មវិធីការបណ្តុះបណ្តាលបន្តមួយ ។[212]

អង្គការ Cambodia Trust (CT) បានជួយឧបត្ថម្ភសេវាស្តារកាយសម្បទានៅតាមមជ្ឈមណ្ឌលនានាក្នុងទីក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងខេត្តកំពង់ឆ្នាំង ។ នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលទាំងនេះបានជួយដល់មនុស្សចំនួន ៥,០៨៧នាក់ (១,២៧១ នាក់ជនរងគ្រោះដែលនៅរស់) : ឧបករណ៍សិប្បនិម្មិតចំនួន ៧៥៨ គ្រឿង និងជើងរណបចំនួន ១,០៥៩ គ្រឿងត្រូវបានផលិត រទេះជនពិការចំនួន ៦២ គ្រឿង ទទួលបានចែកចាយ និងឧបករណ៍ជំនួយចំនួន ២,១៨០ គ្រឿងត្រូវបានជួសជុល ហើយគេបានធ្វើការវាយតំលៃលើការព្យាបាលសរីរាង្គកាយចំនួនចំនួន ១,៧១៥ ករណី និង ការព្យាបាលចំនួន ៤,៩៩១ ករណី ។[213] អង្គការ CT ក៏បានដំណើរការកម្មវិធីចុះមូលដ្ឋាន ដើម្បីជនពិការនៅតាមតំបន់ដាច់ស្រយាល ។[214] មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មនៅក្នុងទីក្រុងភ្នំពេញក៏ជាមន្ទីរពេទ្យ បណ្តុះបណ្តាលសំរាប់សាលាផលិតឧបករណ៍សិប្បនិម្មិត និងជើងរណបកម្ពុជា ដើម្បីផ្តល់ការការបណ្តុះបណ្តាលបច្ចេកទេសខាងផលិតឧបករណ៍សិប្បនិម្មិត និងជើងរណប សំរាប់ប្រទេសកម្ពុជា និងក្នុងតំបន់ ។ ជារៀងរាល់ឆ្នាំ មានសិស្សថ្មីចំនួន ១២នាក់ ចាប់ផ្តើមចូលរៀនក្នុងកម្មវិធីការបណ្តុះបណ្តាលរយៈពេល ៣ឆ្នាំ, គិតត្រឹមខែ មិនា ឆ្នាំ ២០០៦ មានសិស្សចំនួន ៤៩ មកពី ១៤ ប្រទេសហើយ បានចុះឈ្មោះចូលរៀន, ៤១ ភាគរយនៃសិស្សទាំងអស់ជាស្ត្រី និង ១៤ ភាគរយជា ជនពិការ ។[215]

អង្គការ Handicap International (HI) ដំណើរការកម្មវិធីខាងផ្នែកស្តារកាយសម្បទា សមាហរណកម្មផ្នែកសេដ្ឋកិច្ចសង្គម ការប្រមូលទិន្នន័យ ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹងអំពីសិទ្ធនិងសេចក្តីត្រូវការរបស់ជនពិការ។ នៅក្នុងឆ្នាំ ២០០៥ អង្គការ HI-Belgium បានជួយទ្រទ្រង់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួនពីរកន្លែង (នៅខេត្តសៀមរាប និងខេត្តតាកែវ) ហើយ អង្គការ HI-France បានជួយទ្រទ្រង់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម ១ កន្លែង (នៅខេត្តកំពង់ចាម) ដោយផ្តល់នូវសេវាព្យាបាលសរីរាង្គកាយ ឧបករណ៍សិប្បនិម្មិត និងឧបករណ៍ជំនួយផ្សេងៗទៀត កម្មវិធីចុះតាមមូលដ្ឋាន និងការបណ្តុះបណ្តាលជាក់ស្តែងនៅកន្លែងធ្វើការដល់អ្នកបច្ចេកទេស និងអ្នកព្យាបាលសរីរាង្គកាយជាច្រើន។ នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលទាំងពីរដែលឧបត្ថម្ភដោយអង្គការ HI-B បានជួយមនុស្ស ចំនួន ៤,៣៤៥ នាក់ : ឧបករណ៍សិប្បនិម្មិតចំនួន ៧៩៥ គ្រឿង និងជើងរណបចំនួន ៨៤៤ គ្រឿង ត្រូវបានផលិត, រទេះជនពិការចំនួន ២០៨ គ្រឿងត្រូវបានចែកចាយ និង ឧបករណ៍ជំនួយចំនួន ២,៤៩៨ គ្រឿងត្រូវបានជួសជុល, ហើយគេក៏បានធ្វើការវាយតំលៃលើការព្យាបាលសរីរាង្គកាយចំនួន ២,៣៦៥ ករណី និងការព្យាបាលចំនួន ១៥,៤២៦ ករណី ។ នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលដែលឧបត្ថម្ភដោយអង្គការ HI-France បានជួយមនុស្សចំនួន ១,២៨៤ នាក់: ឧបករណ៍

---

[212] Ibid; ICRC, "Physical Rehabilitation Programme – Annual Report 2005," Geneva, July 2006, p. 27; interview with Jöel Nininger, ICRC Cambodia, Battambang, 3 March 2006.

[213] DAC Physical Rehabilitation Committee, "Physical Rehabilitation Centre 2005 Statistics Report," May 2006, pp. 12-14, 18, 22-29; response to Landmine Monitor Questionnaire by Mary Scott, Country Manager, Cambodia Trust, 13 March 2006.

[214] See *Landmine Monitor Report 2005*, p. 229.

[215] Response to Landmine Monitor by Mary Scott, Cambodia Trust, 13 March 2006; see *Landmine Monitor Report 2005*, p. 229.

សិប្បនិម្មិតចំនួន ២៦៤គ្រឿង និង ជើងរណបចំនួន ៤៥៨ គ្រឿង ត្រូវបានផលិត, រទេះជនពិការចំនួន ១១៣ គ្រឿង ត្រូវបានចែកចាយ និង ឧបករណ៍ជំនួយចំនួន ៤៤៩ គ្រឿងត្រូវបានជួសជុល , ហើយគេក៏បានធ្វើការវាយតំលៃលើការព្យាបាលសរីរាង្គកាយចំនួន ១,២៦២ ករណី និងការព្យាបាលចំនួន ៦,១៧១ ករណី។[216] កម្មវិធីស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏របស់អង្គការ HI ផ្តោតទៅលើការតាមដានវេជ្ជសាស្ត្រ ការគាំទ្រផ្នែកចិត្តសាស្ត្រសង្គម ការកាត់បន្ថយភាពក្រីក្រ និងការធ្វើសមាហរណកម្មផ្នែកសេដ្ឋកិច្ចសង្គមរបស់ជនពិការតាមរយៈក្រុមជួយខ្លួនឯងផ្សេងៗការស្នើអោយចូលរៀនក្នុងកម្មវិធីការបណ្តុះបណ្តាលនានា និងកម្មវិធីផ្តល់ជំនួយជាទ្រង់ទ្រាយតូច។ អង្គការ HI ក៏បានគាំទ្រដល់សកម្មភាពកីឡាជនពិការនៅក្នុងខេត្តបាត់ដំបង និងសៀមរាប និងបានជួយជ្រោមជ្រែងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម (Para-Tetra) របស់រដ្ឋ ដែលជាផ្នែកស្តារលទ្ធភាពអ្នករបួសឆ្អឹងកង នៅក្នុងខេត្តបាត់ដំបង។[217]

អង្គការ Veterans International Cambodia បានដំណើរការមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មចំនួនបី កន្លែងនៅក្នុងទីក្រុងភ្នំពេញ,ខេត្តក្រចេះ និងខេត្តព្រៃវែងហើយក៏បានផ្តល់សេវាស្តារលទ្ធភាពពលកម្មនៅតាមសហគមន៏ ក្រុមចុះមូលដ្ឋាន និង ការបញ្ជូនទៅរកសេវាផ្សេងៗទៀត ។ នៅក្នុងឆ្នាំ ២០០៥ មជ្ឈមណ្ឌលចំនួនបីកន្លែងបានជួយជនរងគ្រោះ ចំនួន ៣ ៧៣៣ នាក់ : ឧបករណ៍សិប្បនិម្មិតចំនួន ៦៧៤ គ្រឿង និងជើងរណបចំនួន ១,២៤២ គ្រឿង ត្រូវបានផលិត, រទេះជនពិការចំនួន ៣៩០ គ្រឿងត្រូវបានចែកចាយ និងឧបករណ៍ជំនួយចំនួន ១,៤២៧ គ្រឿងត្រូវបានជួសជុល, ហើយគេក៏បានធ្វើការវាយតំលៃលើការព្យាបាលសរីរាង្គកាយចំនួន ១,៣៧៨ ករណី និងការព្យាបាលចំនួន ៣២,២២៤៥ ករណី។[218]

អង្គការផ្សេងៗទៀតដែលបានផ្តល់ជំនួយជនរងគ្រោះ ដែលនៅរស់ក្នុងប្រទេសកម្ពុជាត្រូវបានគេដាក់បញ្ចូលក្នុង*របាយការណ៍ត្រួតពិនិត្យមីនកប់ដីឆ្នាំ២០០៥*។ [219] អ្នកត្រួតពិនិត្យមីនកប់ដីបានទទួលព័ត៌មានស្តីពីសកម្មភាពនានានៅក្នុងរយៈពេលធ្វើរបាយការណ៍នេះពីអង្គការមួយចំនួនដូចខាងក្រោម ។

មជ្ឈមណ្ឌលវះកាត់ Ilaria Alpi របស់អង្គការ Italian NGO Emergency នៅក្នុងខេត្តបាត់ដំបងផ្តល់នូវផ្តល់នូវជំនួយផ្នែកវះកាត់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយសារសង្គ្រាមរួមទាំងអ្នករងគ្រោះដោយសារគ្រាប់មីនផងដែរ នៅក្នុងឆ្នាំ២០០៥ អង្គការ Emergency បានព្យាបាលអ្នករងរដោយសារគ្រាប់មីនថ្មីចំនួន ១០៣ ករណី និងអ្នករងគ្រោះដោយសារគ្រាប់មិនទាន់ផ្ទុះចំនួន៦៤ករណី ។ អង្គការ Emergency បានផ្តល់ការវះកាត់ឡើងវិញដល់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ចំនួន ៨៥នាក់ និងជនរងគ្រោះដោយសារ គ្រាប់មិនទាន់ផ្ទុះដែលនៅរស់ចំនួន ៦នាក់។ ទទួលអ្នករងគ្រោះដោយសារភាពតក់ស្លុតមកពីបណ្តាខេត្ត-ក្រុង មួយចំនួនត្រូវបានទទួលអោយស្នាក់នៅព្យាបាល ដូចជាខេត្តបាត់ដំបង ក្រុងប៉ៃលិន ខេត្តបន្ទាយមានជ័យ តាកែវ សៀមរាប ឧត្តរមានជ័យ កំពង់ធំ និងក្រុងភ្នំពេញ។[220]

មូលនិធិជំនួយជនរងគ្រោះដោយសារគ្រាប់មីន ដែលត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ ដើម្បីបំពេញតំរូវការ

---

[216] DAC Physical Rehabilitation Committee, "Physical Rehabilitation Centre 2005 Statistics Report," May 2006, pp. 12-14, 18, 22-29; response to Landmine Monitor Questionnaire by Mary Scott, Cambodia Trust, Phnom Penh, 13 March 2006.

[217] Response to Landmine Monitor Questionnaire by Bruno Leclerq, HI-Belgium, Cambodia, 20 March 2006; see *Landmine Monitor Report 2005*, p. 230.

[218] DAC Physical Rehabilitation Committee, "Physical Rehabilitation Centre 2005 Statistics Report," May 2006, pp. 12-14, 18,22-29.

[219] See *Landmine Monitor Report 2005*, pp. 227-232.

[220] Statistics provided by Cino Bendinelli, General Surgeon-Medical Coordinator, Emergency, Battambang, 1 March 2006.

របស់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ក្នុងប្រទេសកម្ពុជា ផ្នែកសមាហរណកម្មខាងផ្នែកសេដ្ឋកិច្ច សង្គម និងកាយសម្បទា ទទួលបានទឹកប្រាក់ចំនួន A$500,000 (ស្មើនឹង$381,350 ដុល្លារអាមេរិក) នៅក្នុងឆ្នាំ ២០០៥ពីអង្គការ AusAID ។ កិច្ចការនេះគឺមានបំណងជួយដៃគូផ្តល់មូលនិធិរួមមាន Veterans International Cambodia, Handicap International, Disability Development Services Pursat, Cambodian National Volleyball League និង Cambodia Trust ដើម្បីលើកកំពស់ការចូលរួមផ្នែកសេដ្ឋកិច្ចសង្គមកិច្ច ក៏ដូចជាការគាំទ្រចំពោះជនពិការទូទាំងប្រទេសកម្ពុជា ។[221] អង្គការ AusAID បានស្រាវជ្រាវរកជំរើសដើម្បីអភិវឌ្ឍន៏កម្មវិធី ជំនួយអោយបានច្រើនជាងនេះ នៅក្នុងឆ្នាំ ២០០៦ ។[222]

សមាគមន៏ Association for Aid and Relief Japan បានដំណើរការសេវាផលិតរទេះជនពិការ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគៀនឃ្លាំង នៅក្នុងទីក្រុងភ្នំពេញ ។ នៅក្នុងឆ្នាំ ២០០៥ សមាគមនេះផលិតរទេះជនពិការ បានចំនួន ២៩៩ គ្រឿង រទេះកង់បី ១ គ្រឿង និងបានចែកចាយរទេះជនពិការចំនួន ២៧២ គ្រឿង, មនុស្សចំនួន ៣៧ នាក់ ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ រួមមានជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ចំនួន ៦នាក់ ។ ពីឆ្នាំ ១៩៩៣ ដល់ ឆ្នាំ ២០០៥ មនុស្សចំនួន ៥០១ ត្រូវបានបណ្តុះបណ្តាល រួមទាំងជនរងគ្រោះដែលនៅរស់ ចំនួន ២១៥ នាក់ផង ។[223]



អង្គការ Jesuit Service Cambodia បានផលិតរទេះជនពិការបានចំនួន ១,១៥៥ គ្រឿង និង រទេះកង់បី ៦៤ គ្រឿង នៅក្នុងឆ្នាំ ២០០៥ ដែលត្រូវបានចែកចាយដោយអង្គការផ្សេងៗទៀត, បុគ្គលិកចំនួន ២១ នាក់ក្នុង ចំណោមបុគ្គលិក ២៤ នាក់គឺជាជនរងគ្រោះដោយសារគ្រាប់មីន ។[224] អង្គការនេះក៏បានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈនៅសាលាបន្ទាយព្រាប,នៅក្នុងឆ្នាំ២០០៥ សិស្សពិការចំនួន ១១៦ នាក់ រួមមាន ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ចំនួន ៤០នាក់ បានចូលសិក្សាវគ្គបណ្តុះបណ្តាលរយៈពេល១ឆ្នាំ ខាងផ្នែកកសិកម្ម ចំលាក់ ជាងឈើ ជួសជុលគ្រឿងអេឡិត្រូនិក ជួសជុលគ្រឿងម៉ាស៊ីន តម្បាញ កាត់ដេរ និងអក្ខរកម្ម ។ អង្គការ JS ធ្វើការជាមួយជនពិការចំនួន ២៥០ នាក់នៅក្នុងខេត្ត សៀមរាប នៅក្នុងភូមិចំនួន១៣ ក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ នៅក្នុងភូមិចំនួន២២៩ ក្នុងខេត្តឧត្តរមានជ័យ និងក្នុងអតីតតំបន់ខ្មែរក្រហមនៅខេត្តកណ្តាល ។ ក្រុមនានាដែលមានជនរងគ្រោះដោយសារគ្រាប់មីន ដែលនៅរស់មួយចំនួនផ្តល់នូវកាគាំពារផ្នែកសរីរាង្គកាយដល់អ្នកភូមិ និងជួយពួកគេក្នុងការធ្វើផែនការកម្មវិធីដើម្បីសុខភាព និងវិបុលភាពរបស់ខ្លួនគេផ្ទាល់ ។ កម្មវិធីនោះរួមមានការសង់ផ្ទះសំបែង អណ្តូងទឹក អាហារហូបចុកបន្ទាន់ ជំនួយសាលារៀនសំរាប់ក្មេងៗ ការផ្តល់សេវាសុខភាព និងទីផ្សារតាមរយៈការសាងសង់ស្ពាន

[221] AusAID, “Aid Activities in Cambodia,” www.ausaid.gov.au, accessed 29 May 2006.
[222] Information provided by Stephen Close, AusAID, Cambodia, 23 March 2006.
[223] Response to Landmine Monitor Questionnaire by Huoy Socheat, Director of Vocational Training, Association for Aid and Relief Japan, Phnom Penh, 2 February 2006.
[224] Email from Nhar Ny, Jesuit Service Cambodia, 7 June 2006.

និងផ្តល់។[225] អង្គការ JS ក៏បានផ្តល់នូវការ បកប្រែនូវផែនការ និងទិសដៅជាភាសាខ្មែរសំរាប់ជំនួយជនរងគ្រោះ ដើម្បីជំរុញលើកទឹកចិត្តអោយមានការចូលរួមរបស់ជនពិការ និងអ្នកផ្តល់សេវា។[226]

អង្គការ Disability Development Services Pursat ដែលជាអង្គការក្រៅរដ្ឋាភិបាលខ្មែរមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៣ ផ្តល់សេវាស្តារកាយសម្បទា ការគាំពារផ្នែកសរីរាង្គកាយ ជួយអោយកុមារបានចូលរៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងលើកកំពស់ការយល់ដឹងលើបញ្ហាពិការភាព ក្នុងភូមិ ៦ នៅក្នុងតំបន់ ដាច់ស្រយាលនៃខេត្តពោធិសាត់។ នៅក្នុងឆ្នាំ២០០៥ គំរោងនេះបានជួយជនពិការចំនួន ១៨៤នាក់រួមទាំង ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ចំនួន ៤៦នាក់ (ស្មើនឹង២៥ភាគរយ)។ នៅភូមិពីរក្នុងចំណោម ភូមិទាំងនោះ គេកំពុងធ្វើការបោសសំអាតមីន ហើយភូមិពីរទៀតជាភូមិដែលពីមុនមានគ្រាប់មីន។ នៅក្នុងខែសីហា ឆ្នាំ២០០៥ ដោយសហការជាមួយរោងជាងអភិវឌ្ឍបច្ចេកទេស អង្គការនេះបានដាក់ចេញនូវគំរោង អនាម័យនិងទឹកស្អាតនៅក្នុងភូមិទាំង ៦នោះ ។ គំរោងស្តារលទ្ធភាពពលកម្មត្រូវបានពង្រីកទៅកាន់ភូមិបីទៀត នៅក្នុងខែមករាឆ្នាំ ២០០៦ ។[227]

កម្មវិធី The Cambodian War Amputees Rehabilitation Society ផ្តល់នូវការបណ្តុះបណ្តាលដល់ជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ និងជនពិការដទៃទៀតផ្នែកធ្វើជំនួញ និងសេវាបង្កើតប្រាក់ចំណូលផ្សេងៗ, អ្នកដែលបានរៀនកម្មវិធីចប់ត្រូវបានគេជួយអោយបង្កើតសហគ្រាសធុនតូចផ្ទាល់ខ្លួនគេ ។ នៅក្នុងខែ ធ្នូ ឆ្នាំ២០០៥ កម្មវិធីថ្មីមួយបានចាប់ដំណើរការនៅក្នុងខេត្តបន្ទាយមានជ័យសំរាប់ជនពិការចំនួន១៦៤នាក់ ភាគច្រើនជាជនរងគ្រោះដោយសារគ្រាប់មីន ដែលនៅរស់រានមានជីវិត។[228] អង្គការ Terre des Hommes បានផ្តល់ទឹកប្រាក់ចំនួន ១៩,៤៥៨ ដុល្លាសហរដ្ឋ ដើម្បីបង្កើតគំរោងឥណទានធុនតូចមួយ។ ក្រោយពេលស្តារលទ្ធភាព ជនរងគ្រោះដែលនៅរស់ទទួលបានឥណទាន ជាចំបងសំរាប់អភិវឌ្ឍសកម្មភាពធ្វើកសិកម្ម ហើយក៏សំរាប់បង្កើតមុខរបរតូចតាចផ្សេងៗផងដែរ។[229] នៅក្នុងឆ្នាំ២០០៥ បុរស និងស្ត្រីពិការចំនួន៨៤៣នាក់ បានទទួលផលប្រយោជន៍ពីកម្មវិធីនេះក្នុងនោះ ៦៣៨ នាក់ ជាជនរងគ្រោះដោយសារ គ្រាប់មីនដែលនៅរស់។[230]

អង្គការ World Vision Cambodia បានដំណើរការគំរោងកំចាត់មីនរួមមួយដែលប្រើប្រាស់គំរោងអភិវឌ្ឍន៏ផ្ទៃដី បណ្តុះបណ្តាល និងឥណទានធុនតូច ដើម្បីជួយសហគមន៏ដែលរងគ្រោះ។ នៅក្នុងឆ្នាំ ២០០៥ ក្មេងៗជាង ៥,០០០នាក់ និងក្រុមគ្រួសាររបស់គេបានទទួលផលប្រយោជន៏ រួមមានជនរងគ្រោះដែលនៅរស់ផងដែរ ។ បន្ថែមពីលើការអប់រំការទទួលបានទឹកស្អាត និងគ្រឿងបរិក្ខាអនាម័យគ្រួសារដែលគ្មានដីធ្លីចំនួន ៩១ គ្រួសារទទួល បានប័ណ្ណកម្មសិទ្ធដី មនុស្សចំនួន ១,៦៧៩ នាក់ទទួលបានការបណ្តុះបណ្តាលខាងបំនិនជីវិត និង ១០៣ គ្រួសារ ទទួលបានកូនជ្រូកយកទៅចិញ្ចឹម។ ជនរង

---

225 Jesuit Service Cambodia, "Jesuit Service Report," December 2005 and 24 February 2006; see *Landmine Monitor Report 2005*, p. 230.
226 Email from Nhar Ny, Jesuit Service Cambodia, 7 June 2006.
227 Response to Landmine Monitor Questionnaire by Steve Harknett, Advisor, Disability Development Services Pursat, Pursat, 10 March 2006.
228 See *Landmine Monitor Report 2005*, p. 230.
229 Information from Actiongroup Landmine.de member in email from Markus Haake, Coordinator, Actiongroup Landmine.de, 8 June 2006.
230 Information provided by Hem Chan Piseth, Deputy Managing Director, CWARS, Phnom Penh, 7 July 2006.

គ្រោះដែលនៅរស់ទទួលបានការបណ្តុះបណ្តាលខាងការធ្វើកសិកម្មក៏ដូចជាផ្នែកជួសជុលគ្រឿងម៉ាស៊ីន ទូរទស្សន៍និងវិទ្យុ ។[231]

អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ បានធ្វើបញ្ជីរាយនាមអង្គការផ្សេងៗជាច្រើនទៀតដែលជួយជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ និងជនពិការដទៃទៀតតាមរយៈក្រុមដែលមានឈ្មោះថា "ក្រុមជួយខ្លួនឯង " ជំនួយតាមសហគមន៍ ប្រព័ន្ធបញ្ជូនអ្នកជំងឺ ការអប់រំ ការផ្តល់ប្រឹក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការចុះតាមមូលដ្ឋាន ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនបានប្រកាន់យកវិធីសាស្ត្រអភិវឌ្ឍន៍សំរាប់ការជំនួយជនរងគ្រោះដែលនៅរស់ ដែលតាមវិធីនេះជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់រានមានជីវិតត្រូវបានគេជួយជាមួយនឹងសមាជិកដទៃទៀតក្នុងសហគមន៍ ។[232]

មជ្ឈមណ្ឌលជាតិសំរាប់ជនពិការបានបង្កើតទិន្នន័យកម្មករពិការ ដែលមានមុខនាទីសំខាន់សំរាប់ជួយជនពិការនៅទីក្រុង ដែលកំពុងស្វែងរកការងារធ្វើ ប៉ុន្តែក្នុងចំណោមជនពិការដែលបានចុះឈ្មោះចំនួន ១,៥០០នាក់ មានតែ ១២៥ ប៉ុណ្ណោះបានទទួលការងារជារៀងរាល់ឆ្នាំ ។ ការត្រួតពិនិត្យសេវាផ្នែកសមាហរណកម្មនិងវិជ្ជាជីវៈនានា បានសន្និដ្ឋានថាបើទោះបីជាសិស្សដែលបានរៀនចប់ដោយជោគជ័យមានចំណេះដឹងនិងជំនាញប្រសើរជាងមុន ក៏ដោយមិនមានមនុស្សច្រើនទេដែលទទួលបានការងារធ្វើយូរអង្វែងជានិច្ចកាលដោយសារតែការរើសអើង ។[233] ឧទាហរណ៍បានហាមឃាត់សូម្បីតែជនពិការបន្តិចបន្តួចមិនអោយធ្វើជាគ្រូបង្រៀននៅក្នុងសាលារដ្ឋ ។[234]

កូនៗរបស់ជនរងគ្រោះដោយសារគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះដែលនៅរស់ ឬរបស់អ្នកដែលបានស្លាប់ក្នុងឧបទ្ទវហេតុគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះជានិច្ចកាលមិនអាចរៀនសូត្របាន ដោយសារតែការសិក្សាត្រូវបង់ថ្លៃច្រើនពេកសំរាប់គ្រួសារទាំងនោះ ។ ក្មេងៗប្រមាណ ៤០០,០០០ នាក់មិនបានចូលរៀនពីព្រោះតែតំលៃការសិក្សា និងចំងាយផ្លូវឆ្ងាយ ។ អង្គការការិយាល័យអប់រំពិសេស (The Special Education Bureau) រួមជាមួយជំនួយបច្ចេកទេសពីអង្គការ DAC បានផ្តល់នូវការអប់រំ ដែលមានលក្ខណៈរួមបញ្ចូល (Inclusive education) ។ កម្មវិធីនេះផ្តោតទៅលើការលើកកំពស់ការយល់ដឹងអំពីពិការភាពសំភារៈ បង្រៀនសំរាប់គ្រូដែលបង្រៀនក្មេងៗពិការនៅក្នុងថ្នាក់ ហើយជួយក្រសួងអប់រំក្នុងការបង្កើតគោលនយោបាយអប់រំ ដែលមានលក្ខណៈរួមបញ្ចូល ។[235]

អង្គការក្រុមបាល់ទះជនពិការជាតិកម្ពុជា ផ្តល់នូវសកម្មភាពកីឡាផ្សេងៗដល់ជនពិការ ។ អង្គការនេះក៏បានផ្តល់ដំបូន្មានស្តីអំពីកម្មវិធីកីឡានានានៅក្នុងមជ្ឈមណ្ឌលស្តារកាយសម្បទានានា និងជួយក្នុងការសាងសង់ទីកន្លែងហាត់ប្រាណផ្សេងៗនៅតាមបណ្តាខេត្តក្នុងប្រទេសកម្ពុជា ។ សមាជិកចំនួនជាង ៧០ភាគរយ ជាជនរងគ្រោះដោយសារគ្រាប់មីនដែលនៅរស់ ។ នៅថ្ងៃទី៣០ ខែមិនា ឆ្នាំ២០០៦ អង្គការនេះទទួលបានចំណាត់ថ្នាក់ការហ្វឹកហ្វឺនល្អបំផុត "best practice"

---

[231] Response to Landmine Monitor Questionnaire by Penh Bunnarith, Mine Programme Manager, World Vision, Phnom Penh, 12 February 2006; World Vision, www.worldvision.com.au, accessed 6 June 2006.

[232] See *Landmine Monitor Report 2004*, pp. 269-270.

[233] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, p. 126.

[234] US Department of State, "Country Reports on Human Rights Practices-2005: Cambodia," Washington DC, 8 March 2006.

[235] "Final Report of the Sixth Meeting of States Parties / Zagreb Progress Report," Part II, Annex V, Zagreb, 28 November-2 December 2005, pp. 126-127.

ពីគណៈកម្មាធិការរៀបចំឆ្នាំអន្តរជាតិកីឡាសហប្រជាជាតិ "UN International Year of Sports" ។[236]

## គោលនយោបាយស្តីពីពិការភាព និងការអនុវត្ត

ប្រទេសកម្ពុជាពុំមានច្បាប់ការពារសិទ្ធិជនពិការទេ បើទុកជាមានពង្រាងច្បាប់មួយនៅក្នុងឆ្នាំ២000 ក៏ដោយ ។ [237] ការធ្វើសេចក្តីព្រៀងច្បាប់បែបនោះឡើងវិញនៅឆ្នាំ ២00៤ (ពង្រាងច្បាប់ស្តីពីសិទ្ធិជនពិការ) ត្រូវបានដាក់ជូនទៅក្រុមប្រឹក្សារដ្ឋមន្ត្រីនៅក្នុងឆ្នាំ ២00៥ ប៉ុន្តែមិនទាន់ត្រូវបានអនុម័តនៅឡើយរហូតមកដល់ខែ មិថុនាឆ្នាំ២00៦ ។[238] កថាខ័ណ្ឌនៃច្បាប់នេះគឺដកស្រង់ចេញពីទិសដៅដែលប្រទេសកម្ពុជាបានថ្លែងនៅក្នុងកិច្ចប្រជុំលើកទី៦ របស់រដ្ឋជាសមាជិកនាខែវិច្ឆិកា-ធ្នូឆ្នាំ២00៥ ។

នាយកដ្ឋានស្តារលទ្ធភាពពលកម្មរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាអ្នកទទួលខុសត្រូវក្នុងការធ្វើគោលនយោបាយ ដើម្បីការពារសិទ្ធិជនពិការ ។[239] ក្រសួងនេះបានដំណើរការគំរោងសោធន៏និវត្តន៏សំរាប់អតីតមន្ត្រីរាជការ និងជនពិការដែលជាអតីតកងទ័ពរដ្ឋាភិបាល ។ ប្រាក់ឧបត្ថម្ភនោះមានចំនួនតិចតួចស្តួចស្តើង ប៉ុន្តែវាជាប្រភពប្រាក់ចំនូលសំខាន់និងជាប្រចាំ ។ តាមសេចក្តីរាយការណ៏បានអោយដឹងថា ការលំបាកដែលគេជួបប្រទះគឺការបើកប្រាក់មិនទៀងទាត់និងមានការយឺតយ៉ាវ ការស៊ីសំណូក និងការលក់ឈ្មោះក្នុងពេលមានតំរូវការចាំបាច់ ។ [240] រដ្ឋាភិបាលបានទទួលស្គាល់បញ្ហាទាំងនេះ ក៏ប៉ុន្តែនៅក្នុងខែ មិនាឆ្នាំ ២00៦ នាយកដ្ឋានអតីតយុទ្ធជននៃក្រសួងនេះ ដែលជាអ្នកទទួលបន្ទុកផ្នែកសោធននិវត្តន៏បានថ្លែងថា ខ្លួននិងកាត់បន្ថយប្រាក់សោធន ពីព្រោះប្រាក់សោធនជាច្រើនត្រូវបានផ្តល់ទៅអោយអ្នកដែលលែងត្រូវនឹងលក្ខណៈវិនិច្ឆ័យបន្តទៀត ។ ប្រាក់សោធនត្រូវបានគេផ្តល់ទៅអោយតែជនណា ដែលជាអតីតយុទ្ធជនដែលពិការ ឬចូលនិវត្តន៏ ប្តីឬប្រពន្ធរបស់ពួកគេ ដែលមេម៉ាយនិងកូនរបស់ពួកគេ ដែលមានអាយុក្រោម ១៨ឆ្នាំ ។ ក្រសួងមានអតីតយុទ្ធជនដែលពិការឬចូលនិវត្តន៏ប្រមាណ ១00,000នាក់ ក្នុងបញ្ជី ប៉ុន្តែបានប៉ាន់ស្មានថាក្មេងៗដែលលើសអាយុប្រមាណ ៦0 000នាក់ កំពុងទទួលបានប្រាក់សោធន ។[241]

អង្គការក្រៅរដ្ឋាភិបាលនានា គ្រប់គ្រងកម្មវិធីជាច្រើនដែលធ្វើអោយមានការរីកចំរើនគួរអោយកត់សំគាល់ក្នុងការព្យាបាលនិងស្តារលទ្ធភាពពលកម្មដល់ជនពិការ ។ ប៉ុន្តែគេបានរាយការណ៏អោយដឹងថា ជនពិការបានជួបប្រទះនូវការរើសអើងពីសង្គមគួរអោយព្រួយបារម្ភ ជាពិសេសក្នុងការទទួលបានការងារជំនាញ ។ ពុំមានការដាក់តំរូវអោយអគារផ្សេងៗ និង សេវានានារបស់រដ្ឋាភិបាលអាចអោយជនពិការប្រើប្រាស់បាន ហើយក៏គ្មានកិច្ចខិតខំប្រឹងប្រែងពេញលេញណាមួយត្រូវបានគេធ្វើឡើង ដើម្បីជួយអោយជនពិការបានបំពេញតួនាទីជាពលរដ្ឋបានដោយពេញលេញឡើយ ។[242]

---

236 Emails from Christopher Minko, Secreatry-General, CNVLD, Phnom Penh, 1 and 30 March 2006; www.standupcambodia.org, accessed 19 June 2006.
237 See *Landmine Monitor Report 2004*, p. 272.
238 See *Landmine Monitor Report 2005*, p. 232.
239 US Department of State, "Country Reports on Human Rights Practices-2005: Cambodia," Washington DC, 8 March 2006.
240 CCC, "The Challenge of Living with Disability in Rural Cambodia," March 2006, p. 15.
241 Cheang Soka, "Move to trim $1-million-a-month veterans pensions," *Phnom Penh Post*, 10-23 March 2006, p. 4.
242 US Department of State, "Country Reports on Human Rights Practices-2005: Cambodia," Washington DC, 8 March 2006.